# សាងខ្លួនឯងដើម្បី ក្លាយជាកំពូលអ្នកដឹកនាំ




...៦.
...៥ក

និង-គុណសម្បត្តិ ៥០ ប្រការ

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh www.elibraryofcambodia.org**

www.budinst.gov.kh www.elibraryofcambodia.org

# សាងខ្លួនឯង

## SELF - CONSTRUCTION

រួបរួមរៀបរៀង

ដោយ

ស៊ា ប៊ុន តេង

*

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ព.ស. ២៥១៨ គ.ស. ១៩៧៣

រក្សាសិទ្ធិ



www.budinst.gov.kh www.elibraryofcambodia.org

# វាចាអ្នករួបរួមរៀបរៀង

លោកអ្នកអានជាទីគោរព !

យើងខ្ញុំបានជំរាបហើយនៅក្នុងការបោះពុម្ពសៀវភៅ <<មនោមយិទ្ធិ >> លើកទីពីរ ថាយើងខ្ញុំនិងនាំមកជូនជាបន្ត នូវសៀវភៅមួយទៀតឈ្មោះ <<***សាងខ្លួនឯង*** >> ទុកដូចជាភាគទី២ របស់សៀវភៅ **មនោមយិទ្ធិ**នោះ ដូច្នេះមុននឹងយើងខ្ញុំចរចាជាមួយនិងលោកអ្នកអានជាទីគោរពបន្តិចនោះ យើងខ្ញុំសូមខ្ចីពាក្យឃ្លោងមួយបទរបស់លោក សុតន្តប្រីជា ឥន្ទ មកជាបទផ្ដើម :

***អ្នកប្រាជ្ញឃើញភ័យមិនទាន់ដល់ យោបល់គិតវៀរពីចម្ងាយ***
***លុះដល់ឃើញភ័យមកដល់កាយមុខនៅពព្រាយឥតភិតភ័យ ។***

យើងខ្ញុំសូមជំរាប និងសូមទោសជាមុន ចំពោះលោកអ្នកអានជាទីគោរពថា យើងខ្ញុំពុំមែនមានសមត្ថភាពគ្រប់គ្រាន់ ដូចមានក្នុងសៀវភៅ **មនោមយិទ្ធិ** ឬសៀវភៅ **សាងខ្លួនឯង** នេះហើយនោះទេ តែយើងខ្ញុំមានជំនឿដ៏ឥតងាករេ ទៅលើគោលការណ៍ទាំងនោះ និងតាំងចិត្តព្យាយាម ឥតរួញរា ប្រតិបត្តិទៅតាមលទ្ធភាពដែលមាន ។ ដូច្នេះមិនមែនជាការអស្ចារ្យអ្វីចំពោះលោកអ្នកអានជាទីគោរពទេ អំពីរូបយើងខ្ញុំជាអ្នករួបរួមរៀបរៀងនោះ ការអស្ចារ្យនោះ គឺស្ថិតនៅលើលោកអ្នកអានជាទីគោរព មានសមត្ថភាពគ្រប់គ្រាន់ និងជ្រើសរើសយក<<ល្អ>>បានចេញពីតម្រានេះ



www.budinst.gov.kh www.elibraryofcambodia.org

ប៉ុណ្ណោះ ឬក៏ហោចបំផុតអោយបានស្របទៅនឹងឃ្លោងមួយបទខាងលើ ដែលយើងខ្ញុំខ្ចីពីលោកនីតិបករណ៍ មកបង្ហាញនេះ ស្រាប់ ។

យើងខ្ញុំសូមផ្ញើជូនការបារម្ភ តូចមួយទៀតថា និស្ស័យជនជាតិខ្មែរយើងដោយច្រើន ដែលនៅមានជំនឿទៅលើ <<***ព្រេងសំណាង*** >> ព្រោះចាស់ទុំបរមបូរាណ យើងតែងទូន្មានមកយ៉ាងនេះ ដូច្នេះយើងខ្ញុំគ្មានឱវាទអ្វីទេ គ្រាន់តែសូមស្នើអោយលោកអ្នកអានជាទីគោរព បកស្រាយពាក្យ <<***ព្រេងសំណាង***>>នេះអោយបានច្បាស់លាស់ទៅ និងឃើញបានថា ចាស់ទុំបរមបូរាណយើងលោកទូន្មានត្រូវណាស់ តែអ្នកស្តាប់ និងជឿតាមនោះ ប្រែន័យទៅខុសស្រឡះថាជា<<***ព្រហ្មលិខិត ឬ បុណ្យពីអតីតជាតិទៅវិញ*** >> ។

ពាក្យថា <<***ព្រេងសំណាង*** >>នេះ តាមនិរុត្តិសាស្ត្រ Etymology និងវេយ្យាករណ៍សាស្ត្រនោះ ពុំមែនបានន័យថា ព្រហ្មលិខិត ឬ បុណ្យពីអតីតជាតិនោះទេ ។ ពាក្យថា ព្រេង អាចមកពីពាក្យថា រវាំងក្លាយជារវេង ហើយខ្មែរយើងមានការនិយាយពាក្យត្រួតយកខ្យល់ខ្លីជាផង និងអក្សរ (រ) អាចផ្លាស់ (ព) បានផងនោះពាក្យថា រវាំង - រវេង ក្លាយទៅជា ព្រេង ប្រែថាប្រយ័ត្នទុកជាមុន ពាក្យព្រេងនេះយកទៅភ្ជាប់និងពាក្យថា សំណាងដែលជាក្រិតនាម (Nom dérivé) មកពីកិរិយាស័ព្ទថា សាង ប្រែថា ធ្វើអោយកើត - បង្កបង្កើត ទៅក៏បានន័យថា <<***ការធ្វើការប្រយ័ត្នទុកជាមុន*** >> ឬថា <<***ធ្វើទុកដោយប្រុងប្រយ័ត្ន*** >> ឬថា <<***សាងដោយរវាំង***>>ដល់និយាយ


www.budinst.gov.kh www.elibraryofcambodia.org

ខ្លីថា << ***សំណាងព្រេង*** >> លុះត្រឡប់ពាក្យមុខទៅជាក្រោយក៏បានទៅជា << ***ព្រេងសំណាង*** >> ដែលនាំអោយមានការភាន់ច្រឡំនេះឯង ។

ការវែកញែកពាក្យនេះ គឺសំរបទៅនឹងឃ្លោងខាងលើ ដែលលោកចិត្តកវី សុតន្តប្រីជា យើងបានតែងទុកមក ។

ចំពោះការបកស្រាយពាក្យព្រេងសំណាងនេះ គឺមតិយើងខ្ញុំផ្ទាល់ យើងខ្ញុំសូមផ្ញើទុកអោយអ្នកអក្សរសាស្ត្រស្រាវជ្រាវដោយសេរីតទៅទៀតចុះ ។

ចំពោះយើងខ្ញុំធ្វើការបកស្រាយនេះ ក៏គឺដើម្បីទាញការប្រុងប្រយ័ត្នកុំអោយច្រឡំថា សៀវភៅនេះ ជាក្បួនអោយធ្វើបុណ្យទានទុកជាជាតិមុខ ចំពោះលោកអ្នកអានជាទីគោរព និងបកប្រែឈ្មោះសៀវភៅនេះ ទៅតាមគោលបំនងរបស់យើងខ្ញុំប៉ុណ្ណោះ តែទោះបីយ៉ាងណា បើលោកអ្នកអានជាទីគោរព មិនធុញទ្រាន់នឹងអានសៀវភៅនេះទេនោះ សាច់រឿងក្នុងសៀវភៅនេះ នឹងបកស្រាយជូនរឹងរឹតតែច្បាស់លាស់ទៅទៀត ។

យើងខ្ញុំសង្ឃឹមថា លោកអ្នកអានជាទីគោរព ប្រាកដជានិងបានក្រេបឱជារសថ្មីមួយទៀត ដោយគាប់ចិត្តជាពុំខាន ។

ចំពោះផលតបស្នង ចំពោះយើងខ្ញុំវិញនោះ យើងខ្ញុំសូមតែត្រឹមទទួលការណែនាំខ្លះ ពីលោកអ្នកអានជាទីគោរពវិញ និងបានទទួលការរួចខ្លួន ពីត្រូវធ្វើជា ***ស៊ីប*** សំរាប់បាញ់ពីជនភាគខ្លះប៉ុណ្ណោះ ជាការគ្រប់គ្រាន់ ។


www.budinst.gov.kh www.elibraryofcambodia.org

យើងខ្ញុំសូមបញ្ចប់វាចានេះ ដោយពាក្យស្លោកថា <<***វិជ្ជាវិសេសរបស់មនុស្ស វិជ្ជាហីនយសស្មើគោខ្លៅ*** >>។

សូមទទួលនូវអភិនន្ទនាការដ៏ស្មោះពីយើងខ្ញុំ

ភ្នំពេញ ថ្ងៃទី ១៨ មីនា ១៩៧៣

*ស៊ា ប៊ុន ភេង*



www.budinst.gov.kh www.elibraryofcambodia.org

# បុព្វប្រយោគ

មានមនុស្សចំពូកខ្លះ ឬ ក៏ដោយច្រើន ក្នុងពិភពលោកយើងនេះ មានសេចក្តីខិលច្រអូសជាប្រក្រតី និងចូលចិត្តគិតដល់សម្បត្តិឆ្កួតលីលាប្រាថ្នាចង់បានកន្សែងបក់កន្សែងបោយ ដើម្បីកើបកាយយកភោគទ្រព្យបរមសុខ ឬឋានសួគ៌វិមានអ្វីសព្វគ្រប់ប្រការ តាមសេចក្តីត្រូវការតែមនុស្សទាំងនោះ ពុំដឹងទាល់តែសោះថា ក្នុងខ្លួនមនុស្សយើងគ្រប់រូបគ្រប់នាមធម្មជាតិបានសាងកន្សែងបក់កន្សែងបោយមួយទុកអោយស្រេចគ្រប់ៗគ្នាទាំងអស់ ។ តែកាលបើខ្លួនឯង បណ្តោយអោយវត្ថុវិសេសនេះជាប់កប់នៅក្នុងផែនដីទេៗ ពុំនាំយកមកបោកបក់ដុសលាងសំអិតសំអាងអោយល្អឡើង និងប្រើអោយបានជាប្រយោជន៍ពិតៗហើយ ក៏នៅតែជាវត្ថុកប់នៅជានិច្ចជាកាល ចំណែកមនុស្សដែលចេះយកមកធ្វើអោយមានខ្លឹមសារ ជាប្រយោជន៍ចំពោះខ្លួនបានហើយ នឹងប្រើវត្ថុវិសេសនោះកើបកោយយកអ្វីក៏បានប្រាថ្នាកន្សែងបក់កន្សែងបោយដែលពោលមកនេះ ក៏គឺ <<***ខួរក្បាល***>> របស់យើងនេះឯង ។

យើងបានឃើញគ្រឿងចក្រគ្រឿងយន្ត ធ្វើប្រយោជន៍ធ្វើដំណើរបានរាប់រយគីឡូម៉ែតក្នុងមួយថ្ងៃ អាកាសយានជួយអោយធ្វើដំណើរបានរាប់ពាន់គីឡូម៉ែតក្នុងមួយថ្ងៃ វិទ្យុទូរលេខ ធ្វើអោយបញ្ជូនដំណឹងឆ្លងកាត់ពិភពលោកបានក្នុងរយវេលាតែ ៣-៤ម៉ោង ទូរស័ព្ទធ្វើអោយសន្ទនាគ្នាបានរវាង


www.budinst.gov.kh www.elibraryofcambodia.org

មនុស្សដែលនៅឆ្ងាយពីដល់ទៅមួយទីបម្នាក់បាន ប្រដាប់បោះពុម្ពៗផ្សាយនូវសៀវភៅ សារពត៌មានក្នុងមួយថ្ងៃ រាប់ទាំងពាន់ៗក្បាល ធ្វើអោយផុយស្រឡះពីសម័យមុនៗ ដែលយើងត្រូវអង្គុយសរសេរចាររាប់ៗខែទំរាំតែបានមួយក្បាលៗ ក្នុងសតវត្សរ៍នេះទៀត យានអវកាស នាំមនុស្សទៅចុះដាន់លើពិភពព្រះចន្ទ ដែលមនុស្សខ្លួននៅមិនទាន់ទាំងជឿទៅទៀតផង ។ ល ។ និង ។ល ។ យើងកោតសរសើរគ្រឿងប្រតិដ្ឋ (Devices) ទាំងនេះថាជារបស់ប្លែកចំលែក អស្ចារ្យប្រដូចបាននឹងព្រះឥន្ទព្រះព្រហ្មប្រទានមកអោយយើង តែការពិតនៅនោះរបស់ទាំងនេះជាផល ដែលផុលផុសចេញពីខួរក្បាលមនុស្សពិតៗ សូម្បីតែរបស់ទាំងនេះធ្វើប្រយោជន៍បានយ៉ាងប្រសើរលើសលប់ហើយក៏នៅតែមិនផុតពីត្រូវប្រើខួរក្បាលមនុស្សគ្រប់គ្រងថែរក្សាប្រយ័ត្នរវាំងអោយប្រព្រឹត្តទៅបានដោយល្អទៀត សមត្ថភាពនៃខួរក្បាលរបស់មនុស្សមានច្រើនលើសលប់រហូតបើនឹងគណនា នរណាអាចនឹងប្រាប់បានថាតទៅមុខទៀតមនុស្សនិងសាងអ្វីងបានខ្លះទៀត ដែលជាប្រយោជន៍ដល់មនុស្សជាតិដូចគ្នា ។ ឯចំណែកខាងផ្លូវអាក្រក់វិញ ក៏មានច្រើនក្រៃលែង ។ ខ្លាសាហាវនៅមានមនុស្សខ្លាចតិចជាង មនុស្សដែលមានចិត្តពាលសាមាន្យ ពិភពលោករបស់យើង និងជាទីអោយសុខ ឬ អោយទុក្ខជាទីមនោរម្យ ឬ ក្រៀមក្រំទោមនស្សនោះ ដោយច្រើនមកតែពីមនុស្សផងគ្នាអំណោយអោយដូច្នោះពិភពលោកនេះជួនកាលក៏ជាសុខ ជួនកាលក៏នៅជាទុក្ខ និងជួនកាលក៏មិនសុខមិនទុក្ខ ដោយប្រការដូច្នេះនេះ ធ្វើអោយចាប់ចំណុចសំខាន់បានថា :


www.budinst.gov.kh www.elibraryofcambodia.org

*មនុស្សមាន ៣ ប្រភេទរបស់នៅលើពិភពលោកនេះ :*

**ប្រភេទទី១** សាងសេចក្ដីល្អ សុខសន្ដិភាពអោយដល់ខ្លួននិងពិភពលោក ។

**ប្រភេទទី២** បំផ្លិចបំផ្លាញសេចក្ដីល្អ សុខសន្ដិភាពរបស់ខ្លួន និង ពិភពលោក ។

**ប្រភេទទី៣** គឺអ្នកដែលមិនបានបំផ្លិចបំផ្លាញតែក៏ឥតបានសាងសេចក្ដីល្អ សុខសន្ដិភាពដល់ខ្លួន និងពិភពលោកដែរ ។

**មនុស្សប្រភេទទី១** រមែងបានទទួលផលល្អយ៉ាងណាមួយជាគ្រឿងតប ស្នង បើប្រសិនជាបានសាងសេចក្ដីល្អដ៏លើសលប់ ក៏នឹងបានឡើងកាន់ឋានៈ ដ៏ខ្ពង់ខ្ពស់បំផុតរហូតដលបាននាមថា <<**វិរៈបុរស** Hero>> ឬ <<**មហា បុរស** Great - men>>ដែលជាវត្ថុបំណងនៃសៀវភៅនេះ ។

នាមថា ***វិរៈបុរស - មហាបុរស*** នោះជាវត្ថុធាតុ ដែលមនុស្សយើង ភាគច្រើនប្រាថ្នាចង់បាន យើងនិយមសរសើរជន ដែលមានកេរ្ដិ៍ឈ្មោះក្នុង ពង្សាវតា ដែលបានធ្វើសេចក្ដីល្អប្រពៃទុកដោយច្រើន យើងរីករាយស្រស់ ស្រាយ កាលបានឃើញពិធីដែលរៀបចំឡើង ដើម្បីជាកិត្តិយសដល់ជនណា ម្នាក់ៗដែលបានធ្វើប្រយោជន៍ដល់ប្រជាជន យើងអន្ទះអន្ទែងចង់ឃើញចង់ ស្គាល់មុខជន ដែលបានធ្វើការណាមួយរហូតដល់មានកិត្តនាមល្បីល្បាញ លោកអ្នកដែលធ្លាប់បានទៅទស្សនានៅបរទេស កាលបានឃើញមនុស្ស


www.budinst.gov.kh www.elibraryofcambodia.org

វណ្ណដ្ឋាន ដែលរដ្ឋាភិបាលទាំងឡាយស្ថាបនាឡើងតាមវិធីនានា មានរូបអ្នកក្លាហាន ក្នុងកិច្ចការសង្គ្រាម អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ និងអ្នកនិពន្ធជាដើម ដែលសុទ្ធតែជា **វិរៈបុរស** ឬ **មហាបុរស** យើងរមែងមានការគាប់ចិត្តប្រាថ្នាអោយបានទទួលកិត្តិយសដូច្នោះខ្លះដែរ ។ ក្នុងប្រទេសបារាំង សេចក្តីប្រាថ្នាដ៏ធំរបស់គេ ក៏គឺអោយបានសាកសពរបស់គេត្រូវបានបញ្ចុះក្នុង ***អាឡាហាណដ្ឋាន បំង់តេអុង*** (Pan Théo.) ដែលជាទីបញ្ចុះសពនៃពួក <<***អមតជន*** Immortal >> បានសេចក្តីថា បើទុកជារាងកាយបាត់បង់ទៅហើយ ក៏កេរ្តិ៍ឈ្មោះនៅមានជាន់នៅក្នុងពង្សាវតារជានិរន្តរ៍ ។ ដូច្នេះទៅកាន់ផ្លូវដែលនឹងសាងខ្លួនឯងខ្ពង់ឡើង ។ តែថា ក្នុងលោកនោះមានមនុស្សជាច្រើនរយលានឯចំនួនអ្នកដែលពង្សាវតារព្រមត្រាទុកថាជា ***វិរៈបុរស*** ឬ ***មហាបុរស*** នោះយើងអាចរាប់អស់ ទាំងនេះព្រោះការសាងខ្លួនអោយបានជា ***វិរៈបុរស*** ឬ ***មហាបុរស*** នោះជាការលំបាកក្រៃលែងហ្នឹងឯង ។

ចុះ អ្វីហ្ន៎ ! ជាគ្រឿងជួយមនុស្សសាងខ្លួនអោយបានជាវិរៈបុរស ឬមហាបុរស ?

មានជនភាគច្រើន ភាន់ច្រឡំថា ចំណេះវិជ្ជាតែម្យ៉ាងប៉ុណ្ណោះ ជាគ្រឿងជួយឲ្យមនុស្សខ្ពស់ឡើងបាន និងអោយសំរេចផលគ្រប់យ៉ាងដែលត្រូវការ ។ អ្នកមានគំនិតរបៀបនេះ រមែងមិនសាងអ្វីដទៃទៀត ក្រៅពីការផ្ទុកយកចំណេះវិជ្ជាផ្សេងៗ ចូលទៅផ្ទុកក្នុងខួរក្បាល និងជឿជាក់ថាខ្លួនមានគ្រឿង ឧបករណ៍សំរាប់នាំទៅកាន់លាភយស និងឋានៈដ៏ខ្ពង់ខ្ពស់


www.budinst.gov.kh www.elibraryofcambodia.org

ហើយ ។ តែបើត្រឡប់ជាផ្ទុយស្រឡះទៅវិញ ពោលគឺ កាលបានឃើញមិត្រភក្តិមួយស្របាលគ្នា មានចំណេះវិជ្ជាទន់ទាបជាងខ្លួនត្រឡប់ជាមានឋានៈខ្ពង់ខ្ពស់ជាង បានរៀនសូត្រច្រើនជាង មានមនុស្សនិយមរាប់អានច្រើនជាងខ្លួន ដូច្នេះកុំធ្វើអោយងោងងងឹតងងល់លែងយល់ទាល់តែសោះថា មនុស្សយើងតើ និងត្រូវប្រតិបត្តិយ៉ាងណា ? ទើបអាចសាងខ្លួនអោយឡើងកាន់សេចក្តីចំរើនបាន ។ លើសទៅទៀត បើសិនជាខ្លួន ជាអ្នកប្រព្រឹត្តល្អត្រឹមត្រូវតាមសីលធម៌ទៀតផងនោះ ក៏អាចនិងធ្វើអោយផ្លាស់ការគិត វេទៅរកផ្លូវរបស់មនុស្សខូច អាចយល់ឃើញថាល័ទ្ធសាសនា សុភាវធម៌ សិលធម៌អ្វីៗនោះសុទ្ធតែជាគ្រឿងភរភូតបោកបញ្ឆោតទាំងអស់ ពាក្យប្រៀនប្រដៅដែលថាអោយមនុស្សប្រព្រឹត្តសុចរិតទៀងត្រង់នោះ សុទ្ធតែជាឧបករណ៍របស់មនុស្សខូច សំរាប់ឃោសនាអោយជនល្ងង់ខ្លៅស្លាប់ចិត្ត ហើយបំបិទភ្នែកបានយ៉ាងងាយស្រួលប៉ុណ្ណោះត្រឡប់ទៅជាជឿភាសិតឡាតាំងថា <<Homo Homini Lous មនុស្សជាឆ្កែចចក ចាំតែប្រទុសរាយមនុស្សដូចគ្នាប៉ុណ្ណោះ ឬក៏អាចចុះសំរុង តាមពាក្យរបស់ ប្រ៊ុយទុស (Brutus) អ្នកក្លាហានជាតិរ៉ូម៉ាំងថា

<<***ឱ! សុចរិតអើយ អ្នកគ្រាន់តែជាពាក្យពោលប៉ុណ្ណឹង***>> ។

ការពិត ចំណេះវិជ្ជា និងសុចរិត ជារបស់ដែលមនុស្សចាំបាច់ត្រូវតែមានជាដាច់ខាត ។ តែថា ត្រឹមតែពីរប្រការប៉ុណ្ណោះទេ នៅមិនទាន់គ្រប់គ្រាន់ល្មមសាងខ្លួនអោយឡើងកាន់ឋានៈខ្ពស់ខ្ពស់នៅឡើយទេ ។ ព្រោះថា ចំណេះវិជ្ជានោះ យើងត្រូវចេះប្រើក្នុងផ្លូវដែលសក្តិសម ។ រីឯសុចរិតនោះទៀត


www.budinst.gov.kh www.elibraryofcambodia.org

ក៏ត្រូវប្រើអោយត្រឹមត្រូវតាមកាលៈទេសៈដូចគ្នា ។ ពិតណាស់ មនុស្សយើង មិនគួរប្រព្រឹត្តទុច្ចរិត សុខចិត្តស្លាប់ល្អជាងធ្វើអំពើដ៏ពុំប្រពៃ ។ តែការប្រព្រឹត្ត សុចរិតនោះឯងត្រូវប្រយ័ត្នប្រយែងអោយណាស់ ប្រព្រឹត្តអោយ‌ជោគជ័យ ដោយពុំក្រឡេកមើលហេតុការណ៍ជុំវិញខ្លួនសោះទេ ក៏និងប្រទ្បប់ជាអោយ ទោសច្រើនជាងអោយគុណ ឧបមាថា ក្នុងសាធារណរដ្ឋខ្មែរនេះ មហាសេដ្ឋី ធំម្នាក់បរិច្ចាគទ្រព្យរាប់លានក្នុងមួយថ្ងៃ អោយដល់មនុស្សគ្រប់ៗគ្នាដែលទៅ សុំ យ៉ាងនេះៗ និងធ្វើអោយមនុស្សហៀបតែអស់ពីនគរ លះបង់វិជ្ជាជីវៈ ដែលធ្លាប់ធ្វើ ក្លាយខ្លួនទៅជាអ្នកសុំទានអស់ ។ កាលណាសុំបានមក ក៏ប្រជុំ គ្នាលេងល្បែងផ្សេងៗឥតគិតបង់ខាតប៉ុណ្ណាក៏ពុំស្តាយ ព្រោះទៅសុំបាន ទៀត ។ ការវិវាទទាស់ទែងបែកបាក់សាមគ្គី និងការបោកប្រាស់ជាអំពើទុច្ចរិត ផ្សេងៗ ក៏កើតមានឡើងជាលំដាប់មនុស្សទាំងនគរក៏នឹងទៅជាខ្ជិលច្រអូស ។ យើងដឹងហើយថា សេចក្តីខ្ជិលច្រអូសជាមូលហេតុនៃអកុសលទុច្ចរិតដទៃ ទៀតជាច្រើនប្រការ ដូចនេះ ទើបឃើញបានថា សេចក្តីល្អខ្លះៗក្នុងលោក នេះ ប្រសិនបើធ្វើទៅហើយ បែរជាបានអោយទោសទៅវិញ ។ មិនមែនថា អោយតែសុចរិតហើយ ធ្វើទៅចេះតែអោយគុណដរាបនោះទេ ។ ព្រោះ ហេតុនេះឯង ក្នុងព្រហ្មវិហារធម៌ទើបត្រូវមានឧបេក្ខា (Equanimity) ជា ប្រការទី៤ ។ យើងទើបឃើញបានថាការដំណើរជីវិតអោយរៀបរយក្នុង លោកនេះ នោះមិនមែនជាការងាយឡើយ ។


www.budinst.gov.kh www.elibraryofcambodia.org

កាលណាយើងសិក្សាប្រវត្តិរបស់ជន ដែលអាចសាងខ្លួនពីជាន់ទាបបំផុតឡើងទៅកាន់ជាន់ខ្ពស់បំផុត ហើយយកចរិយាវត្តរបស់ជនទាំងនោះមកញែកធាតុមើលអោយល្អិតល្អន់ហើយនឹងឃើញបានថាមនុស្សយើងនឹងសាងខ្លួនអោយបានល្អពិតៗនោះ ត្រូវមានគុណសម្បត្តិរហូតដល់ទៅ៤០ប្រការ ។ គួរអោយអនិច្ចាណាស់ ចំណេះវិជ្ជា និងសុចរិត ត្រឹមតែ២ក្នុង ៤០ប៉ុណ្ណោះ អ្នកដែលមានតែចំណេះវិជ្ជា និងសុចរិត ប្រសិនបើគ្មានប្រការដទៃៗទៀតទេនោះ រាប់ថានៅខ្វះដល់ទៅ៣៨ប្រការទៀត និងសាងខ្លួនអោយបានល្អពិតៗ បានយ៉ាងលំបាកក្រៃលែង ។

ការសិក្សាប្រវត្តិរបស់មនុស្សដែលល្បីល្បាញមកហើយ ក្នុងប្រវត្តិសាស្ត្រក្តី ឬមានការគយគន់ឃ្លាំមើលចរិយាវត្ត របស់លោកដែលមានឋានៈឧត្តុង្គឧត្តម ក្នុងបច្ចុប្បន្នសម័យនេះក្តី រមែងជាប្រយោជន៍របស់ខ្លួនយើងជាអនេកប្បការ ។ តែត្រូវចាំអោយច្បាស់ម្យ៉ាងថា ការមើលការប្រព្រឹត្តទៅរបស់មនុស្ស យើងត្រូវសំឡឹងមើលតែខាងល្អបានហើយ ។ មនុស្សគ្រប់រូបក្នុងលោកនេះ តែងមានអាក្រក់ និងល្អលាយឡំគ្នា ក្នុងខ្លួនជានិច្ច ។ បើយើងស្វែងរកមនុស្សដែលល្អគ្រប់យ៉ាង មិនពព្រុសពពាលមិនធ្លាប់ធ្វើអ្វីខុសសោះក៏គង់មិនងាយជាងរាវរកម្ជុលក្នុងមហាសមុទ្រដែរទេ ។ ដូច្នេះបើយើងសិក្សារកប្រយោជន៍ពិតៗ គួរតែសំឡឹងមើលតែផ្លូវដែលល្អដូចយ៉ាង ជួនកាលយើងបានឱកាសចូលទៅជិតលោកអ្នកមានបណ្តាស័ក្តិខ្ពស់ យើងគួរព្យាយាមពិគ្រោះក្នុងចិត្តថាលោកមាន <<ល្អ>> ដូចម្តេចខ្លះ មិនមែនសំឡឹងមើលថា


www.budinst.gov.kh www.elibraryofcambodia.org

លោកមាន <<អាក្រក់ទាស់ខុស>>អ្វីខ្លះនោះទេ ។ ធ្វើបានដូច្នេះនេះ និងបានជាប្រយោជន៍ដល់យើងជាច្រើន ព្រោះយើងអាចនាំយកគុណសម្បត្តិរបស់លោកមកជាឧទាហរណ៍សំរាប់ខ្លួនយើង ។ បើយើងសំឡឹងមើលតែខាងទាស់ខាងខុសតែម្យ៉ាងហើយ យើងមិនសំគាល់ឃើញខ្លួនរបស់យើងប្រសើរបំផុត ហើយពុំអាចមានឱកាសកែប្រែ សេចក្តីអាក្រក់របស់ខ្លួនយើងបានឡើយ ។ ព្រោះពុំបានដឹងថា ខ្លួនឯងអាក្រក់យ៉ាងណាខ្លះ និងពុំព្យាយាមសាងសេចក្តីល្អឡើងទៀតផង ព្រោះជឿថាខ្លួនល្អគ្រប់គ្រាន់ហើយ ។ សូមធ្វើការសង្កេតថា ជនដែលនិន្ទាឈ្នានិះអ្នកដទៃជាប្រក្រតី មិនដំកុំដំកើងសរសើរអ្នកណាថាល្អសោះឡើយនោះ ជនប្រភេទនោះជាអ្នកមានគុណសម្បត្តិក្នុងខ្លួនតិចបំផុត ។ ពាក្យរបស់លោក ជោន រ៉ាស្គិន (John Rukin)អ្នកនិពន្ធជាតិអង់គ្លេសថា <<***គប្បីសំឡឹងលក្ខណៈដែលល្អ និងមាំទាំ ដែលមាននៅក្នុងបុគ្គលគ្រប់ប្រភេទ ដែលចូលមកជិតអ្នក ចូរលើកដំកើងសរសើរ ត្រេកអររីករាយជាមួយ ហើយប្រសិនបើអ្នកអាចធ្វើបាន ចូរព្យាយាមយកតំរាប់តាម។ កាលបើយ៉ាងនេះ លក្ខណៈមិនល្អរបស់អ្នក នឹងរបេះរបូតចេញទៅពីអ្នក ដូចស្លឹកឈើស្ងួតរបេះធ្លាក់ទៅ កាលដល់ពេលវេលា***>> ។

នេះឯងគឺវត្ថុបំណង និងផលដែលគប្បីបានក្នុងការសិក្សា <<***សាងខ្លួនឯង***>> ។

✻ ✻ ✻ ✻ ✻


www.budinst.gov.kh www.elibraryofcambodia.org

# ផ្នែកទី ១



www.budinst.gov.kh www.elibraryofcambodia.org

# កាលិលេវ កាលិលេ

Galileo Galilée
1564 1642



<<Magister - Dixit ពាក្យបូរាណាចារ្យ >> នេះជាគ្រឿងអាកាត់ជម្រះការសង្ស័យ និងជំនឿគ្រប់យ៉ាង ទោះជាសមហេតផលក្ដី ពុំសមហេតុផលក្ដីតែកាលណាគ្រូប្រាប់ដោយពោលពាក្យឃ្លាខាងលើនេះ ត្រូវស្ដាប់ - ជឿ - គោរពតាមជាដាច់ខាត និងបំពារដោយគ្រាន់តែនៅតែសង្ស័យ ក៏ពុំបានដែរ វិធីសិក្សារបស់ជនជាតិអឺរ៉ុបក្នុងសម័យ៥០០ឆ្នាំកន្លងផុតមកហើយនោះ ចូលក្នុងន័យខាងលើនេះឯង ។

***កាលិលេ*** កើតនៅថ្ងៃទី ១៨កម្ភៈ ១៥៦៤ ឪពុកជាគ្រូភ្លេងនៅក្រុងពីស (PISE)ប្រទេស ***អ៊ីតាលី*** ។

***កាលិលេ*** កាលនៅជាកុមារជាមនុស្សភ័យខ្លាចច្រើន មានសន្ធូរផ្គរលាន់ផ្អើលបន្ទោរជាដើម ដល់ពេញវ័យបរិបូរណ៍ឡើង ក៏ក្លាយទៅជាមនុស្ស ផ្ញើប្រយោជន៍ដ៏ធំដល់មនុស្សលោក គឺគ្រាន់តែឃើញ ***ចង្កៀងយោលយោក*** ជា



www.budinst.gov.kh www.elibraryofcambodia.org

ហេតុ ក៏អាចរកវិធីកំណត់នូវ ***ចន្ទ្រគ្រាស សូរ្យគ្រាស*** បាន ហើយក្នុងការទៅរស់នៅឯក្រុងវេនីស (Vénise) អាចរកឃើញនូវកំលាំងស្រូបទាញរបស់ផែនដី នាំអោយអាចធ្វើគ្រឿងវាស់បាន បន្ទាប់មកទៀត អាចធ្វើគ្រឿងចក្របូមទឹកបាន ធ្វើគ្រឿងវាស់កំដៅ និងត្រជាក់បាន (ឧណ្ហមាត្រ) ក្រោយមកទៀត ធ្វើបានសំរេចនូវ ***កែវទូរទស្សន៍*** (Téléscope) ដែលក្លាយទៅជាឧបករណ៍ខាងតារាសាស្ត្រ រហូតដល់បច្ចុប្បន្ននេះ មិនតែប៉ុណ្ណោះទ្រឹស្តីផែនដីវិលក៏កើតឡើងយ៉ាងជាក់ប្រាកដពីត្រឹមនោះមកដែរ ជាហេតុអាចអោយគេសាង នាឡិកា ប្រើបានរហូតដល់សម័យនេះ ។

មិនមែន ***កាលិលេ*** អាចធ្វើនូវកិច្ចការដ៏មហាថ្លៃទាំងនោះបានដោយគ្មានឧបសគ្គនោះទេ គាត់ធ្វើការពិសោធន៍ បំពានបំពារលើ (Magoster Dixit ពាក្យបូរាណាចារ្យពោល) ដែលមានកំហុសស្មើនិងការប្រឆាំងចំពោះព្រះជាម្ចាស់(God)ដែរ គាត់ក៏ត្រូវខ្វាត់ខ្វាតចេញពីមាតុភូមិ ទៅរស់នៅឯ ***វេនីស*** ទើបគាត់ផុតពីគ្រោះថ្នាក់បានមួយគ្រា ហើយអាចធ្វើអោយសំរេចនូវកិច្ចការដូចមានពីខាងលើស្រាប់ ។ ព្រោះនៅ ***វេនីស*** នេះ គាត់មានសេរីភាពពេញបរិបូណ៌លើពាក្យបូរាណាចារ្យ ដែលកាលគាត់រស់នៅឯ ***ពីស*** ជាមាតុភូមិរបស់គាត់ តែងតែបានទទួល និងជាដំបងប្រហារគាត់ តែគាត់ក៏នៅតែរត់ពុំផុតពីការស្រឡាញ់មាតុភូមិ នាំអោយគាត់ត្រឡប់មក ***ពីស*** វិញ មាតុភូមិពុំស្រឡាញ់គាត់ ធ្វើអោយគាត់ត្រូវសាលកាត់ទោសពិសេសរបស់អ្នកបួស (តាមលទ្ធិគ្រិស្ត) ដែលប្រវត្តិសាស្ត្រហៅថា << ***អាំងគវីស៊ីស្យុង*** Inquisition >>


www.budinst.gov.kh www.elibraryofcambodia.org

កោះហៅយកទៅហាមប្រាម គាត់ក៏ធ្វើជាយល់ព្រមតាមវា សុខចិត្តលះបង់គំនិតថា ផែនដីវិល នោះចោលព្រោះជាការប្រឆាំងនឹងព្រះជាម្ចាស់ នេះជាលើកទី១ នៅឆ្នាំ១៦១៦ ដែលត្រូវ ***សាល*** នោះកោះឡើង តែការយល់ព្រមនោះគ្រាន់តែដើម្បីរស់នៅធ្វើការតទៅទៀតប៉ុណ្ណោះ ព្រោះបើពុំយល់ព្រមថាកែប្រែទេ ***សាល*** Inquisition នេះ អាចនឹងកាត់ទោសប្រហារជីវិតក៏បាន ។ ***ដឹងការពិតហើយលាក់ទុកពុំបាន*** ក្រោយមកតម្រាតារាសាស្ត្រមួយបានត្រូវផ្សាយចេញ ក៏ទាក់ទងពីរឿងផែនដីវិលទៀត ទោះបីកំពុងឈឺក៏ដោយ ត្រូវតែចូលទៅកាន់ ***សាល*** ខានពុំបាននា***ក្រុងរោម*** នៅថ្ងៃទី ២២ មិថុនា ១៦៣៣ ***កាលិលេ*** អាយុ ៦៩ ឆ្នាំ សាលជំនុំជំរះអស់រយៈកាល ៦ ខែ គាត់ត្រូវសន្យាជាលាយលក្ខណ៍អក្សរប្រកាសថា លះបង់ការយល់ថាផែនដីវិលនោះម្តងទៀតក្នុងព្រះបរមនាមដ៏សក្តិសិទ្ធនៃ ***ព្រះយេស៊ូគ្រិស្ត*** តែការនៅតែប្រព្រឹត្តល្មើសរហូតដល់ទៅពីរលើកយ៉ាងនេះ គាត់ពុំអាចនៅជាអ្នកជាបានឡើយ ត្រូវសាលអ្នកបួសកាត់ទោស ដាក់គុកដោយឥតមានកំណត់ ។ មួយរំពេចប៉ុណ្ណោះ ត្រូវជាប់គុកក៏ពិត តែគ្រាន់តែគេសែងចេញពីទីជំនុំជំរះ គាត់ក៏ខ្សឹបប្រាប់គេឯងភ្លាមថា << ***ការពិតផែនដីវិល*** >> ។

នៅក្នុងគុក ៤ ឆ្នាំ គាត់នៅតែមានឱកាសផ្សាយចេញដោយលួចលាក់នូវទ្រឹស្តីរបស់គាត់ជានិច្ច ទីបំផុតគាត់ក៏ខ្វាក់ភ្នែកទាំងសង្ខាង ទើបបានចេញទៅរស់នៅក្រៅគុកបានតែ ៥ ឆ្នាំ ទៀតប៉ុណ្ណោះ អាយុ ៧៨ ឆ្នាំ ក៏ទទួលមរណភាពនៅថ្ងៃទី ៨ មករា ១៦៤២ ។


www.budinst.gov.kh www.elibraryofcambodia.org

# រីហ្សីលីយ៉ឺ

Riche Lieu
1585 1649



***រីហ្សីលីយ៉ឺ*** ជាអ្នកបួសគ្រិស្ត កិច្ចការដែលគាត់ធ្វើទាំងអស់ សំរេចដោយការគិត ច្រើនជាងការប្រើអាវុធ ។

កើតនៅថ្ងៃទី ៩ កញ្ញា ១៥៨៥ ជាបារាំងសែស ឪពុក ជា ***នាយទាហាន*** មាតា ជាបុត្រី ***មេធាវី*** ។ កាលនៅជាកុមារ ជាមនុស្សសំបុករោគ ហៀបតែនឹងស្លាប់ពីតូចទៅហើយ ដល់ធំឡើងដំបូងចូលរៀនវិជ្ជាទាហាន ក្រោយមកបានទៅបួសតាមគោលបំណងរបស់ម្ដាយ រហូតដល់បានឋានៈជា ***អេវេគ*** (éveque) ប្រចាំនៅក្រុង***លុយសុង*** (Luçon) ។

អ្នករៀនប្រវត្តិសាស្ត្រតែងបានដឹងហើយថា នៅអឺរ៉ុបនោះកិច្ចការផែនដី និងសាសនា តែងមានការទាក់ទងគ្នាបំផុត ជួនកាលខាងសាសនាចក្រមានអំណាចលើសពីអាណាចក្រក៏មាន ដូចយ៉ាង pape ***ប៉ាប*** មានអំណាចបង្គាប់អោយប្រទេសមួយ ទៅធ្វើសង្គ្រាមនិងប្រទេសមួយទៀតក៏មាន ឬគាប់



www.budinst.gov.kh www.elibraryofcambodia.org

ជូនជាប្រទេសណាមួយត្រូវ ***ចាប់*** កាត់ទោសហើយ ត្រូវប្រទេសដទៃចោម រោមគ្នាវាយក៏មាន ហេតុនេះ ទើបក្នុងប្រទេសបារាំង ត្រូវមានអ្នកតំណាង របស់អ្នកបួសចូលក្នុង ***រដ្ឋសភា*** ផង ***រីហ្សីលីយ៉ឺ*** ជាអ្នកវាងវៃជាងគេ ក្នុង បណ្តាអ្នកបួសទាំងអស់ ទើបត្រូវបានតែងតាំងជាតំណាងនៃសាសនាចក្រក្នុង រដ្ឋសភា បានចូលក្នុងរដ្ឋសភាហើយ គាត់ក៏បានសំដែងការវាងវៃរបស់គាត់ ធ្វើអោយប្រជាជនជ្រះថ្លាកើនឡើងជាលំដាប់រហូតទាល់តែ ***ព្រះមហារាជិនី*** សព្វព្រះរាជហឫទ័យទ្រង់ជ្រើស ជាអ្នកថ្វាយសីល ក្នុងព្រះបរមរាជវាំង ជា ហេតុអោយ ***រីហ្សីលីយ៉ឺ*** មានការប្រាស្រ័យទាក់ទងនិងវីរជនជាច្រើន និង ទទួលបានការប្រោសប្រាណព្រះមហារាជនីទ្វេឡើងជាលំដាប់ទាល់តែក្នុង អាយុ ៣១ ឆ្នាំបានទទួលតំណែងជា ***រដ្ឋមន្ត្រីមហាផ្ទៃ*** ។ លុះស្តេច ***ហង់រីទី*** ៤ (Henri IV) ចូលទិវង្គតទៅ ***ល្វីស៍ទី*** ១៣ (Loui XIII) ទទួលរាជសម្បត្តិក្នុង ព្រះជន្មាយុ ៩ ព្រះវស្សា ***ព្រះមហារាជិនី*** ទ្រង់កាន់កាប់ការផែនដី ក៏ឃើញតែ ***រីហ្សីលីយ៉ឺ*** ទើបប្រគល់តំណែងជា ***នាយករដ្ឋមន្ត្រី*** ក្នុងអាយុ ៣៨ ឆ្នាំ គាត់រត់ នៅក្នុងមុខតំណែង ១៩ ឆ្នាំ ក៏អស់អាយុ ក្នុងកាលអាយុ៥៧ ឆ្នាំ ។

កិច្ចការជាប្រយោជន៍ដល់ប្រទេសបារាំង ***រីហ្សីលីយ៉ឺ*** បានស្ថាបនា ***កង នាវាបារាំងសែស*** ដែលអាចប្រៀបផ្ទឹមបាន និង ***កងរាជនាវីអង់គ្លេស*** នា សម័យនោះ បានរួបរួមច្បាប់និងកែប្រែអោយល្អឡើង ក្នុងសម័យនោះ ឈ្មោះ ( Code Michau ) បានរកផែនដីអាណានិគមអោយដល់ប្រទេសបារាំង ៥ កន្លែង រួមទាំងប្រទេស ***កាណាដា*** ផង (ដែលក្រោយមកធ្លាក់ទៅជារបស់



www.budinst.gov.kh www.elibraryofcambodia.org

***ចក្រភពអង់គ្លេស*** ) បានស្លាបនាវិជ្ជាស្ថានសរ័កបោន (Srbonne) ដែលជាស្ថានសិក្សាដ៏សំខាន់មួយដល់សម័យនេះបង្កើតអោយមាន ***បណ្ណាល័យជាតិ*** (L'Académie Française) ដែលជាសភាប្រជុំអ្នកប្រាជ្ញ ៤០នាក់ សុទ្ធតែជាអ្នកធ្លាប់មានឈ្មោះល្បីមកហើយ ជាទីនិយមកោតសរសើររបស់ប្រជាជនក្នុងផ្នែកវិជ្ជាណាមួយ ទើបអាចជ្រើសចូលជាសមាជិកក្នុងសភាពនេះបាន ហើយក្នុងបណ្តាខ្មោចនៃសមាជិកទាំងនេះ សុទ្ធតែត្រូវបញ្ចុះនា ***អាឡាហាណដ្ឋានអមតជន*** ទាំងអស់ សភានេះជាសភាសំខាន់បំផុត របស់ប្រទេសបារាំងរហូតដល់សម័យនេះ ។

***ខាងផ្នែកនីតិប្រតិបត្តិ វិហ្សឺលីយ៉ឺ*** ជាអ្នកគោរពគោលការណ៍យុត្តិធម៌មធ្យ័តបំផុត ជនណាទោះមានឋានៈជាអ្វីក៏ដោយ ទោសដល់ដាក់គុក ត្រូវតែដាក់គុក ទោសដល់ប្រហារត្រូវតែប្រហារ ឥតមានយល់មុខជនណាម្នាក់ៗឡើយ ។ ក្នុងសម័យនយោបាយក៏មានការដាច់ខាត នៅក្នុងខ្លួនទៀត ។ ជនណាជំទាស់ពុំបានជាដាច់ខាតសម្បីព្រះរាជិនី ដែលដល់ពេលក្រោយមកជំទាស់នឹងកិច្ចការរបស់គាត់ ក៏ត្រូវយាងស្តេចអោយទៅគង់នៅប្រទេស ***ប្រ៊ុចែល*** (Bruxelles) ដែរ ហេតុនេះ ការបៀតបៀនឈ្នានីស ពីវរៈជនជាច្រើនក្នុងសម័យនោះ បើទុកជា ***វិហ្សឺលីយ៉ឺ*** ធ្វើប្រយោជន៍បានពិតៗយ៉ាងណា ក៏គាត់ពុំអាចជៀសផុតបានឡើយ រហូតដល់ពេលមួយ គាត់ដាក់ពាក្យសុំលាលែងពីមុខតំណែង តែស្តេច ***លូវីស៍ទី១៣*** ឈ្វេងយល់ថានិងរកវរជនណាអោយល្អក្រៃលែងទៅទៀតពុំបាន ទ្រង់ក៏ពុំយកព្រះទ័យទុកដាក់ចំពោះ


www.budinst.gov.kh www.elibraryofcambodia.org

ពាក្យពិតទូលរបស់អ្នកណាទាំងអស់ ហើយថែមទាំងពុំទ្រង់អោយ ***វីហ្សឺលីយ៉ឺ*** ចុះពីតំណែងផង ទ្រង់ព្រះរាជទានការធានាគាំទ្រគ្រប់បែបយ៉ាងចំពោះ ***វីហ្សឺលីយ៉ឺ*** រហូតដល់ទីបំផុត ក្នុងការប្រកួតរវាងសត្រូវរបស់ ***វីហ្សឺលីយ៉ឺ*** ព្រះរាជពរដ៏ថ្លៃថ្លានេះ គឺទ្រង់រក្សាស្មោះពិតឥតប្រែប្រួល សូម្បីតែព្រះរាជវល្លភៈ ឈ្មោះ ***សែងមាស់*** (Cing - Mars) ដែលព្រះអង្គទ្រង់ប្រោសប្រាណស្មើនឹងព្រះរាជបុត្រហើយនោះ ក៏ព្រះអង្គយល់ព្រមអោយ ***វីហ្សឺលីយ៉ឺ*** កាត់ទោសប្រហារជីវិតដែរ ដែលជារឿងភ្លូកភ្លឹកភ្ញាក់ផ្អើល បំផុតនៅពេលនោះ និងក្នុងពង្សាវតារបារាំង ។

អ្នកពង្សាវតារបារាំងសែស បានកត់ត្រាទុកថា (១) ***វីហ្សឺលីយ៉ឺ ហាក់ដូចជាគ្រាន់តែកើតឡើងហើយ ក៏ចេះស្រឡាញ់ប្រទេសជាតិ និងមហាក្សត្រតែម្តង*** (២) ***វីហ្សឺលីយ៉ឺ បានទទួលគ្រប់គ្រងប្រទេស ក្នុងកាលដែលប្រទេសជុនជាបទន់ខ្សោយបែកបក្សពួក ដល់មរណភាព លះបង់ចោលប្រទេសនេះក៏កាលមានកំឡាំងមាំទាំ ជាទីកោតក្រែងដល់ប្រទេសជិតខាងរួបរួមប្រទេសបារាំងបានមូលមិត្រជាធ្លុងមួយ>>*** ។

❊ ❊ ❊ ❊ ❊


www.budinst.gov.kh www.elibraryofcambodia.org

# ណាប៉ូឡេអុង បូណាប៉ារត៍

## Napoleon - Bonaparte

## 1769 1821



**ណាប៉ូឡេអុង** កើតនៅថ្ងៃទី ១៥ សីហា ១៧៦៩ ក្នុងត្រកូលជនជាតិ **អ៊ីតាលី** ដ៏ក្រីក្រ មានកូនច្រើន (សូមចាំអោយច្បាស់ថា **ណាប៉ូឡេអុង** មិនមែនឈាម**បារាំង**ទេ) ។ ការបានជា **អធិរាជ** ប្រទេស**បារាំង** នេះ អស្ចារ្យណាស់ដោយបានទទួលការអនុគ្រោះពីថៅហ្វាយរដ្ឋដែលខ្លួនកើតអាយុ ១១ឆ្នាំ បានចូលរៀនក្នុងសាលាយោធា ដល់អាយុ១៧ឆ្នាំ បានឋានន្តរសក្តិជា **អនុសេនីត្រី** នៅរវាងនេះឯងដែល **ណាប៉ូឡេអុង** បានដំណើរជីវិតយ៉ាងលំបាកតោកយ៉ាកបំផុត ។ អាយុ ២៥ឆ្នាំ បានជា **អនុសេនីឯក** ធ្វើការបានល្បីឈ្មោះជាដំបូងនៅក្រុង **ទូឡុង** (Toulon ) តែក៏ឥតបានទទួលផលតបស្នងអោយបានសក្តិសមដែរ ។ គាត់ហៀបតែនឹងចេញទៅទទួលមុខងារឯប្រទេស **ទួរគី** (Turquie )ទៅហើយ ។ តែថៃដន្យគាត់ត្រូវបានជ្រើសអោយជាអ្នកបង្ក្រាបប្រជាជនដែលប្រឆាំងនិងរដ្ឋការថ្មី ហើយគាត់ក៏ធ្វើទៅបានសំរេចយ៉ាងប្រសើរ ជាហេតុ



www.budinst.gov.kh www.elibraryofcambodia.org

អោយគាត់បានទទួលឋានៈគ្រាន់បើឡើង ។ គាត់រៀបការនិងស្ត្រីមេម៉ាយម្នាក់ឈ្មោះ ***ហ្សូសែហ្វីន***(Josephine) ដែលជាអ្នកមានការស្និទ្ធស្នាល និងវីរជនជាច្រើន ជាហេតុអោយ ***ណាប៉ូឡេអុង*** បានឋានៈខ្ពង់ខ្ពស់ឡើងជាលំដាប់ ។ ក្រោយពីរៀបការហើយ គាត់ទៅធ្វើសង្គ្រាមប្រទេស ***អ៊ីតាលី*** ធ្វើការបានជ័យជំនះជានិច្ចមក អាយុ ២៨ ឆ្នាំបានជា***ឧត្តមសេនី*** និងទៅធ្វើសង្គ្រាមនៅប្រទេស ***អេហ្ស៊ីប្ត*** បានជ័យជំនះដ៏ធំ ជាហេតុអោយបានទទួលការគោរពរាប់អានពីប្រជាជនទូទៅក្នុងប្រទេស ***បារាំង*** ។

ក្នុងរយៈកាលធ្វើសង្គ្រាមនៅប្រទេស ***អេហ្ស៊ីប្ត*** នេះ ***ណាប៉ូឡេអុង*** បានដឹងច្បាស់ថា រដ្ឋាភិបាលមានអំណាចទន់ខ្សោយហើយទើបគាត់ត្រឡប់មកកាន់ក្រុង ***ប៉ារីស*** ដោយសារជ័យជំនះរបស់ខ្លួន ទើបប្រជាជនគោរពរាប់អានច្រើន រហូតដល់បានជាប្រមុខរដ្ឋាភិបាលថ្មី (ភាសាបារាំងនៅសម័យនោះហៅថា ***កុងស៊ុល*** Consul) សាងប្រយោជន៍សំខាន់ៗអោយដល់ជាតិបារាំងសែសជាច្រើន ។ អាយុ ៣៦ ឆ្នាំ ក៏ប្រកាសតាំងខ្លួនជា ***អធិរាជ*** នៃប្រទេស ***បារាំង*** ។ ពង្សាវតារ ***ណាប៉ូឡេអុង*** បន្តពីនេះទៅពេញពោរទៅដោយការបង្ហូរឈាម តែពុំមែនជាគោលបំណងក្នុងទីនេះ ទើបពុំបាច់ពោលពីជ័យជំនះរបស់គាត់ឡើយ ។ ***ណាប៉ូឡេអុង*** បានឧទាហរណ៍មួយ ដ៏ខ្ពស់បំផុតរបស់មនុស្សដែលមានភាពរឹងប៉ឹងអត់ធន់ ។ កាលបើបានធ្វើគំរោងការណ៍អ្វីមួយហើយ តែងតែយកជីវិតទៅប្តូរដើម្បីសំរេចអោយបាននូវគំរោងការណ៍នោះ ។ ការដែលគាត់អាចសាងខ្លួនឡើងទៅដល់ឋានៈខ្ពស់បំផុត ដែល



www.budinst.gov.kh www.elibraryofcambodia.org

មនុស្សអាចនឹងឡើងទៅបានយ៉ាងនោះក៏ព្រោះលក្ខណៈដែលរឹងប៉ឹងជា ប្រធាន ។ ***ណាប៉ូឡេអុង*** បានទទួលការសរសើរថា ជាមេទ័ពដ៏មានថ្វីដៃបំផុតក្នុងលោក ។ តែក៏បានទទួលពាក្យរិះគន់ថាជាអ្នកប្រាថ្នា ធ្វើជាម្ចាស់លើ ***អឺរ៉ុប*** លើកគ្នាចោមវាយ ***ណាប៉ូឡេអុង*** ។ ***ណាប៉ូឡេអុង*** បាក់ទ័ពជាដំបូងនៅប្រទេស ***រុស្ស៊ី*** ហើយតមក ក៏មានតែការទទួលបរាជ័យ ទាល់តែសត្រូវហៀបចូលដល់ក្រុង ***ប៉ារី*** តែដល់រៀបនឹងចូលដល់ ក៏បានដឹងថា រដ្ឋសភាបានក្រាសតាំងរដ្ឋាភិបាលថ្មីរួចទៅហើយ ទើបត្រឡប់ទៅកាន់***ហ្វុងតែនប្លូ*** (Fontainbleau) ចម្ងាយពីប៉ារីស ៦០គ.ម ***ទ្រង់លាចាករាជសម្បត្តិ*** ។ ឯខាងក្រុង ***ប៉ារីស*** ក៏តាំងស្ដេច ***ល្វីស៍ទី ១៨*** (Loui XVIII) ដែលជាវង្សក្សត្រចាស់របស់ប្រទេស***បារាំង*** ឡើងជាម្ចាស់ផែនដី ។

***ណាប៉ូឡេអុង*** លាចាករាជសម្បត្តិហើយ ក៏សត្រូវរបស់ព្រះអង្គនៅតែពុំទុកចិត្ត ទើបបង្គាប់អោយរដ្ឋាភិបាល ***បារាំងសែស*** យក ***ណាប៉ូឡេអុង*** ទៅបំបរបង់កោះទៀត ***ណាប៉ូឡេអុង*** ប្រាថ្នានឹងផ្ដាច់បង់ជីវិតព្រះអង្គឯង តែមានគេឃាត់គាត់ទាន់ ក៏ត្រូវនាំទៅចោលឯកោះ ***អេលប៍*** ( Elbe )នៅថ្ងៃ ១២ មេសា ១៨១៣ ។

សូម្បីនាំយកទៅចោលឯកោះហើយ ***ណាប៉ូឡេអុង*** ក៏ពុំអស់ពិសនៅទីនោះពុំដល់មួយឆ្នាំផង ក៏លបចុះទូកគេចវាងនាវាចំបាំង ***អង់គ្លេស*** ដែលយាមល្បាត មកកាន់ទីគោកបានទៀត ។ ***ល្វីស៍ទី ១៨*** ទ្រង់ជ្រាប ក៏បញ្ជូនកងទ័ពទៅចាប់ ។ តែកាលកងទ័ពទៅជួប ***ណាប៉ូឡេអុង*** ហើយពុំចាប់


www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ត្រឡប់ជាចុះចូលនឹង ***ណាប៉ូឡេអុង*** ទាំងអស់ទៅវិញ ។ ***ណាប៉ូឡេអុង*** ទើបបានកំឡាំងទ័ពលើកចូលមកកាន់ក្រុង ***ប៉ារីស*** ។ ព្រះបាទ ***លូវីស៍ទី ១៨*** ក៏ស្ដេចទ្រង់គៀសខ្លួនទៅកាន់ប្រទេស ***បែលហ្ស៊ិក***ព្រោះទ្រង់ជ្រាបថា នឹងនៅតទល់ជាមួយ ***ណាប៉ូឡេអុង*** ពុំបានឡើយ ។ ការដែល ***ណាប៉ូឡេអុង*** ត្រឡប់មកគ្រានេះ គ្រប់ប្រទេសក្នុងអឺរ៉ុប ចាត់ទុកថាជា ***ការប្រកាសសង្គ្រាម*** ទើបនាំគ្នាចោមវាយ ***ណាប៉ូឡេអុង*** ។ ចំណែក ***ណាប៉ូឡេអុង*** ក៏តស៊ូដោយយល់ថា ជាទីបំផុតនៃជីវិត ។ ទីបំផុត ក៏ត្រូវទ័ពបច្ចាមិត្រចាប់កណ្ដាលសង្គ្រាម និងត្រូវបញ្ជូនទៅកាន់កោះ ***សាំងអេលេន***(St. Hélène) នៅទីនេះបាន៦ឆ្នាំ ក៏អស់ព្រះជន្មក្នុងជន្មាយុ ៥២ឆ្នាំ ។

សេចក្ដីបញ្ចប់ ***ណាប៉ូឡេអុង*** នៅរួមនឹង ***ហ្សូសែហ្វីន*** ពុំមានបុត្រ ក៏ទ្រង់លែងលះពី***ហ្សូសែហ្វីន*** ហើយទ្រង់សមរបនឹងម្ចាស់ក្សត្រីជាតិ ***អូទ្រីស*** ទៅវិញ ។

***ណាប៉ូឡេអុង*** ទ្រង់កាន់ព្រះអង្គថាជាស្ដេចចក្រពត្តិ ក៏គួរណាស់ព្រះអំនាចរាជបារមីរបស់ព្រះអង្គ ផ្សាយទៅសឹងគ្រប់ទៅលើទ្វីប ***អឺរ៉ុប*** ទាំងមូល ហើយព្រះអង្គទ្រង់ទីនាំងសេះសជានិច្ច ត្រឹមត្រូវតាមក្បួនព្រាហ្មណ៍និយមទៀត ។

សូម្បីទ្រង់មានអំណាចវាសនាយ៉ាងណាក៏ដោយ ក៏មានរឿងគួរអោយប្លែក ដែលរំលងពុំពោលមិនបាន គឺទ្រង់អភ័ព្វខាងក្នុងគ្រួសារ បងប្អូនពុំនៅក្រោមឱវាទ មហេសីពុំកោតក្រែង ផ្ទុយទៅវិញ ***ណាប៉ូឡេអុង*** ត្រូវខ្លាច


www.budinst.gov.kh www.elibraryofcambodia.org

ក្រែងជនទាំងនោះទៅវិញ ។ ប្រែថា អំណាចរបស់ ***ណាប៉ូឡេអុង*** ខាងកិច្ចការផែនដី និងខាងគ្រួសារ ខុសគ្នាមេឃនឹងដី មានរឿងតំណាលថា មហេសីទ្រង់ប្រោសចិញ្ចឹមឆ្កែ ព្រះអង្គពុំទ្រង់ប្រោស ដែលពុំអាចទ្រង់ពោលដូចម្តេចបានឡើយ ។ ពេលមួយនោះឆ្កែបាត់ ទ្រង់សប្បាយព្រះទ័យថានឹងផុតទុក្ខ ហើយទ្រង់ហាមដាច់ខាត ពុំអោយអ្នកណានាំឆ្កែថ្មីមួយចូលវាំងទៀត ។ តែបានប៉ុន្មានផង ស្រាប់តែមហេសី បានឆ្កែថ្មីមួយមកទៀតជាការល្មើសនឹងព្រះរាជនិយម តែក៏មិនប្រាកដថាទ្រង់មានព្រះឱង្ការយ៉ាងណាឡើយ ។

***អាធួរលេវីស៍*** (Arthur Lévis) បាននិយាយឡកទុកក្នុងសៀវភៅរបស់គាត់ថា

<<***ព្រះមហាចក្រពត្តិ ព្រះអង្គមានព្រះតេជានុភាពបង្ក្រាបអឺរ៉ុបអស់មួយទ្វីប តែក្នុងរាជវាំងព្រះអង្គនោះ សូម្បីតែទ្រង់ដេញឆ្កែតែមួយចេញក៏ទ្រង់ពុំបាន***>> ។

❊ ❊ ❊ ❊ ❊



www.budinst.gov.kh www.elibraryofcambodia.org

# ស៊ីម៉ុង បូលីវ៉ារ

## SIMON BOLIVAR

## 1783 - 1830



សម័យកាលជាង ២០០ឆ្នាំកន្លងទៅហើយ អំពើ ***ពុករលួយ*** (Corruption) បានកើតឡើងក្នុងវង់ ***សក្តិជន*** ជាតិ ***អេស្ប៉ាញ៉ុល*** ការរឹបជាន់ជញ្ជក់ឈាមរាស្ត្រធ្វើស្រែលើខ្នងរាស្ត្ររហូតដល់ព្រះរាជាក៏រឹតត្បិតពី លើសក្តិជនអ្នករាជការរបស់ព្រះអង្គដែរ ។ អំពើពុករលួយនេះឯងជាដង្កូវដួង ស៊ីពន្លុំនូវបង្គោលអំណាច ***មហាចក្រពត្តិ*** នៃប្រទេស ***អេស្ប៉ាញ*** អោយរលំរលាយហៀបតែនឹងអស់ទៅពីពិភពលោកនេះ ។

បណ្តាលអំពើទារុណ ជិះជាន់ជិះសាហាវផ្សេងៗ ដែលធ្លាក់លើជនជាតិនៃរដ្ឋតូចៗលើ ***ទ្វីបអាមេរិចខាងត្បូង*** ដែលកំពុងងើបឡើងទាមទារសេរីភាពឥស្សរភាព រដ្ឋធានី ***ការាកាស់*** (Caracas) នៃរដ្ឋ ***វេនេស៊ុយអេឡា*** (Vénézuela) ជាដែនដីអាណានិគមរបស់ ***អេស្ប៉ាញ*** ថ្ងៃ២៤កក្កដា ១៧៨៣ បានអោយកំណើតឡើងនូវវរៈបុរសម្នាក់ ឈ្មោះ ***ស៊ីម៉ុង បូលីវ៉ារ*** ក្នុងត្រកូលកុដុម្ពីក៍ ។



www.budinst.gov.kh www.elibraryofcambodia.org

អាយុ ៣ ខួប ឪពុកស្លាប់ចោលទៅ មាតាយកទៅអោយសិក្សាជាមួយ ចៅក្រមមួយរូប លុះអាយុបាន ៩ ខួប មាតាក៏ស្លាប់ចោលទៅទៀត ទុកបន្សល់កេរ្តិ៍មត៌កជាច្រើនអោយដល់ ***ស៊ីម៉ុង*** ។ ***ស៊ីម៉ុង*** ពុំសូវយកចិត្តទុកដាក់នឹងទ្រព្យសម្បត្តិទាំងនោះទេ និស្ស័យជាអ្នកចូលចិត្តការផ្សាញភ័យ (Adanture) សេពគប់តែនឹងកុមារដែលប្រដាល់ប្រតប់ច្រើន ក្រោយមកបានជួបនឹង ***ទស្សនវិទូ អចេលក៍*** ជាអ្នកពនេចរម្នាក់ឈ្មោះ ***រ៉ោរិកាស*** (Roricas) គ្រូនេះបានប្រដៅទ្រឹស្តីមួយដល់ ***ស៊ីម៉ុង*** ថា :

<<រាង***កាយជាវត្ថុសក្តិសិទ្ធិ ដួងចិត្តជាវត្ថុល្ងង់ខ្លៅ*** >> ។ ***ស៊ីម៉ុង*** បានយកចិត្តទុកដាក់ណាស់ ចំពោះទ្រឹស្តីនេះ ហើយគ្រូនោះដ៏ដឹកនាំហ្វឹកហាត់អោយ ***ស៊ីម៉ុង*** ផ្តល់ផ្គង់តែរាងកាយដោយវិធីផ្សេងៗ មានហាត់ចំបាប់ កាប់ដាវគុនដំបង និងដេកលើទីមិនស្អាត ដើរផ្លូវឆ្ងាយដោយជើងទទេ ។ ក្រោយមកក៏បែកបាត់មុខគ្នាមួងជាយូរ ស្រាប់តែបានជួបគ្នាជាថ្មីទៀតនៅ បារីស ។ គ្រូនេះបាននាំដើរកាត់ភ្នំ អាលព៍្ស(Alps) ទៅកាន់ប្រទេស ***អ៊ីតាលី*** ទៅក្រុង ***មីលង់*** (Milan) ក្រុង ***វេនីស៍*** (Vénise)ក្រុង ***ណាប្ល៍*** (Naples) ***រ៉ោម*** ចូលគាល់ ***ស្តេចប៉ាប*** (Pape) <<***ខ្ញុំព្រះករុណាគោរពស្តេច តែខ្ញុំព្រះករុណា ពុំថើបជើងរបស់អ្នកណាទាំងអស់*** >> ***ស៊ីម៉ុង*** ពោលចំពោះ***ប៉ាប*** ។ នៅក្រុង ***រ៉ោម*** នេះឯង ***ស៊ីម៉ុង*** បានសំរេចចិត្តធ្វើការរំដោះ រដ្ឋ ៦ នៅ ***អាមេរិកខាងត្បូង*** ពីនឹមអាណានិគម ***អេស្បាញ*** ។


www.budinst.gov.kh www.elibraryofcambodia.org

អាយុ ១៦ឆ្នាំ បានឋានៈជា ***អនុសេនីយត្រី*** ក្នុងកងអាសាស្ម័គ្ររបស់រដ្ឋការ ***អេស្ប៉ាញ*** ថ្ងៃទី ១៩ មករា ១៧៩៩ បានធ្វើដំណើរពី ***អាមេរិចខាងត្បូង*** មកកាន់ប្រទេស ***អេស្ប៉ាញ*** នៅទីនេះបាន ២-៣ខែប៉ុណ្ណោះ ក៏ត្រូវរាជការចាប់និរទេសទៅ ***បារីស*** ដោយបទថារួមគំនិតក្បត់នឹងឪពុកធំ ដើម្បីធ្វើឃាដស្តេច ។ អាយុ ១៩ឆ្នាំ ផុតពីទោសនីរទេស ហើយក៏ចូលទៅកាន់ប្រទេស ***អេស្ប៉ាញ*** វិញ រៀបការនឹងស្ត្រីជាតិ ***អេស្ប៉ាញ៉ុល*** ម្នាក់ ហើយក៏ត្រឡប់ទៅ ***អាមេរិកខាងត្បូង***វិញ រស់នៅយ៉ាងសុខសាន្តស៊ីមតិករបស់ខ្លួន ។ តែផ្ទុយទៅវិញ ***ស៊ីម៉ុង*** មិនសុខសោះ ទទួលជាជោគជតាមកផ្លាស់វេន ភរិយាទទួលមរណភាពទៅទៀត ។ ***ស៊ីម៉ុង*** ក៏សំរេចចិត្តមករៀនច្បាប់ឯប្រទេស ***អេស្ប៉ាញ*** ម្តងទៀត ដោយត្រូវចោទពីបទថា ជាអ្នកដឹកនាំនិស្សិតជាតិ ***អាមេរិកខាងត្បូង*** អោយបង្កើតអង្គការសេរីកាជាតិ ក៏ត្រូវនីរទេសទៅ ***បារីស*** ម្តងទៀត(ឱកាសនេះឯងដែលបានជួបនឹងគ្រូចាស់ ហើយធ្វើដំណើររហូតដល់ក្រុង ***រោម*** ដូចពោលហើយខាងមុខ) លុះបានសំរេចចិត្តធ្វើការរំដោះជាតិហើយ ក៏ធ្វើដំណើរចេញពីក្រុង ***រោម*** ទៅកាន់មាតុភូមិវិញ ។ ក្នុងអាយុ ២៣ឆ្នាំ បានចូលរួមក្នុង***ចលនាតស៊ូ*** ដែលមានកើតឡើងស្រាប់នៅរដ្ឋ ***វេនេស៊ុយអេឡា*** នោះ ។ តែការចុះដៃប្រកាសឯករាជ្យជាដំបូង ត្រូវរលំរលាយទៅវិញ ដោយបរាជ័យខាងកងទ័ព មិនត្រឹមតែប៉ុណ្ណោះ គេរឹមតិករបស់ខ្លួនក្នុងរដ្ឋនេះ ក៏ត្រូវរាជការរឹបអូសយកអស់ទៀត ដោយហេតុរួមក្នុងការក្បត់នេះ ។ ទីបំផុតត្រូវរាជការចាប់ខ្លួនយកទៅឃុំឃាំងបានទៀត ។ តែ


www.budinst.gov.kh www.elibraryofcambodia.org

***ឌីស្រាអែលី*** ជា ***ហ្សីហ្វ*** (Juit) កើតនៅថ្ងៃ២១ ធ្នូ ១៨០៤ ក្នុងសម័យនោះ***អង់គ្លេស*** ស្អប់ខ្មើមជាតិ ***ហ្សីហ្វ***យ៉ាងក្រៃលែង (សូម្បីសម័យសព្វថ្ងៃនេះក៏នៅស្អប់មិនតិចដែរ) ទើបគ្មានមហាវិទ្យាល័យណាមួយទទួលអោយចូលសិក្សាឡើយ ។ តែជាគ្រោះល្អ បិតារបស់ ***ឌីស្រាអែលី*** ជាអ្នកតែងសៀវភៅសៀវភៅមួយក្បាលដែលបិតារបស់គាត់តែងឡើងបានទទួលការនិយមបំផុតឈ្មោះ <<***រឿងដែលគួរដឹងក្នុងអក្សរសាស្ត្រ*** Curiosidties of Literature >> ***ឌីស្រាអែលី*** បានអាស្រ័យការសិក្សាពីបិតារបស់ខ្លួន និងនិយមទីស្ងាត់ ជាកន្លែងអានសៀវភៅ និងរៀនសូត្ររបស់គាត់ ទើបគាត់ផ្ចង់ទៅខាងអក្សរសាស្ត្រ ដល់ចំរើនវ័យឡើង បានផ្ដើមតែងសៀវភៅលក់ តែកុំថា តែមានមនុស្សទិញឡើយ សូម្បីអោយទទេក៏គ្មាននរណាចង់បានដែរ ។ ***ឌីស្រាអែលី*** ពុំលះបង់ព្យាយាមចចេសតែងទៀត ក្រោយមកបានតែងរឿង ***វិវៀនគ្រេយ៍*** (Vivian Gray) ក្នុងអាយុ ២២ឆ្នាំ ទើបមានមនុស្សផ្ដើមស្គាល់គាត់ខ្លះ ជាការសំរេច ***ជាន់ទី១*** ។

***ឌីស្រាអែលី*** ជាឧទាហរណ៍យ៉ាងល្អរបស់មនុស្សដែលមានសេចក្ដីព្យាយាម មិនរួញរា និងខកចិត្តកាលធ្វើអ្វីពុំបានសំរេច ។ កាលតែងសៀវភៅច្រើនឡើងៗ ទាល់តែមានមនុស្សនិយម និងទទួលស្គាល់ការវាងវៃរបស់ខ្លួនហើយ ក៏នាំយកការនិយមនោះ មកប្រើជាឧបករណ៍សំរាប់សាងអោយខ្លួនបានទទួលជ្រើសចូលក្នុង***រដ្ឋសភា*** ជាតំណាងរាស្ត្រក្នុងមណ្ឌលរបស់ខ្លួន ។ តែការព្យាយាមនោះៗធ្វើអោយបានសំរេចយ៉ាងលំបាកក្រៃលែង ជាងការតែង


www.budinst.gov.kh www.elibraryofcambodia.org

សៀវភៅអោយមនុស្សនិយមជាច្រើនរយគុណ តែជនជាតិស្បែកសតែងប្រកាន់ថា ***ការមិនសំរេចជាកាំជណ្តើរទី១ ដែលនឹងនាំទៅកាន់ការសំរេច*** ព្រោះហេតុនោះកាលមួយឆ្នាំ ពុំបានសំរេចក្នុងការជ្រើស ក៏ព្យាយាមដូច្នេះទាល់តែអាយុ ៣៤ ឆ្នាំ ទើបបានជ្រើសចូលក្នុង ***សភាសាមញ្ញ***ជាការសំរេច ***លើកទី ២*** ។

កាល ***ឌីស្រាអែលី*** ក្រោកឡើងនិយាយក្នុងសភាសាមញ្ញ ជាដំបូងគ្មាននរណាចង់ស្តាប់សោះ សមាជិកទាំងអស់ក្នុងសភានោះ សុទ្ធតែនាំគ្នាមើលងាយចំអកឡុកឡឺយ ។ ដូច្នោះ កាលគាត់និយាយចប់មុននឹងអង្គុយចុះគាត់តែងបន្ថែមចុងក្រោយថា<<***គង់មានវេលាថ្ងៃណាមួយដែលលោកទាំងឡាយនឹងត្រូវតាំងចិត្តស្តាប់ពាក្យដែលយើងខ្ញុំនិយាយ***>> ។ ក្រោយពីនោះមក ***ឌីស្រាអែលី*** ក៏តាំងគណៈបក្សរបស់ខ្លួនមួយឡើងអោយឈ្មោះថា <<***យុវអង់គ្លេស*** Young England>>ដែលមានសមាជិកសុទ្ធតែអ្នកចេះដឹង និងមានឋានៈល្អទាំងអស់ ។ អាយុ ៤៩ ឆ្នាំ ក៏បានជា ***រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ*** ជាការសំរេច***ជាន់ទី ៣*** ។

តែ ***ឌីស្រាអែលី*** និងបានរួញរា ឬលះបង់ព្យាយាម តែត្រឹមណេះក៏ទេដែរ បានព្យាយាមប្រៀនប្រដៅបក្សពួកក្នុងគណៈរបស់ខ្លួនអោយមានការចេះដឹងបន្ថែមច្រើនឡើងៗ ហើយខ្លួនឯងក៏មានៈធ្វើការយ៉ាងក្រៃលែង រហូតដល់អាយុ ៦៨ ឆ្នាំ ក៏បានជា ***នាយករដ្ឋមន្ត្រី*** ដែលជាការសំរេច ***ជាន់ទី ៤*** និងជា***ជាន់ខ្ពស់បំផុត*** ។


www.budinst.gov.kh www.elibraryofcambodia.org

ផលដែល ***ឌីស្រាអែលី*** បានធ្វើអោយប្រទេស ***អង់គ្លេស*** នោះគឺធ្វើអោយប្រទេស ***អង់គ្លេស***បានមានភាគហ៊ុន ក្នុងព្រែកជីក ***ស៊ុយអ៊ែស៍*** ពាក់កណ្ដាល ដែលជាគ្រឿងឧបករណ៍សំខាន់សំរាប់វាតអំណាចរបស់ ***អង់គ្លេស*** មកកាន់ប្រទេស***ឥណ្ឌា***និង ***អាស៊ី*** បានធ្វើអោយព្រះរាជវង្សអង់គ្លេសមានអំណាចពេញបរិបូណ៌ ។ ***ឌីស្រាអែលី*** បានចូលរួមប្រជុំដោយផ្ទាល់នាក្រុង ***ប៊ែរឡាំង*** ពីបញ្ហាសង្គ្រាមរាជវង្ស ***រុស្ស៊ី***និង ***ទួរគី*** និងជាអ្នកដែលធ្វើអោយប្រទេស ***អង់គ្លេស*** មិនត្រូវប្រកាសសង្គ្រាមនិងប្រទេស ***ព្រូស*** (Prusse) ដែលអាចជាគ្រោះថ្នាក់ដល់ប្រទេស ***អង់គ្លេស*** នឹងជាហេតុអោយប្រទេសដទៃៗនាំគ្នាចោមវាយប្រទេស ***អង់គ្លេស*** ។ ហេតុនេះឯង ***ឌីស្រាអែលី*** ទើបអះអាងបានថា ខ្លួនជាអ្នកផ្សាយរស្មីនៃប្រទេស ***អង់គ្លេស*** ដោយសន្តិវិធី មិនមែនដោយការកាប់សម្លាប់បង្ហូរឈាមតែម្យ៉ាងឡើយ ហើយការដែលអាចធ្វើបានយ៉ាងនេះ ក៏ដោយខួរក្បាលដែលឆ្លាតជាងមនុស្សធម្មតាជាច្រើន ។

***ឌីស្រាអែលី*** បានទទួលឋានន្តរជា ***ល័រដ ប៊ីខនស៍ហ្វីលដ៍*** (Lord Beaconsfield) និងទទួលមរណភាពកាលអាយុ ៧៧ ឆ្នាំ ។ សពរបស់គាត់បានបញ្ចុះក្នុងវិហារ ***វេស្ទិមន្សទើរ*** (Westminster) ដែលជាទីបញ្ចុះសព***វីរៈបុរស*** និង ***មហាបុរស*** នៃប្រទេស ***អង់គ្លេស*** ។ មហាក្សត្រីយានី ***វិគតូរៀ*** (Queen Victoria) នៃប្រទេសអង់គ្លេស ស្ដេចយាងទៅដាក់ភួងផ្កា ដោយផ្ទាល់ព្រះអង្គ និងទ្រង់ចារឹកអក្សរទុកដូច្នេះ ៖


www.budinst.gov.kh www.elibraryofcambodia.org

អនុស្សាវរីយ៍ជាទីស្រឡាញ់ និងប្រកបដោយកិត្តិយស

សំរាប់

បេនស្សមិន ខៅន៍ថ៍ អូហូ ប៊ីនខនស៍ហ្វីលដ៍

អនុស្សាវរីយ៍នេះបានសាងឡើងដោយព្រះរាជិនី

ជាមិត្រដែលស្គាល់គុណ និងស្រឡាញ់រាប់អាន

(ព្រះហស្តលេខា)

វិគតូរៀ

ខាងក្រោយបង្អស់មានពាក្យស្លោកថា :

<< ម្ចាស់ផែនដីទ្រង់ប្រោសជនដែលពោលពាក្យពិត >>

* * * * *



www.budinst.gov.kh www.elibraryofcambodia.org

# ប៊ីសម៉ាក៍

## BISMARCK
## 1815 - 1898



***ប៊ីសមារក៍*** មានលក្ខណៈជាអ្នកធ្វើអ្វីធ្វើពិត ។ បើត្រូវការអ្វីហើយ ត្រូវតែយកអោយបាន ពុំព្រមលះបង់ឡើយ នេះឯងជាលក្ខណៈពិតរបស់ ***ប៊ីសមារក៍*** និងជាឧទាហរណ៍ ដ៏សំខាន់នាំគាត់ទៅកាន់ការដ៏ធំ ក្នុងពង្សាវតារ ។ និស្ស័យដែលធ្វើអ្វីពិតនេះ មាននៅក្នុងខ្លួន ***ប៊ីសមារក៍*** តាំងពីនៅជាកុមារ មានរឿងដំនាលពីកាលនៅជាកុមារជាគ្រឿងបង្ហាញនូវ<<***និស្ស័យដែកថែប***>> របស់គាត់ដូចតទៅនេះ :

វេលានៅជាកុមារ ក្នុងសាលារៀន អាយុប្រហែល ១១-១២ឆ្នាំ មានពិធីបុណ្យមួយនៅភូមិរបស់ខ្លួន ហើយ ***ប៊ីសមារក៍*** ក៏នឹងត្រូវទៅរាំលេងជាមួយនឹងកុមារដទៃទៀតដែរ ។ តែខ្វះស្បែកជើងរកទិញពុំត្រូវសោះ ទើបទៅអោយជាងកាត់ស្បែកជើងកាត់អោយដំបូងជាងប្រកែង ព្រោះមានគេបញ្ជាអោយកាត់មុនច្រើនមកហើយ ហើយត្រូវប្រញាប់ធ្វើអោយ ហើយស្រេច


www.budinst.gov.kh www.elibraryofcambodia.org

នៅថ្ងៃបុណ្យដល់ទីបំផុត ***ប៊ីសមារក៍*** អន្ទោលខ្លាំងពេក ជាងក៏ព្រមទទួល មុននឹងដល់ថ្ងៃបុណ្យ ***ប៊ីសមារក៍*** ទៅសួររកស្បែកជើង ជាងប្រាប់ថាមិនទាន់បានចាប់ធ្វើនៅឡើយ ។ នរណាបញ្ជាមុនត្រូវធ្វើអោយមុន ចំណែក ***ប៊ីសមារក៍*** មកក្រោយគេ ជាងឥតសង្ឃឹមថា និងធ្វើអោយបានហើយស្រេចទាន់ថ្ងៃបុណ្យឡើយ ។ ***ប៊ីសមារក៍*** ឈរត្រង់ខ្លួនស្ងៀមមួយស្របក់ ក៏និយាយនឹងជាងថា :

<< ***ទុកជាយ៉ាងណាក៏ដោយ ខ្ញុំត្រូវតែបានស្បែកជើងក្នុងថ្ងៃបុណ្យអោយទាល់តែបាន*** >> និយាយហើយក៏ដើរចេញទៅ ជាហេតុអោយម្ចាស់ហាងញញឹមបញ្ចោះ ព្រោះទុកជាដូចម៉េចក៏ស្បែកជើងនោះពុំហើយដែរ ។

មួយស្របក់ក្រោយមក ***ប៊ីសមារក៍*** ក៏ត្រឡប់មកវិញ ដឹកផ្លែធំៗពីរមកផង ចូលទៅសួរជាងកាត់ស្បែកជើងថា :

***អ្នកឃើញផ្លែពីរនេះឬទេ ?***

***ឃើញ ! តើអ្នកនឹងធ្វើដូចម្ដេច ?***

***<<អ្នកចូរជ្រាបថា បើខ្ញុំមិនបានស្បែកជើងពាក់ក្នុងថ្ងៃបុណ្យនេះទេ ផ្លែទាំងពីរនេះនឹងហែកសញ្ជែកអ្នក >>*** និយាយរួចហើយ ក៏ដើរដឹកផ្លែចេញទៅអង្គុយនៅមាត់ថ្នល់ពីមុខហាងនោះឯង ។

អង្គុយទាល់តែយប់ហាងបិទទ្វារ ជាងកាត់ស្បែកជើងគិតថានឹងសំរាកក៏បានឮសម្លេងផ្លែព្រួសពីមុខខាង និងបានឮសម្លេង ***ប៊ីសមារក៍*** ដែលទុកជាហាងបិទទ្វារហើយ ក្ដីនៅតែអង្គុយនៅទីនោះឯង ស្រែកមកថា


www.budinst.gov.kh www.elibraryofcambodia.org

<<*ប្រយ័ត្ន ! ត្រូវអោយស្បែកជើងរបស់ប៊ីសមារក៍ បានរួចស្រេច បើពុំដូច្នោះទេ ជីវិតរបស់អ្នកនឹងរលត់*>> ។

ជាងកាត់ស្បែកជើងក៏សំរេចចិត្តហៅភរិយាមកជួយធ្វើ នៅយប់ថ្ងៃនោះ ដោយឥតបានដេក ធ្វើអស់មួយយប់ព្រឹកឡើងស្បែកជើងក៏ហើយស្រេច ។ បើកទ្វារឡើងក៏ឃើញ ***ប៊ីសមារក៍*** និងឆ្កែនៅអង្គុយពីមុខហាងនៅឡើយ អស់មួយយប់ដោយឥតមានសំដែងអោយឃើញថាងាកងុយ ឬ ចុករោយបន្តិចបន្តួចឡើយហើយក៏បានស្បែកជើងពាក់ទាន់ថ្ងៃបុណ្យដូចប្រាថ្នា ។

នេះឯងគឺ និស្ស័យដែលរឹងដូច ***ដែកថែប*** របស់លោក ***នាយករដ្ឋមន្ត្រី*** ជាអ្នកតាំង ***មហាណាចក្រ អាល្លឺម៉ាញ*** ។ បើសិនពុំបានជា ***នាយករដ្ឋមន្ត្រី*** ទេនោះ អាចនឹងទៅជាចោរដ៏សាហាវបំផុត ក៏បាន ។

***ប៊ីសមារក៍*** កើតនៅថ្ងៃទី១ មេសា ១៨១៥ ក្នុងត្រកូលអ្នកមានបង្គួរ និងជាទាហាន បានទទួលការសិក្សាយ៉ាងប្រសើរ ចាប់រៀនច្បាប់ជាមុន ហើយរៀនវិជ្ជាទាហានជាក្រោយ ដើម្បីតំណវង្សត្រកូល សំរេចវិជ្ជាពីរប្រការនេះហើយ ក៏ចូលធ្វើការផ្នែករាជការស៊ីវិល ដោយអាស្រ័យលក្ខណៈមាំទាំរឹងប៉ឹង និងវាងវៃរបស់ខ្លួន ក៏បានចូលជាសមាជិកក្នុង ***រដ្ឋសភា*** ។ កាលអាយុ៣២ឆ្នាំ បានជា ***ប្រធានគណបក្សខាងស្តាំ*** ។ អាយុ៣៧ឆ្នាំ បានទទួលតំនែងជា ***លេខាធិការស្ថានទូតព្រុស***(Prusse)ប្រចាំរដ្ឋ ***ហ្វ្រង់ហ្វរដ***(Francforts) ពីរខែក្រោយមក ក៏បានជា ***ឯកអគ្គរាជទូត*** តមកទៀត ១០ឆ្នាំ បានជា ***ឯកអគ្គរាជទូត*** ប្រចាំនៅក្រុង ***ប៉ារីស*** តែនៅបានតែមួយឆ្នាំ គណៈបក្សនយោបាយ


www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងប្រទេស ក៏ចាប់ផ្ដើមប្រកួតប្រជែងនិងស្ដេចផែនដី ។ ព្រះរាជាប្រទេស ***ព្រូស*** ទ្រង់យល់ឃើញថាមានតែ ***ប៊ីសមារក៍*** ម្នាក់ប៉ុណ្ណោះ អាចនិងជួយព្រះអង្គបាន ទើបកោះហៅ ***ប៊ីសមារក៍*** អោយត្រឡប់មក ***ប៊ែរឡាំង*** ។ ***ប៊ីសមារក៍*** ក៏បានជា ***នាយករដ្ឋមន្ត្រី*** និង ***រដ្ឋមន្ត្រីកិច្ចការបរទេស*** ផង ក្នុងអាយុ ៤៩ ឆ្នាំ។ អច្ឆរិយនិស្ស័យរបស់ ***ប៊ីសមារក៍*** ម្យ៉ាងទៀតនោះ គឺមិនចូលចិត្តធ្វើអ្វីងាយៗចូលចិត្តរើសរកផ្លូវដែលលំបាកៗ ដោយយល់ឃើញថារបស់អ្វីដែលសំរេចដោយលំបាក តែងនាំផលល្អមកអោយប្រសើរជាងរបស់ដែលសំរេចដោយងាយៗ ។ ក្រៅពីនោះគាត់ជាមនុស្សដែលមិនចេះ រន្ធត់ញាប់ញ័រចំពោះព្រឹត្តិការណ៍ណាមួយឡើយ ។ កាលឡើងជា នាយករដ្ឋមន្ត្រីថ្មីៗ តំនាងរាស្ត្រក្នុងរដ្ឋសភាក៏មិនចូលខាងខ្លួន កាសែតជាច្រើនក៏ចោមគ្នាជេរ តែក៏ឥតធ្វើអោយ ***ប៊ីសមារក៍*** ញាប់ញ័រឡើយ ទ្រនិចរបស់ ***ប៊ីសមារក៍*** ចង្អុលទៅទិសតែមួយ គឺលើកស្ទួយ ***អំណាចព្រះមហាក្សត្រ*** និងរួបរួមអាណាចក្រ ***អាល្លឺម៉ាញ*** ទាំងអស់ដែលកំពុងបែកខ្ញែកគ្នាអោយរួមគ្នាតែមួយ តែការធ្វើដូច្នេះនេះ ត្រូវជួបការលំបាកពីរផ្លូវគឺ

១. បណ្ដាអាណាចក្រអាល្លឺម៉ាញទាំងអស់ ក្រៅពីព្រូសចេញ នៅមាន ***អូទ្រិស*** មួយទៀត ដែលបានទទួលការគោរពរាប់អានពីជនជាតិអាល្លឺម៉ង់ដ៏ទូទៅ ហើយមានអាណាចក្រខ្លះចង់រួម និងអូទ្រិស ជាងរួមនឹង ***ព្រូស*** ។

២. គឺប្រទេសបារាំង នៅតែព្យាយាមរារាំង មិនអោយប្រទេសអាល្លឺម៉ាញរួមចូលគ្នាបាន ព្រោះនិងទៅជាគ្រោះថ្នាក់ដល់ប្រទេសបារាំងទៅ


www.budinst.gov.kh www.elibraryofcambodia.org

អនាគត ដោយហេតុនេះឯងផែនការណ៍របស់***ប៊ីសមារក៍***ទើបមាន៣ខគឺ :

*១. ការពារកុំអោយមនោគមវិជ្ជា អូទ្រីសផ្សាយចូលទៅក្នុងអាណាចក្រអាល្លឺម៉ាញទាំងអស់ ។*

*២. ការពារកុំអោយប្រទេសបារាំង ជាមិត្រស្និទ្ធស្នាលនិងប្រទេសដទៃៗ ព្រោះប៊ីសមារក៍យល់ថាលំពាំង បារាំង តែមួយពុំអាចជាគ្រោះថ្នាក់ដល់ខ្លួនបានឡើយ ។*

*៣. បង្កើនកម្លាំងប្រទេសព្រូស អោយមាំទាំឡើងទាល់តែបានជាទីកោតក្រែង និងនិយមរាប់អានអាណាចក្រអាល្លឺម៉ាញទាំងអស់ ។*

គ្រោងការណ៍ទាំង៣នេះឯងដែល ***ប៊ីសមារក៍*** អនុវត្តអស់មួយសម័យដែលគាត់កាន់អំណាច ។

ការសំរេចជាដំបូងរបស់ ***ប៊ីសមារក៍***គឺដណ្តើមយក ***ស្លេស្វិក*** (Slesvig) និង***ហូលស្តែន៍*** (Holstein) មកពី ***ដាណឺម៉ារក***(Danemark)បាន ជាហេតុអោយសត្រូវខាងក្រៅនាំគ្នាកោតក្រែង ហើយសត្រូវខាងក្នុងគឺ ***រដ្ឋសភា*** ក៏ក្លាយទៅជាមិត្រ អំណាចរបស់ ***ប៊ីសមារក៍*** ក្នុងព្រូស ក៏មាំទាំឥតឃ្លេងឃ្លោង ។ កាលបានចាត់ការបង្កើនកងទ័ពក្នុង ***ព្រូស*** អោយមានកំលាំងគ្រប់គ្រាន់ហើយក៏ប្រកាសយក ***ហ្សេង្គហ្វូរ៍ដ*** រួមចូលបានមួយទៀត ។ សង្គ្រាមដែល ***រុស្ស៊ី*** បានជ័យជំនះលើបារាំងនៅឆ្នាំ១៨៧១ ជាការសំរេច ***ដាច់ខាតបំផុត***របស់ ***ប៊ីសមារក៍***រួបរួមអាណាចក្រ ***អាល្លឺម៉ាញ*** ទាំងអស់ចូលជាប្រទេសតែមួយបាន ។ នេះពោលយ៉ាងសង្ខេបបំផុតពីជីវប្រវត្តិរបស់ ***ប៊ីសមារក៍*** ។

លោក ***ប៊ីសមារក៍*** បានអនិច្ចកម្មនៅឆ្នាំ១៨៩៨ ក្នុងអាយុ៨៣ឆ្នាំ ។



www.budinst.gov.kh www.elibraryofcambodia.org

# ស៊ុន យ៉ាត់ សេន

# SUN YAT SEN
## 1866 - 1925



***ស៊ុន យ៉ាត់ សេន*** ជាអ្នករំដោះ ***ប្រទេសចិន*** ពីនឹមដែកនៃស្ដេច ***ម៉ង់ស៊ូ*** (Mandchoue) ដែលឥតមានជនណាម្នាក់ភ្ញាក់នឹកឃើញថា <<***អាចនឹងធ្វើទៅកើតសោះ***>> <<***ទុកចិនអោយដេកលក់ចុះ***>> ***តែកាលណាចិនភ្ញាក់ឡើងពិភពលោកនឹងមានភ័យ***>>នេះឯងដែលអាណានិគមនិយម គេត្រូវប្រព្រឹត្តអនុវត្តទៅលើជនជាតិនិង***មហាប្រទេសចិន*** ។

***ស៊ុន យ៉ាត់សេន*** កើតនៅជិតខេត្ត ***កង់តុង*** (Canton) ក្នុងគ.ស. ១៨៦៦ ក្នុងត្រកូលអ្នកស្រែ ។ កាលនៅជាកុមារតូចនៅឡើយ ត្រូវមានបន្ទុកការងារធ្ងន់ៗជាច្រើន គឺត្រូវរៀនអក្សរចិនក្នុងមួយសប្ដាហ៍ពេញ ៧ ថ្ងៃ ផុតម៉ោងរៀនត្រូវជួយធ្វើកិច្ចការផ្ទះ ស្រែចំការជាមួយនិងឪពុកទៀត ។

បិតារបស់គាត់ជាមនុស្សខួរក្បាលសម័យ បើទុកជាពុំដែលឃើញ ពុំដែលស្គាល់ ***សហរដ្ឋអាមេរិក*** ក៏ដោយ ។ គាត់ក៏តែងតែស្រវាស្រទេញ ដើម្បី


www.budinst.gov.kh www.elibraryofcambodia.org

បញ្ជូនកូនគាត់ទៅប្រកបវិជ្ជាជីវៈនៅ ***ស.រ.អា*** ជានិច្ច ។ គាត់បានបញ្ជូនបង បង្កើតរបស់ ***ស៊ុន***នេះទៅនៅ ***ហូណូលូៗ*** ម្នាក់រួចទៅហើយ ។ ឯកុមារ ***ស៊ុន*** វិញ តែងតែបានស្តាប់ការពិពណ៌នាអំពី ***ស.រ.អា*** ដោយឪពុកមារបង្កើតរបស់ខ្លួនម្នាក់ ដែលជាអ្នកមានពត៌មានប្លែកៗ ពី ***ស.រ.អា*** នាំមកបញ្ចូលចិត្តកុមារ ***ស៊ុន*** ជារឿយៗ ។ ក្រោយមក កុមារ ***ស៊ុន*** កាលណាបានជួប និងអ្នកដែលទើបវិលមកពី ***ស.រ.អា*** ក៏តែងតែសាកសួរពីជីវិតប្រចាំថ្ងៃរបស់ជនជាតិ ***អាមេរិកកាំង*** ។ កុមារ ***ស៊ុន*** បានស្តាប់ហើយ ក៏ជារឿងប្លែកអស្ចារ្យនៅក្នុងចិត្តក្រៃលែងថា :

<< ***ដែលមានឬមនុស្សក្នុងលោកនេះ មិនបួងសក់*** >> !

<< ***ដែលមានឬមនុស្សក្នុងលោកនេះ មិននៅក្រោមអំណាចព្រះទេវឱរសជាអម្ចាស់ ក្រុងចិន*** >> !

<< ***ដែលមានឬមនុស្សក្នុងលោកនេះ អាចជ្រើសរើសអ្នកគ្រប់គ្រងកំពូលរបស់គេម្នាក់ មិនបាច់ឡើងផ្ទាល់ព្រះអម្ចាស់ក្រុងចិន*** >> រឿងសំខាន់ដែលប្លែកអស្ចារ្យណាស់ទៅទៀតនោះ គឺ << ***គេមិនប្រហារមនុស្សជាល្បែងដោយឥតមានកំហុសពិតប្រាកដបានឡើយ*** >> ។ កុមារ ***ស៊ុន*** ធ្លាប់តែបានទទួលការអប់រំ ផ្ទុយពីឃ្លាទាំងប៉ុន្មានខាងលើនេះ មកជាយូរយារមកហើយ សូម្បីតែជីវិត ក៏គេគ្មានសិទ្ធិនឹងការពារ រកយុត្តិធម៌បានដែរ ព្រោះស្រេចហើយតែព្រះទេវឱរសជាអម្ចាស់ ***ក្រុងចិន*** ទាំងអស់ ។



www.budinst.gov.kh www.elibraryofcambodia.org

ចង់ដឹង ចង់ឃើញ ចង់រស់នៅក្នុងលោក ដែលបានឮគេពិពណ៌នាអោយស្តាប់នោះ រឹតតែមានទម្ងន់ទៅលើការតាំងចិត្ត របស់បិតាគាត់ស្រាប់មកហើយនោះ ។ អាយុ ១៥ឆ្នាំ ***ស៊ុន*** ក៏បានទៅនៅ ***ហូណូលូៗ*** ជាមួយនឹងបងប្រុស ដែលមានឋានៈបង្គួរក្នុងជីវិតប្រចាំថ្ងៃ ជួយលក់ដូរផង ចូលទៅរៀននៅក្នុងសាលាផង ចំណាចវេលាតែ៣ឆ្នាំ ***ស៊ុន*** ក៏បានទទួលមធ្យមសិក្សាប័ត្រខាងភាសា ***អង់គ្លេស*** គណិតសាស្ត្រ និងប្រវត្តិសាស្ត្រ ។ ត្រឹមតែជាដែនដីអាណានិគមប៉ុណ្ណោះដែនដី ***ហូណូលូៗ***ប្រៀបបាននឹងឋានសួគ៌របស់ស៊ុនទៅហើយ ។ ចុះទំរាំបើ ***សហរដ្ឋអាមេរិក*** មែនៗនោះ តើនឹងជាយ៉ាងណាទៅ ? ពិសេសទៅទៀត វិជ្ជាប្រវត្តិសាស្ត្រធ្វើអោយ ស៊ុនស្គាល់ច្បាស់នូវអតីតកាលដ៏ថ្កុំថ្កើងរបស់ចិនលើសទៅទៀត បញ្ជាក់អោយរឹតតែច្បាស់ថាព្រះទេវឱរសជាអម្ចាស់ក្រុងចិននោះ ពុំមែនជាជាតិចិនទៅទៀត គឺជាជាតិ ***ម៉ង់ស៊ូ*** ។ ពន្លឺថ្មីនេះឯង ជាប្រភពនៃជាតិនិយម ដុះឡើងក្នុងចិត្តរបស់ ***ស៊ុន*** ។ បងរបស់***ស៊ុន*** ហាមប្រាមជានិច្ច ព្រោះគាត់យល់ថា ការយល់សប្តិរបស់ ***ស៊ុន*** នោះ<< ***ទៅមិនរួចទេ*** >> ***ស៊ុន*** ក៏នៅតែរវើរវាយទៀត ។ ទីបំផុតបងរបស់ ***ស៊ុន*** គិតឃើញថា នឹងទុកអោយនៅជាមួយ ក៏ជាការឥតប្រយោជន៍ ក៏បញ្ជូន ***ស៊ុន***ត្រឡប់អោយទៅនៅជាមួយបិតាវា សូម្បីបិតាក៏ពុំអាចទប់នូវកម្លាំងទឹកហូរនៃគំនិតជាតិនិយមរបស់ ***ស៊ុន*** ដែរ ។ ប៉ុន្តែនិយមជាតិខ្លាំងពេក រហូតដល់ទៅប្រឆាំងនឹងរូបអ្នកតា ជាទីកសក្ការៈរបស់អ្នកភូមិផងទៀតនោះ សេចក្តីល្អខាងការបង្កើតលទ្ធិជាតិនិយមពុំអាចជួយ ***ស៊ុន*** ដែលអាយុមិនទាន់


www.budinst.gov.kh www.elibraryofcambodia.org

ដល់ ២០ឆ្នាំផងក្នុងពេលនោះបានឡើយ អ្នកភូមិក៏ទាមទារដល់ឪពុក ***ស៊ុន*** អោយដេញស៊ុនចេញពីភូមិ ដោយហេតុគាត់ទៅកាច់បំបាក់ដៃ រូបអ្នកតា នៅក្នុងវត្តរបស់គេ ។ ***ស៊ុន*** ក៏បាននិរទេសខ្លួនទៅនៅ ***ហុងកុង*** ។ ហុងកុង ជាដែនដីអាណានិគមរបស់ ***អង់គ្លេស*** នៅទីនោះ ***ស៊ុន*** ក៏ចូលរៀននៅ ***ឃ្វីន្ស ខលេ្លចូ*** (Queen's College) ហើយក៏ប្រឡងបានសំរេច នូវបរិញ្ញប័ត្រខាងពេទ្យ ***ជំនាន់ទី១*** នៃវិទ្យាល័យនោះ ក្នុងរយៈសិក្សានេះ គាត់ក៏មានសេរីភាពគ្រប់គ្រាន់ផ្សាយនៅគំនិតជាតិនិយមរបស់គាត់ រហូតដល់បានរីកចំរើនឡើងៗ ស្ទើរតែគ្រប់ក្រុងធំៗទាំងអស់ មានការទាក់ទងគ្នាទៅវិញទៅមក ហើយគ្រប់សាលាទាំងអស់ ក៏សុទ្ធតែទទួលស្គាល់ ***ស៊ុន*** តែមួយប៉ុណ្ណោះ ជា***នាយក*** ។

នៅឆ្នាំ ១៨៩៥ ***ស៊ុន*** អាយុ ២៩ឆ្នាំ ការចលាចលក៏កើតឡើងបានដូចបំណង តែជាការបដិវត្តន៍ប្រញាប់ប្រញាល់ពេក ក៏បានទទួលនូវបរាជ័យទៅវិញ តែពុំរលត់ទេ ។ រដ្ឋាភិបាល ***ម៉ាំងស៊ូ*** ក៏ប្រកាសគ្រប់ទីកន្លែង គ្រប់ស្ថានទូតរបស់ខ្លួនអោយចាប់ខ្លួន ***ស៊ុន យ៉ាត់សេន*** ទោះជារស់ក្តីស្លាប់ក្តីអោយតែបានវាយតម្លៃរង្វាន់មួយសែនប៉ោនដ៏ប្រាក់អង់គ្លេស តែក៏គ្មាននរណាអាចសម្រេចបាន ។

***ស៊ុន យ៉ាត់សេន*** ក៏ធ្វើដំណើរទៅកាន់មហាប្រទេសធំៗ ក្នុងលោកស្ទើរតែទាំងអស់ ដើម្បីថ្លែងការណ៍ យកមតិសាកល រូបមន្តដាស់ស្មារតីជាតិចិន សំខាន់បំផុតរបស់គាត់ គឺនៅត្រង់ឃ្លាថា <<***ស្តេចម៉ង់ស៊ូ គ្មានសិទ្ធិគ្រប់គ្រងជនជាតិចិនទេ មានតែជនជាតិចិនប៉ុណ្ណោះ ទើបមានសិទ្ធិគ្រប់***


www.budinst.gov.kh www.elibraryofcambodia.org

***គ្រងខ្លួនឯង*** >> រូបមន្តនេះជ្រួតជ្រាបទូទៅ សូម្បីមហាតលិកក្នុងវាំង ក៏យកទៅសូត្រលេងដែរ ដំបូងទំនងជាការឡកឡឺយ តែយូរៗទៅក៏ក្លាយជាជំនឿមែនទែនតែម្តង ។

គាត់បានត្រូវស្ថានទូតចិននៅប្រទេស ***អង់គ្លេស*** ចាប់ខ្លួនបានម្តង តែរដ្ឋាភិបាល ***អង់គ្លេស*** តវ៉ា ដោយទំនាស់នឹងច្បាប់អន្តរជាតិ ។ លុះរួចខ្លួនហើយ គាត់ក៏ចូលទៅតាំងមន្ទីរចាត់ការបដិវត្តន៍នៅប្រទេស ***ជប៉ុន*** គៀកគ្នានឹងស្ថាន ***ទូតចិន***ប្រចាំប្រទេសជប៉ុននោះឯង គាត់ផ្សាយគ្រប់មធ្យោបាយបដិវត្តន៍ ចូលទៅក្នុង ***ប្រទេសចិន*** ។

នៅខែ កញ្ញា ១៩១១ អាយុ ៤៥ឆ្នាំ គាត់ក៏បានសំរេចនូវការបដិវត្តន៍បង្ហូរឈាមជាប្រាកដប្រជាឡើង ។ លុះអាយុ ៥២ឆ្នាំ ១៩១៨ គាត់ក៏បានគ្រប់គ្រងលើអាណាខេត្ត ៧ នៅភាគខាងត្បូងនៃប្រទេសចិន ។ នៅថ្ងៃទី ១ មករា ១៩២១ អាយុ ៥៥ឆ្នាំ ក៏បានទទួលតំណែង ***ប្រធានាធិបតីនៃសាធារណរដ្ឋចិន*** សឹងមិនដល់មួយឆ្នាំផង ដោយការប្រជែងប្រណាំនូវកៅអីពីវរជនដទៃទៀត គាត់ក៏លាលែងពីតំណែង ដោយគាត់ឥតប្រាថ្នាអ្វីជាការផ្ទាល់ខ្លួនសោះ សុខចិត្តដើរខាងក្រៅ ទទួលយកអំណាចខាងផ្លូវចិត្ត (Spiritual power) ជាអ្នកឃោសនាដឹកនាំ ខាងអភិវឌ្ឍនាការនិយមទៅវិញ ។ ឋានៈគាត់ក៏ក្លាយទៅជាខ្ពស់បំផុត ផ្ទៀបទៅនឹង ***ខុងជឺ*** (Confucious) អ្នកប្រាជ្ញចិនពីបុរាណកាលដែលជាឋានៈមិនចេះក្តៅក្រហាយ រលត់រលាយសោះឡើយ ។


www.budinst.gov.kh www.elibraryofcambodia.org

អាយុ ៥៩ ឆ្នាំ គ.ស ១៩២៥ ។ អវសាននៃជីវិតបិតាជាតិនិមយមចិនក៏ចូលមកដល់ ។ នៅលើទង់នៃសេចក្តីគោរព - ស្វាមីភក្តិដ៏ជ្រាលជ្រៅជាទីបំផុត ដែលកប់នៅក្នុងបេះដូង នៃជនជាតិចិនរាប់រយលាននាក់ជានិច្ចរៀងមក ។

* * * * *


www.budinst.gov.kh www.elibraryofcambodia.org

# នីកូឡាយ លេនីន

# NIKOLAI LENINE

# 1870 - 1924

***ហេនរី ថូមាស*** (Henrethomas) និង ***ដាណាលី ថូមាស*** (Danaly thomas) អ្នកនិពន្ធ ***អាមេរិកកាំង***បានសរសេរសៀវភៅ Famous men (ឆ្នើមមនុស្ស)ថា <<មានមនុស្សតិចណាស់ក្នុងប្រវត្តិសាស្ត្រ បានទទួលការស្រឡាញ់ពីជនទាំងឡាយដូច ***លេនីន*** >> ។ ***តែលេនីន*** បានទទួលការស្រឡាញ់គោរពពីជនទាំងឡាយយ៉ាងជ្រាលជ្រៅ ព្រោះបានចំណាយសតិប្រាជ្ញាទាំងអស់ ដើម្បីបំរើចំពោះជនជាតិរបស់គាត់ ។ គាត់មានសមត្ថភាពក្នុងការបង្ហាញការគិតដែលយល់លំបាកបំផុតដោយពាក្យងាយយល់បំផុត និយាយទៅបានតាមគិត និងនិយាយគ្រប់យ៉ាងដោយសេចក្តីស្មោះត្រង់ប្រាសចាកការលាក់គំនួច ។ បើគាត់ធ្វើអ្វីខុស គាត់នឹងជាមនុស្សមុនបំផុត ដែលសំដែងកំហុសរបស់គាត់ចេញមកខ្លួនឯង ។ អស់មួយជីវិតរបស់គាត់***លេនីន*** មានគោលបំណងតែម្យ៉ាង គឺចាត់របៀប


www.budinst.gov.kh www.elibraryofcambodia.org

សង្គមថ្មី មិនអោយមានការជិះជាន់ មិនអោយមានការធ្វើស្រែលើខ្នងមនុស្ស មិនអោយមានការគ្មានការងារធ្វើ មិនអោយមានការប្រើកលល្បិចឡប់ឡិន ក្នុងការរដ្ឋរវាងប្រទេស និងមិនអោយមានសង្គ្រាម ដោយគោលបំណងដូច ពោលមកនេះ ***លេនីន*** បានលះបង់សេចក្តីសុខ សេចក្តីប្រាថ្នាផ្ទាល់ខ្លួន និង មហិច្ឆតា(Ambition )គ្រប់យ៉ាង ។

***លេនីន*** កើតក្រោយ ***ស៊ុន យ៉ាត់សេន*** បិតាជាតិនិយមចិនចំនួន ៤ឆ្នាំ គឺ ក្នុងគ.ស ១៨៧០ គ្រួសារធុនកណ្តាល ***ឪពុក*** ជាអធិការប្រចាំខេត្ត ***ម្តាយ*** ជា បុត្រីពេទ្យ ។

***លេនីន*** កើតឡើង ក្នុងក្រុងប្រជុំអ្នកចេះដឹង គឺក្រុង ***សាំប៊ើក*** (Sim-birsk ) ក្នុងសម័យកាប់សម្លាប់ជិះជាន់លួចប្លន់ដីប្លែកៗ និងតែមួយម័យ ប៉ុណ្ណោះក្នុងប្រវត្តិសាស្ត្រ ***រុស្ស៊ី*** ។

គាត់មានគំនិតបដិវត្ត ផ្ទុយពីបុព្វការីជនរបស់គាត់ ដែលមានប្រាថ្នាចង់ អោយគាត់មានមុខតំណែងក្នុងកិច្ចការរាជការ ។ គាត់អាយុ ១៦ឆ្នាំ សិក្សានៅ ថ្នាក់មធ្យមសិក្សាភាគទី២ សល់តែមួយឆ្នាំប៉ុណ្ណោះនឹងចូលក្នុងមហាវិទ្យាល័យ ក៏កើតរឿងគួរអោយតក់ស្លុត គឺពួកនិស្សិតមួយក្រុមត្រូវចាប់ ដោយបទ ប្រាថ្នាធ្វើឃាតចំពោះព្រះមហាចក្រពត្តិ ហើយត្រូវកាត់ទោសប្រហារជីវិត ។ បងប្រុសរបស់គាត់ម្នាក់ ក៏ចូលក្នុងចំណោមអ្នកទោសឧក្រិដ្ឋនោះដែរ ។ មួយ ឆ្នាំក្រោយមកគាត់ ក៏ចូលរៀនក្នុងមហាវិទ្យាល័យ ដោយឋានៈខ្លួនជាប្អូននៃ ជនទោសឧក្រិដ្ឋដូច្នោះ បញ្ហាដ៏តឹងរឹងពីរាជការដល់មហាវិទ្យាល័យ


www.budinst.gov.kh www.elibraryofcambodia.org

អោយពិនិត្យតាមដានមធ្យ័ត ។ ហើយក្នុងមហាវិទ្យាល័យក៏ពុំពេញចិត្ត នឹងទទួលអោយចូលរៀនបណ្តោយទៅទៀត ។ ***លេនីន*** រៀនពុំបានប៉ុន្មានខែផង ក៏ត្រូវលប់ឈ្មោះចោលអោយឈប់រៀន ដោយបទថាបានផ្សាយឥទ្ធិពលអាក្រក់ដល់មិត្តនិស្សិតដូចគ្នា ។

***លេនីន*** បានរៀននឹងគ្រូផ្ទាល់នៅផ្ទះអស់មួយរយៈ ក៏ប្រឡងចូលរៀនច្បាប់នៅសាលាច្បាប់ក្រុង ***ប៉េទ័រសប៊ួរក៏*** (Péters bourg) សព្វថ្ងៃហៅ (Leningrad) រៀនបានប្រឡងជាប់ជានីតិបណ្ឌិត ។ អាយុ២៤ឆ្នាំ ចេញធ្វើជាមេធាវីធ្វើបាន ៣ឆ្នាំ ក៏ត្រូវចាប់និរទេសទៅ ***ស៊ីបេរី*** (Sibérfie) ដោយបទបង្កអសន្តិសុខផ្ទៃក្នុង ។

ក្នុងរយៈកាលត្រូវនិរទេសនេះឯង ជាឱកាសអោយគាត់រៀបចំផែនការណ៍ និងទ្រឹស្តីបដិវត្តដ៏សំខាន់ៗ ដោយបានជំនួយពីស្ត្រីម្នាក់ឈ្មោះ ***ស្គ្រុបស្កាយ៉ា*** (Skrup Skaya) ដែលជាមិត្តសមានាចារ្យ ហើយត្រូវនិរទេសដូចគ្នា (ក្រោយមកគឺជាភរិយារបស់គាត់) ។ លុះអាយុ៣០ឆ្នាំ (១៩០០) គាត់បានត្រូវរួចទោស ហើយធ្វើដំណើរទៅកាន់ប្រទេស ***អាល្លឺម៉ាញ*** ចាប់បង្កើតសារពត៌មានមួយឈ្មោះ ***អ៊ីសក្រា*** (Ikra សែងអគ្គី) អត្ថបទពេញទៅដោយការដាស់អោយធ្វើបដិវត្ត ។ រដ្ឋាភិបាល ***អាល្លឺម៉ង់*** ពុំពេញចិត្តក៏ដេញចេញពីប្រទេស ។ តមកគាត់ក៏ក្លាយទៅជាអ្នកពនេចរ ទៅគ្រប់ច្រកល្ហកតែក៏ជាផលនាំអោយគាត់បានមិត្តរួមឧត្តមគតិកើនឡើងដែរ ។


www.budinst.gov.kh www.elibraryofcambodia.org

សង្គ្រាម ***ជប៉ុន -រុស្សី*** (១៩០៤)កើតឡើង គាត់ក៏បានចុះដៃធ្វើការបដិវត្តន៍ជាលើកទី១ ។ តែអង្គការបដិវត្តន៍ ត្រូវបរាជ័យ គាត់ក៏នៅជាអ្នកពនេចរតទៅទៀត ។

សង្គ្រាមលោក ១៩១៤ អង្គការបដិវត្តន៍ ក៏បានទទួលជោគជ័យក្នុងឱកសនោះ ។ បន្ទាប់ពីនោះមក ឆាកជីវិតរបស់គាត់ ក៏ចូលដល់ការសាងអោយសំរេច នូវគោលបំណងសន្តិភាពរបស់គាត់ ដូចមានពោលជាសង្ខេបពីខាងមុខស្រាប់ ។ គូប្រជែងទន្ទឹមស្មាគ្នាដែលមានការយល់ផ្ទុយ របស់គាត់ក៏បានទទួលការបរាជ័យយ៉ាងសន្សឹមៗ ។ ការសំរេចនូវគោលបំណងសន្តិភាពរបស់គាត់ ក៏មានរស្មីភ្លឺរុងរឿងសាងខ្លួនរបស់គាត់អោយក្លាយទៅជាអាទិទេព តាមទស្សនៈរបស់លោក***វ៉ល់ធឺរ ឌូរេន្ធី***(Walter Duranty) និង ***ម៉ូអ៊ីស*** (Moïse) តាមទស្សនៈរបស់លោក***ប៊ែរណារ៍ដ ប៉ារេស*** (Bernard Peres) ។ ***លេនីន*** បានសាងខ្លួន ទៅជាអ្នកជប់***សាធារណរដ្ឋសង្គមនិយមសូវៀត*** ថ្មីដូចបច្ចុប្បន្ននេះ ។

ថ្ងៃទី ៧ វិច្ឆិកា ១៩១៧ ***លេនីន*** បានសាងខ្លួនឡើងដល់ថ្នាក់ខ្ពស់បំផុតគឺជា ***ប្រមុខរដ្ឋសូវៀត*** ។ ។

អាយុ ៥៤ឆ្នាំ ថ្ងៃទី ២១ មករា ១៩២៤ ***លេនីន*** បានលាចាកលោកនេះទៅ បន្សល់ទុកនូវសំណាង ដ៏មហិមា ដល់ជនជាតិ ***សូវៀត*** ។

❊ ❊ ❊ ❊ ❊


www.budinst.gov.kh www.elibraryofcambodia.org

# មូស្សូលីនី

# MUSSOLINI

## 1883 - 1945

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



***មូស្សូលីនី*** ជាអ្នកបង្កើតលទ្ធិ ***កលាបនិយម*** (Fascism) ដែលយើងមិនគួរលើកឡើងមកជាតួយ៉ាងសំរាប់អ្នកសាងខ្លួនឡើយ ។ តែដោយវត្ថុបំណងសៀវភៅនេះ ត្រូវការតែ <<***កូនសោរ***>> ដែលនាំខ្លួនគាត់ឡើងទៅកាន់កំពូលប៉ុណ្ណោះ ដើម្បីអោយបានជាឧបករណ៍ដល់អ្នកអានសំរាប់សាងខ្លួន ។ មិនមែនអោយលោកអ្នកអាន ក្លាយទៅជា ***មូស្សូលីនី*** ឡើយ ហើយឯលទ្ធិ ***កលានិយម*** របស់គាត់មកអនុវត្តឡើយ សូមអោយរើសចំនុចល្អរបស់គាត់ មកប្រើបានហើយ ដូចមានបញ្ជាក់នៅក្នុងបុព្វប្រយោគស្រាប់ ។

***មូស្សូលីនី*** កើតនៅខែកក្កដា ១៨៨៣ ក្នុងត្រកូលក្រីក្របំផុត ធំឡើងឪពុកអោយរៀនឯសាលា បានទទួលរាយការណ៍ពីគ្រូថា រៀនពូកែណាស់ ។ តែឪពុកម្តាយពុំមានប្រាក់គ្រប់គ្រាន់ នឹងបង់ថ្លៃសិក្សាតទៅទៀត ទើបបានផ្ញើពាក្យសុំអង្វរកចំពោះសាលាធិការសុំអោយ ***មូស្សូលីនី*** បានសិក្សាដោយមិនបាច់បង់ថ្លៃសាលា ។ តែសាលាធិការពុំយល់ព្រម ***មូស្សូលីនី*** ក៏ត្រូវឈប់រៀន



www.budinst.gov.kh www.elibraryofcambodia.org

មករកស៊ីចិញ្ចឹមជីវិតជាមួយឪពុកម្តាយ ។ កាលអាយុបាន២០ឆ្នាំ អស់ផ្លូវរកស៊ីចិញ្ចឹមជីវិតក្នុងប្រទេស ***អ៊ីតាលី*** ក៏នីរទេសខ្លួនឯងទៅកាន់ប្រទេស ***ស្វីស*** និងរកសុំការធ្វើ ដោយឥតរើសថាជាមុខការដូចម្តេចឡើយ ។ ទីបំផុតរកការធ្វើពុំបានទាល់តែសោះ ហើយក៏ត្រូវធ្លាក់ខ្លួនទៅជាមនុស្សសុំទានគ្រាន់តែបានកំណាត់នំបុ័ងបន្តិចបន្តួច ដើម្បីបន្តជីវិតទៅទៀតប៉ុណ្ណោះ ដេកនៅតាមថ្នល់ តាមសំយាបផ្ទះ ឬក៏ក្រោមស្ពាន តាមតែដូចម្តេចអោយតែបានរស់នៅសិន ទីបំផុតក៏បានចូលទៅធ្វើការនៅក្នុងសារពត៌មានខាងពួកសង្គមនិយម (Socialist) ពុំដឹងជាសរសេររឿងទំនាស់អ្វី ក៏ស្រាប់តែត្រូវរដ្ឋាភិបាលស្វីស ចាប់ខ្លួនបញ្ជូនទៅប្រទេស ***អ៊ីតាលី*** វិញ ។

អ្នកសរសេររឿង ***មូស្សូលីនី*** បានវែកញែកថា គុណសម្បត្តិដែលនាំ ***មូស្សូលីនី*** ទៅកាន់ភាពជាធំបាននោះ គឺភាពជាអ្នកមាំទាំមិនព្រមចុះចាញ់ចំពោះការលំបាកតោកយ៉ាកក្នុងជីវិត និងប្រើពេលវេលាគ្រប់នាទីដែលមានសំរាប់សិក្សាអប់រំខ្លួនឯង ។ ព្រោះគ្មានឱកាសបានចូលទៅសិក្សា ក្នុងមហាវិទ្យាល័យដូចជនទាំងឡាយដទៃ ។ សេចក្តីព្យាយាមទាំងនេះឯងជាហេតុអោយ ***មូស្សូលីនី*** មានការចេះដឹង និងតែងអត្ថបទផ្សេងៗបានប្រសើរ ។ កាលត្រឡប់មកប្រទេស ***អ៊ីតាលី*** វិញ ក៏រកស៊ីចិញ្ចឹមជីវិតខាងធ្វើកាសែត ក្នុងតំណែងតាំងពីតូចបំផុត រហូតដល់ធំបំផុត និងបានជាម្ចាស់សារពត៌មានមួយដោយខ្លួនឯង ហើយក៏បានបក្សពួកច្រើនឡើងៗរហូតដល់ទីបំផុតក៏បានជាសមាជិកក្នុង ***រដ្ឋសភា*** ។


www.budinst.gov.kh www.elibraryofcambodia.org

***សង្គ្រាមលោកលើកទី១*** កន្លងទៅ ការគ្រប់គ្រងប្រទេស ***អ៊ីតាលី*** ច្របូកច្របល់វឹកវរក្រៃលែង ព្រោះរដ្ឋាភិបាលមិនអាចបង្ក្រាបពួក ***បូលហ្សេវិត*** (Bolchévic) និង ***កុម្មុយនិស្ត*** ដែលផ្សាយលទ្ធិ និងធ្វើការលំបាកអោយដល់ប្រទេស***អ៊ីតាលី*** ក្នុងវេលានោះយ៉ាងក្រៃលែង ។ គ.ស. ១៩២២ អាយុ៣៩ឆ្នាំ ***មូស្សូលីនី*** ឃើញថាគណៈរដ្ឋមន្ត្រីចាស់អស់សមត្ថភាពហើយ ទើបត្រៀមបក្សពួករបស់ខ្លួន ដើម្បីរំលំគណៈរដ្ឋាភិបាលចាស់ចេញ និងចូលកាន់កាប់កិច្ចការរដ្ឋ ដោយខ្លួនឯង ។គណរដ្ឋមន្ត្រីចាស់បាននាំរឿងនេះចូលក្រាបបង្គំទូលព្រះបាទ ***វិគទ័រ អេម៉ានុយអែល***(Victor Emmanuel) សុំអោយទ្រង់ឡាយព្រះហត្ថលេខា ជាព្រះបរមរាជឱង្ការថា : ***មូស្សូលីនីក្បត់*** ព្រោះបើបានព្រះបរមរាជឱង្ការនេះហើយ ក៏និងប្រើកម្លាំងទ័ពចាប់ខ្លួន ***មូស្សូលីនី*** និងបក្សពួក ។ តែព្រះបាទ ***វិគទ័រ អេម៉ានុយអែល*** ទ្រង់ព្រះតម្រិះវៃពុំព្រះសណ្តាប់ពាក្យទូលថ្វាយនោះ និងពុំទ្រង់ឡាយព្រះហត្ថលេខាលើសេចក្តីប្រកាសនោះ ។ គណៈរដ្ឋមន្ត្រីចាស់ក៏ត្រូវលាចេញ ។ ***មូស្សូលីនី*** និងពួករបស់ខ្លួនក៏ចូលជំនួសឡើង កិច្ចការរដ្ឋរបស់ប្រទេស***អ៊ីតាលី*** ក៏ប្រសើរឡើងមួយរំពេច លទ្ធិ ***បូលហ្សេវិត*** និង ***កុម្មុយនិស្ត*** ក៏ត្រូវបានបង្ក្រាបរាបទៅអស់ ។ ការគ្រប់គ្រងក៏ចាត់របៀបរៀបរយយ៉ាងប្រសើរ គ្រប់ក្រសួងរាជការនានា ក៏ធ្វើការយ៉ាងរៀបរយ និងប្រឹងប្រែងផ្ទុយស្រឡះពីកាលមុន***មូស្សូលីនី*** ឡើងកាន់ការ មានដំណាលថាមុន***មូស្សូលីនី*** ឡើងកាន់អំណាចនោះបើសិនជាអ្នកណាម្នាក់ ត្រូវការនិយាយទូរស័ព្ទ ទៅកាន់អ្នកដែលគេអាចដើរទៅដល់


www.budinst.gov.kh www.elibraryofcambodia.org

បាន ក្នុងវេលា២០នាទី ដើរទៅតែម្តងល្អជាងព្រោះក្រៅពីយឺត និងភ្ជាប់លេខអោយខុសៗ ហើយជួនកាលវេលាសុំតទូរស័ព្ទនោះបានឮសម្លេងនាងប្រចាំការ (Opératrice) នោះច្រៀងអោយស្តាប់ជំនួសការភ្ជាប់អោយតាមសុំ ។ តែនៅថ្ងៃដែល ***មូសូលីនី*** ឡើងកាន់អំណាចនោះ អំពើឧបទ្រពទាំងនោះ ក៏រលាយបាត់ទៅភ្លាម មានអ្នកគំនូរបារាំងម្នាក់ នៅសម័យនោះបានគូរជារូបប្រៀបធៀប ជាបន្ទប់ពីរ បន្ទប់មួយនិយាយពីភាពភ្នាក់ងាររាជការផ្សេងៗ ធ្វើការខ្លះដេកលក់ ខ្លះចង់ស្រី ពីកាលមុន ***មូសូលីនី*** ឡើងកាន់អំណាច ។ បន្ទប់មួយទៀតនិយាយពីភាពក្នុងពេលដែល ***មូសូលីនី*** ឡើងកាន់អំណាច ភ្នាក់ងាររាជការគ្រប់រូបប្រឹងប្រែងខ្មីឃ្មាត ក្នុងកិច្ចការយ៉ាងស្វាហាប់ ។

***មូសូលីនី*** ចូលដល់អវសាននៃជីវិត ដោយត្រូវដោតឆ្កាងដោយកងទ័ពសម្ពន្ធមិត្រ ក្នុង***សង្គ្រាមលោកលើកទី២*** ដោយបន្សល់ទុកនូវការអារម្មណ៍ដ៏សំខាន់ៗជាច្រើនដល់អ្នកសិក្សាប្រវត្តិសាស្ត្រ រហូតដល់សម័យនេះ ។

❊ ❊ ❊ ❊ ❊


www.budinst.gov.kh www.elibraryofcambodia.org

# អូ កូ បូ

# OKOBO

1830 - 1878

***អូ កូ បូ*** កើតពីថ្ងៃទី២៦ កញ្ញា ១៨៣០ ។ បើពោលពីការសិក្សាហើយ គ្មានអ្វីជាល័ក្ខឋានទេ ព្រោះ ***ប្រទេសជប៉ុន*** ក្នុងសម័យកាលជាង ១០០ឆ្នាំមកនេះ ឥតបានចាត់ការសិក្សាតាមរបៀប ***អឺរ៉ុប*** ទាល់តែសោះ ទាំង ***ប្រទេសជប៉ុន*** ក៏ត្រូវជនជាតិស្បែកសជិះជាន់រហូតដល់ទៅមានច្បាប់ ហាមមិនអោយជនជាតិ***ជប៉ុន*** ធ្វើការទាក់ទងនិងជនជាតិស្បែកសទៀតផង ។ ការសិក្សារបស់អូបូកូ ទើបប្រកាន់តែថាការសិក្សានៅផ្ទះស្តាប់តែមនុស្សធំនិយាយអោយស្តាប់ ពីកិច្ចការផែនដី ហើយកាលដល់ធំឡើង ខ្លួនឯងក៏មានមិត្តសំឡាញ់ពីបីនាក់ ដែលតែងតែមកជួបគ្នាសឹងតែរាល់ថ្ងៃ សន្ទនាជជែកអោយយោលគ្នាផ្សេងៗខួរក្បាលរបស់ ***អូ កូ បូ*** បានទទួលការអប់រំដោយវិធីនេះឯង ទើបខុសពី ***វីរបុរស រដ្ឋបុរស*** ឬ ***មហាបុរស***ដទៃទៀតជាច្រើនដែលសុទ្ធតែបានចូលមហាវិទ្យាល័យបានទទួលការសិក្សាយ៉ាងប្រសើរមកហើយ ។ បើទុកជាដូច្នោះ សេចក្តីឈ្លៀសវៃរបស់ ***អូ កូ បូ*** ក៏មិនចាញ់ពួកទាំងនោះឡើយ ។

ដោយអំណាច ការបានស្តាប់បានឮច្រើន ***អូ កូ បូ*** ទើបបានល័ក្ខឋានច្រើនប្រការ ជាគ្រឿងពិសោធន៍អោយរដ្ឋាភិបាលឃើញការអាក្រក់ទន់ខ្សោយរបស់ជនខ្លះៗ ក្នុងគណៈរដ្ឋាភិបាល ។ តមកអាយុ២៣ឆ្នាំ បានឱកាស



www.budinst.gov.kh www.elibraryofcambodia.org

ចូលគាត់ព្រះអង្គម្ចាស់ ***ណាវិអាគី*** ដែលកាន់អំណាចនៅ ***ប្រទេសជប៉ុន*** ក្នុងវេលានោះ ហើយក៏ស្នើខពិសោធន៍របស់ខ្លួន ដែលបានធ្វើមកជាយូរហើយ ដោយហេតុនេះឯង ***អូ កូ បូ*** ទើបបានទទួលតំណែងរាជការ ខាងក្រសួងហិរញ្ញវត្ថុ និងជាទីប្រោសប្រាណរបស់ព្រះអង្គម្ចាស់ ***ណាវិអាគី*** យ៉ាងក្រៃលែង ។ តែមានរឿងថា ***អូ កូ បូ*** ជាអ្នកមាននិស្ស័យរឹងប៉ឹងពេកទៅក្នុងពេលខ្លះ ទាល់តែព្រះអង្គម្ចាស់ ***ណាវិអាគី*** មានព្រះរាជឱង្ការពោលពី ***អូ កូ បូ*** ថា ***ជនប្រភេទនេះរកបានដោយលំបាក និងមានប្រយោជន៍បំផុត តែមានតែខ្ញុំម្នាក់ប៉ុណ្ណោះ ដែលចេះយកមនុស្សនេះទុកក្នុងកណ្តាប់ដៃបាន*** ។ អាយុ ៣០ឆ្នាំ ***អូ កូ បូ*** បានជាអធិការកិច្ចការឃ្លាំងប្រាក់ ។ អាយុ ៤២ឆ្នាំ បានជាភូឈ្មួយឯកអគ្គរាជទូតពិសេស ដែលបញ្ជូនជាផ្លូវការទៅកាន់ប្រទេស ***អង់គ្លេស បារាំង អាល្លឺម៉ាញ*** និង ***រុស្ស៊ី*** ហើយក៏ឆ្លៀតយកឱកាសនេះឯងសិក្សាយកវិជ្ជាថ្មីៗទៀតបានជាច្រើន ។ លុះត្រឡប់មក ***ប្រទេសជប៉ុន*** វិញ បានជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងអាយុ ៤៤ឆ្នាំ ។

***អូ កូ បូ*** ជា ***វីរជនជប៉ុន*** ដំបូងបំផុត ដែលជាអ្នកយល់ថា : ការដែលនឹងប្រជែងប្រណាំងនឹងជនជាតិ ***ស្បែកស*** បាននោះ ចាំបាច់ត្រូវរៀន តាមវិធីសិក្សារបស់ជនជាតិ ***ស្បែកស*** យកមកផ្លាស់ប្តូរកិច្ចការផែនដីរបស់ខ្លួន និងមិនគួររឹងរូសយកតែការច្បាំងជាត្រីមុខតែម្យ៉ាងតាមគំនិតរបស់ពួក ***សាមូរ៉ៃ*** (Samurai )ឡើយ ។ ហេតុនោះឯង រដ្ឋបាលនយោបាយរបស់ ***អូ កូ បូ*** ទើបងាកទៅរកផ្លូវដែលនឹងបើកការទាក់ទង ជាមួយជនជាតិ ***ស្បែកស*** អោយ


www.budinst.gov.kh www.elibraryofcambodia.org

បានច្រើនឡើងផ្ដើមធ្វើការកែប្រែសន្ធិសញ្ញានឹងប្រទេស ។ ស្ថាបនាផ្លូវរថភ្លើងរៀបចំក្រុមនគរបាលតាមបែបទំនើបផ្គត់ផ្គង់ខាងវប្បកម្ម តាំងសាលារៀនខាងកសិកម្ម និងពាណិជ្ជកម្ម កិច្ចការផ្សេងៗរបស់ ***អូ កូ បូ*** នេះញុំាងប្រយោជន៍ដ៏ធំមហិមាដល់ ***ប្រទេសជប៉ុន*** តែក៏រមែងមិនជាទីពេញចិត្តរបស់ជនជាតិ ***ជប៉ុន*** ដែលមិនត្រូវការយកតម្រាប់តាមជនជាតិស្បែកស ។ ដូច្នេះទើងមានគណៈបក្សពួកដែលធ្វើការតតាំងប្រឆាំងជំទាស់នយោបាយរបស់ ***អូ កូ បូ*** ។ តែ ***អូ កូ បូ*** បានទទួលការគាំទ្រពីព្រះមហាក្សត្រ ទើបអាចយកឈ្នះពួកបក្ស ដែលជំទាស់ចាត់ការស្ថាបនា ***ប្រទេសជប៉ុន*** អោយចូលបែបទំនើបរហូតមក ។ តែ ៥ឆ្នាំក្រោយពីបានជា ***នាយករដ្ឋមន្ត្រី*** អាយុ ៤៨ឆ្នាំ គ. ស. ១៨៧៨ ក៏ត្រូវជនពុំស្គាល់មុខលួចសម្លាប់កណ្ដាលផ្លូវថ្នល់ យ៉ាងគួរអោយអាណោចអធម្មក្រៃលែង ។ មរណភាពរបស់ ***អូ កូ បូ*** នាំមកនូវសេចក្ដីតក់ស្លុតដល់ព្រះរាជានៃ ***ប្រទេសជប៉ុន*** យ៉ាងលើសលប់ ។ ព្រះអង្គទ្រង់ជាអ្នកចាត់ចែងពិធីបញ្ចុះសព ***អូ កូ បូ*** ផ្ទាល់ព្រះអង្គឯង ។ រហូតមកទល់នឹងថ្ងៃមរណៈ ***អូ កូ បូ*** មានទ្រព្យសម្បត្តិសល់នៅតែត្រឹម ២០០យេនប៉ុណ្ណោះ ។ ***អូ កូ បូ*** ធ្លាប់បានទទួលព្រះរាជអំណោយដ៏ច្រើនពីព្រះមហាក្សត្រម្ដងដែរ តែគាត់ពុំបានយកទៅជាប្រយោជន៍ផ្ទាល់ខ្លួន បែរជាយកទៅទំនុកបំរុងសាលាវប្បកម្មទាំងអស់ទៅវិញ ។

បានសេចក្ដីថា ***អូ កូ បូ*** ទទួលមរណៈភាពទៅចោលគ្រួសារនៅក្រោមអំណាចនៃសេចក្ដីក្រខ្សត់ ខុសពីជនដទៃៗទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

# ផ្នែកទី ២



www.budinst.gov.kh www.elibraryofcambodia.org

# គុណសម្បត្តិ ៤០ ប្រការ

# THE FORTY QUALITIES

## ក្នុងផ្នែកទី១

យើងបានរៀនប្រវត្តិរបស់ ***មហាបុរស*** ១០រូបដោយបានដឹងហើយថា ជីវិតលោកទាំងនោះថ្លៃថ្លាយ៉ាងណាខ្លះ ។ អំពើរបស់លោក ជាប្រយោជន៍ដល់ពិភពលោក ពួកគណៈ និងខ្លួនលោកយ៉ាងណាខ្លះ ។ យើងនិយាយសរសើរលោកទាំងនោះ និងប្រាថ្នាចង់សាងខ្លួនរបស់យើងអោយបានទទួលកិត្តិនាម កិត្តិគុណ យ៉ាងហ្នឹងខ្លះ ។

ហេតុនេះ យើងចាំបាច់ត្រូវរៀនតទៅទៀតថា : តើលោកទាំងនោះមាន***<<ល្អ>>***យ៉ាងណា បដិបទារបស់លោកដូចម្ដេចខ្លះ ដើម្បីនឹងនាំយកមកប្រតិបត្តិតាម តាមដែលយើងបានលទ្ធភាពអាចធ្វើទៅបាន ។

មែនពិត អ្នកដែលបានសំរេចដល់ឋានៈដ៏ខ្ពង់ខ្ពស់នោះ មានខ្លះក៏ត្រូវអាស្រ័យនឹងគ្រឿង ***ឡោមព័ទ្ធ*** Surroundings or environment ជាគ្រឿងជួយផ្ដល់ផ្សំនិងការអប់រំដែលមានមកពីតូចផង ។ អ្នកតែងពង្សាវតារ ***វីរបុរស*** ឬ ***មហាបុរស*** គ្រប់រូប តែងពោលសរសើរមាតានៃលោកទាំងនោះ ដូចយ៉ាងមាតារបស់ ***ណាប៉ូឡេអុង*** ជាស្ត្រីក្លាហានដាច់ខាត មិនតក់ស្លុតចុះចាញ់ចំពោះអន្តរាយឡើយ ។ ពេលដែល ***ណាប៉ូឡេអុង*** នៅក្នុងផ្ទៃ មានកើតវិបត្តិ



www.budinst.gov.kh www.elibraryofcambodia.org

ចលាចលនៅក្នុងស្រុក ។ អ្នកស្រុកត្រូវនាំគ្នាភៀសខ្លួនទៅពួននៅព្រៃភ្នំ ដើម្បីអោយផុតភ័យ ។ មាតា**ណាប៉ូឡេអុង** ពរបងប្រុស**ណាប៉ូឡេអុង** ដែលទើបមានអាយុបានមួយខួបកន្លះជិះសេះ ទៅនិងពួកអ្នកស្រុកទាំងនោះដែរ ។ ក្នុងពេលដែលកំពុងទៅតាមផ្លូវនោះ ត្រូវលុយទឹកឆ្លងអូរមួយកន្លែង ទទួលសេះដែលមាតា**ណាប៉ូឡេអុង** ជិះនោះ ត្រូវទឹកហូរទាញទៅធ្លាក់ត្រង់អន្លង់ជ្រៅ ។ មនុស្សទាំងអស់គ្នាដែលទៅជាមួយ ហួសគំនិតនឹងជួយបាន ក៏នាំគ្នាស្រែកអោយម្ដាយ **ណាប៉ូឡេអុង** លែងសេះនោះចោល ហើយពរតែកូននោះហែលទៅរកច្រាំងយកតែខ្លួនរួចទៅ ។ តែមាតា **ណាប៉ូឡេអុង** នឹកដល់គុណរបស់សេះគូជីវិត ដែលបានទទួលការលំបាកត្រាំត្រែងមកជាមួយគ្នា មិនព្រមលែងចោលសុខចិត្តព្យាយាមនាំសេះហែលទៅទាល់តែដល់ច្រាំងរួចពីការស្លាប់ទាំងអស់គ្នា ។ រួមទាំង **ណាប៉ូឡេអុង** នៅក្នុងពោះផង ហេតុនេះឯង ដល់ជីវិត **ណាប៉ូឡេអុង** រុងរឿងហើយនោះ **ណាប៉ូឡេអុង** ពុំលះបង់ចោលមាតាឡើយ សូម្បីត្រូវបំបរបង់ទៅនៅកោះហើយក៏នៅតែយកមាតាទៅជាមួយផង បើគេបានរៀនច្បាប់ដែល **ណាប៉ូឡេអុង** រួបរួមឡើងក្នុងសម័យនោះ ។ និងឃើញបានថា លក្ខណៈដែលសំខាន់បំផុតក៏គឺការស្រឡាញ់គ្រួសារ ។ មាតារបស់រីហ្សិលីយ៉ឺ ជាបុត្រីមេធាវី តែងយកចិត្តទុកដាក់ខាងច្បាប់ទម្លាប់ ក៏អប់រំបុត្រអោយវាងវៃខាងច្បាប់ទម្លាប់នោះទៅ ។ មាតារបស់ **ជីស្រាអែលី** និង **មុស្សូលីនី** ទាំងអស់នេះក៏សុទ្ធតែប្រាកដថាជាស្ត្រីវាងវៃ ពោរពេញទៅដោយការព្យាយាម មិនដាក់ធុរៈហើយនិស្ស័យដ៏ប្រសើរនោះៗក៏ជាមតិក



www.budinst.gov.kh www.elibraryofcambodia.org

ចែកចាយដល់លោកទាំងនោះ ។

ប្រការមួយទៀត ***សេចក្តីក្រីក្រ*** នោះដោយពិតជារបស់ដែលគ្មាននរណាចង់បានទាល់តែសោះ ។ យើងចំណាយកម្លាំងកាយកម្លាំងចិត្តធ្វើការងារអស់មួយជីវិត ។ ក៏ដើម្បីកំចាត់សេចក្តីក្រីក្រនោះអោយផុតរលត់ទៅ ។ តែក៏សេចក្តីក្រីក្រនោះឯងជាហេតុអោយមនុស្សបាន <<***ល្អ***>>មកជាច្រើន ។ បណ្តាប្រវត្តិដែលយើងបានរៀនមកហើយក្នុងខាងដើមទាំង ១០ នាក់នោះ អ្នកដែលស៊ូយ៉ាងជោគជាំ និងការក្រីក្រ ***លេខ១*** គឺ ***មុស្សូលីនី*** ។ ក្រដល់កំណត់ទាល់តែសុំទានគេចំអែតពោះ ។ ***ណាប៉ូឡេអុង ជាទី២*** ត្រូវស្លៀកពាក់ខោអាវកញ្ចាស់រហែក រហូតដល់បានទទួលការមើលងាយសើចចំអកឡកឡឺយនៅសាលារៀន ដល់ពេលចេញពីសាលារៀនហើយ ត្រូវឈមមុខទល់នឹងសេចក្តីក្រីក្រដ៏ធំក្រៃលែងទៀត ព្រោះត្រូវបញ្ជូនប្រាក់ទៅចិញ្ចឹមមាតា និងបងប្អូនរួមផ្ទៃជាច្រើននាក់ទៀត ។ សៀវភៅលោក ***អាធួរ លេវិ*** ពោលថា <<***កាលណា ណាប៉ូឡេអុង ទៅលេងផ្ទះ ជនទាំងឡាយរីករាយក្រៃលែងតែអនិច្ចា ! បើសិនជាសេចក្តីក្រីក្រមិនចូលទៅសណ្ឋិតនៅក្នុងផ្ទះនោះផងទេ នោះសេចក្តីរីករាយនោះ និងទ្វេឡើងជាច្រើនគុណ***>> បិតា ***ណាប៉ូឡេអុង*** អនិច្ចកម្ម កាល ***ណាប៉ូឡេអុង*** ទើបអាយុ១៦ឆ្នាំ ចោលគ្រួសារអោយចំកណ្តាលនៃអនាថភាព ។ សំបុត្រដែល***ណាប៉ូឡេអុង*** សរសេរទៅអោយម្តាយ កាលដែលបានដំណឹងថា បិតាខ្លួនទទួលអនិច្ចកម្មនោះមានសេចក្តីថា :



www.budinst.gov.kh www.elibraryofcambodia.org

<<***សូមអោយរលត់ផុតចាក សេចក្តីសោកសៅទៅ លោកម្តាយជាទីស្រឡាញ់របស់កូន កូននឹងជឿ ស្តាប់ឱវាទរបស់អ្នកម្តាយ ហើយនឹងព្យាយាមទាល់តែអាចចិញ្ចឹមអ្នកម្តាយ ជំនួសលោកឪពុកដែលរំលងខន្ធទៅហើយ កូនសូមបញ្ចប់សំបុត្រត្រឹមប៉ុណោះ សេចក្តីទុក្ខធំ បង្គាប់អោយខ្ញុំជាកូនឈប់សរសេរ***>> ។

សូមលោកអ្នកអានជាទីគោរព អានផ្ទួន សំបុត្រ២-៣ បន្ទាត់នេះម្តងទៀត ហើយគិតដល់ពាក្យទាំងនោះ ដែលជាពាក្យរបស់យុវជនអាយុ ១៦ឆ្នាំ ការដែលយុវជនអាយុប៉ុណ្ណេះ មានការគិតបានដល់ថ្នាក់នេះ ក៏ព្រោះសេចក្តីទាល់ក្រ បង្គាប់អោយគិតជានិច្ច ។ ២០ឆ្នាំក្រោយមក ក្មេងនេះឯងជា ***មហាចក្រពត្តិ*** មានអំណាចបញ្ជាលើ***អឺរ៉ុប*** ជិតអស់ទាំងទ្វីប ។ ***ណាប៉ូឡេអុង*** ខ្លួនឯង កាលបានសំរេចជា ***អធិរាជ*** ហើយ មានព្រះបន្ទូលថា :

<<***សេចក្តីទាល់ក្រ ធ្វើអោយខ្ញុំធំរហ័សជាងអាយុ***>>

ដោយ ***ណាប៉ូឡេអុង*** គាត់ធ្លាប់តែសេចក្តីទាល់ក្រញាំញីមកហើយនោះ កាលបានជាធំឡើង ជាមនុស្សល្អិតល្អៀតចំពោះកិច្ចការសព្វសារពើ ទាំងក្នុងកងទ័ព ទាំងក្នុងកិច្ចការគ្រប់គ្រងផែនដី ។ ប្រទេសហៀបតែនឹងរលំទៅហើយពេលនោះ ***ណាប៉ូឡេអុង*** ដោះបំណុលអោយដល់ ***ប្រទេសបារាំង*** ធ្វើ ***ប្រទេសបារាំង*** អោយទៅជាមានវិញបាន ស្ថាបនា ***ថ្នល់ -ស្ពាន - កំពង់ផែ*** អស់ប្រាក់រាប់រយលានហ្វ្រង់ក៏ទាំងមានសល់ទុកនៅក្នុងឃ្លាំងទៀត ។ សៀវភៅ ***អាឡូរលេវី*** ពោលថា <<***ណាប៉ូឡេអុង លះបង់ប្រទេសបារាំង***


www.budinst.gov.kh www.elibraryofcambodia.org

*ទៅក្នុងឋានៈជាប្រទេសមានបំផុតក្នុងសម័យនោះ >>*

ជីវិតដ៏ជូរចត់របស់ ***ណាប៉ូឡេអុង*** ធ្វើអោយ ***ណាប៉ូឡេអុង*** ធ្វើការបានសព្វយ៉ាងហ្នឹង ដូចមានប្រាកដនៅក្នុងពាក្យរបស់គាត់ខ្លួនឯងថា ៖

***<<សំរាប់ការងារក្នុងកងទ័ពនោះ គ្មានអ្វីដែលខ្ញុំធ្វើពុំបាន បើគ្មាននរណាធ្វើ***

***រំសេវ ខ្ញុំធ្វើខ្លួនឯង ,***

***បើគ្មាននរណាធ្វើទីតាំងកាំភ្លើងធំ ខ្ញុំចេះធ្វើខ្លួនឯង,***

***បើគ្មាននរណាចេះចាក់ពុម្ពកាំភ្លើង ខ្ញុំក៏នឹងជាអ្នកចាក់ពុម្ពខ្លួនឯង>>*** ។

***វីហ្សីលីយ៉ី ជាអ្នកទី៣*** ដែលត្រូវចូលទៅបួសក្នុងវត្តនោះ ក៏ព្រោះសេចក្ដីទាល់ក្របង្គាប់ ។

***ឌីស្រាអែលី ជាអ្នកទី ៤*** និង ***កាលីលេ ជាអ្នកទី៥*** ។ ហើយ ៥ នាក់ទៀតនោះ បើទុកជាមិនថាក្រ ក៏មិនមែនមានយ៉ាងលើសលប់ដែរ ។

***ស៊ីម៉ុង បូលីវ៉ារ*** មានក៏ពិតតែក្រោយមកត្រូវរាជការរឹបអូសអស់ ។

***លេនីន*** ជាមនុស្សត្រូវបរបង់រកទីលំនៅពុំប្រាកដ ។

***ស៊ុន យ៉ាត់សេន*** ក៏ត្រូវនិរទេសខ្លួនឯងចោលទីលំនៅ ។ ល ។

ដូចពោលមកនេះ យើងទើបបានគិតម្យ៉ាងថា : តាមប្រក្រតី មនុស្សយើងត្រូវការរស់នៅដោយមិនបាច់ធ្វើអ្វី ទាល់តែមានការចាំបាច់ចូលមកបង្គាប់ទើបត្រូវធ្វើ ។ ជនអ្នកក្រីក្រមានការចាំបាច់ត្រូវរកស៊ីចិញ្ចឹមជីវិតត្រូវព្យាយាម ហើយសេចក្ដីព្យាយាមនោះឯងជាផលដ៏ធំដល់ខ្លួនក្នុងកាលជាខាង


www.budinst.gov.kh www.elibraryofcambodia.org

ក្រោយ ។ ចំណែកអ្នកដែលកើតមកមានសម្បូណ៌សប្បាយ មានអណ្តូងមាសប្រាក់នៅជុំវិញផ្ទះគ្មានការចាំបាច់ត្រូវធ្វើអ្វីឡើយ អង្គុយដេកស៊ីនៅព្រងើយរហូតដល់ស្លាប់តែម្តងក៏បាន ។ ហេតុនេះឯងអ្នកដែលកើតមកមានសម្បូណ៌ហើយ នៅព្យាយាមប្រកបសេចក្តីល្អតទៅទៀតនោះ ទើបមានតិចណាស់ ។

ប្រការមួយទៀត ការសិក្សាខាងផ្នែកអក្សរសាស្ត្រ ជាហេតុអោយមនុស្សមានខួរក្បាលស្រៀវស្រួច ជាងការសិក្សាដទៃៗមានយោបល់ត្រឹមត្រង់មានការគិតស្រឡះស្រឡំ ជាងអ្នកដែលមិនយកចិត្តទុកដាក់ចំពោះក្បួនតម្រា ។ កាលបើយើងបានអានប្រវត្តិនៃមនុស្សសំខាន់ទាំងក្នុងសៀវភៅនេះ និងដទៃទៀតនោះ និងអាចឃើញបានថា លោកទាំងនោះច្រើនបំផុតដែលសុទ្ធតែយកចិត្តទុកដាក់ខាងអក្សរសាស្ត្រ ។***ណាប៉ូឡេអុង ជីស្រាអែលី*** ជាដើមសុទ្ធតែជំនាញខាងអក្សរសាស្ត្រ ។ ***ណាប៉ូឡេអុង*** សិក្សាវិជ្ជាទាហានក៏ពិតតែក្រោយមកក៏យកចិត្តទុកដាក់ខាងអក្សរសាស្ត្រមិនតិចដែរ ។ យើងដឹងហើយថា គាត់ពុំមែនជាឈាមបារាំងទេ តែដូចម៉េចក៏គាត់អាចប្រើ ***ភាសាបារាំង*** បានត្រឹមត្រូវ មិនគឺមកពីការយកចិត្តទុកដាក់ខាងអក្សរសាស្ត្រឬ ? ***មុស្សូលីនី*** រៀនក្នុងសាលាតិចបំផុត តែការព្យាយាមអប់រំផ្ទាល់ខ្លួនរបស់គាត់ធ្វើខ្លួនរបស់គាត់ អោយទៅជាអ្នកកាសែតបានយ៉ាងប្រសើរ ។

ទីបំផុតនៅមាន ការចម្លែកមួយទៀតដែលបណ្តាលជីវិតរបស់មនុស្ស និងហេតុការណ៍ក្នុងលោកអោយប្រព្រឹត្តទៅផ្សេងៗរឿងនោះ គឺការ ***ចៃដន្យ*** កាលបើយើងសិក្សាប្រវត្តិរបស់ ***វីរបុរស*** ឬ ***មហាបុរស*** គ្រប់រូបដោយ



www.budinst.gov.kh www.elibraryofcambodia.org

ល្អិតល្អន់ហើយនឹងឃើញបានថា ***ការថៃដន្យ*** មានចំណែកចូលរួមក្នុងជីវិតលោកទាំងនោះច្រើនក្រៃលែង ។ ជាថៃដន្យធ្វើអោយលោកទាំងនោះឆក់យកឱកាស សាងខ្លួនឡើងកាន់ថ្នាក់ខ្ពស់បំផុតបាន ។

លោកអ្នកអានជាទីគោរព អាចនឹងតាំងបញ្ហាសួរថា ***នេះឯងឬជាគុណសម្បត្តិសំរាប់សាងខ្លួន ?*** យើងខ្ញុំឆ្លើយភ្លាមថា មិនមែនរឿងមាតា សេចក្តីទាល់ក្រ ការសិក្សា និងការថៃដន្យទាំង ៤ ប្រការនេះទេ ។ ទាំង ៤ នេះ គ្រាន់តែជាគ្រឿង***ឡោមព័ទ្ធ*** ចំណែកគុណសម្បត្តិពិតៗនោះ មិនទាន់ពោលដល់នៅឡើយ ។ ខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនាដោយចំពោះឬក៏ដោយអមបើបានសិក្សាដោយរៀនឬដោយស្តាប់គង់បានដឹងថា ធម៌របស់ព្រះពុទ្ធមួយកន្លែងហៅថា ***ចក្កធម៌ ៤ ប្រការ*** ដែលជាគ្រឿងនាំបុគ្គលទៅកាន់សេចក្តីចំរើនប្រដូចនឹងកង់រថយន្ត ។ ***ចក្កៈទាំង ៤*** នោះគឺ :

***១. បដិរូបទេសវាសៈ រស់នៅក្នុងប្រទេសដ៏សមគួរ***

***២. សប្បុរិសូបសំសេវៈ សេពគប់សប្បុរស***

***៣. អត្តសម្មាបណិធិ តាំងខ្លួនដោយប្រពៃ***

***៤. បុព្វេកតបុញ្ញតា ភាពជាអ្នកធ្វើល្អទុកពីកាលមុន*** ។

ទាំង ៤ ប្រការនេះ ប្រការ ១-២ និង ៤ គ្រាន់តែជាគ្រឿងឡោមព័ទ្ធខាងក្រៅ ។ ប្រកាដែលសំខាន់បំផុតនោះ គឺប្រការទី ៣ ***តាំងខ្លួនដោយប្រពៃ*** ដូច្នោះគុណសម្បត្តិដ៏សំខាន់ដែលនឹង ***សាងខ្លួនវីរៈបុរស*** ឬ ***មហាបុរស*** នោះក៏គឺនៅក្នុងខ្លួនរបស់ ***សាងខ្លួនវីរៈបុរស*** ឬ ***មហាបុរស*** នោះឯង មិនមែន


www.budinst.gov.kh www.elibraryofcambodia.org

គ្រឿងឡោមព័ទ្ធខាងក្រៅនោះទេ ។

យើងខ្ញុំបានពោលមកហើយក្នុងបញ្ញប្រយោគថាមនុស្សយើងដែលនឹង ***សាងខ្លួន*** អោយល្អពិតៗបាន ត្រូវមាន ***គុណសម្បត្តិ ៤០ ប្រការ*** ។ លោកអ្នកអានជាទីគោរព អាចនឹងយល់ឃើញថាលើសពីការពិត ។ តែលោកអ្នកអានជាទីគោរពអាចនឹងឃើញបានជាខាងក្រោយ ព្រោះគុណសម្បត្តិទាំង ៤០ ប្រការនេះ លោកអ្នកប្រាជ្ញទាំងឡាយ បានញែកធាតុយ៉ាងល្អិតល្អន់មកហើយ ។ តែបើសិនជាលោកអ្នកអានជាទីគោរព អាចញែករកឃើញតិចជាងទៅវិញនោះ ជាការប្រសើរលើសលប់ ព្រោះជាហេតុងាយនឹងប្រតិបត្តិ ។ លំដាប់មាតិកាបន្ទាប់ទៅនេះ យើងខ្ញុំបានផ្ទៀបស័ព្ទប្រែជា ***៣ភាសា*** គឺ ***ខ្មែរ អង់គ្លេស បារាំង*** ចំណែកពាក្យ ***ខ្មែរ*** នោះយើងខ្ញុំប្រើពាក្យ ***ខ្មែរ*** សុទ្ធៗ ស្ទើរទាំងអស់ ព្រោះពុំអាចរកពាក្យ បាលី សំស្ក្រឹត មកដាក់អោយបានល្អ ។ សូមទុកបន្សល់ធុរៈ កិច្ចបន្តិចនោះ ជាមតិក ខាងកិច្ចការដល់លោកអ្នកអានជាទីគោរពតទៅ ។ សូមលោកអ្នកអានជាទីគោរពធ្វើការចាំ និងចូលចិត្តចំពោះមាតិកានីមួយៗអោយបានជាក់ប្រាកដផង ទើបអាចជាផលដល់ខ្លួនបាន ។ បើពុំដូច្នោះទេ នឹងទៅជាការឥតប្រយោជន៍ ថែមទាំងជាហេតុអោយសាបរលាប <<***តម្រាសាងខ្លួនឯង***>> នេះទៀតផង ។

លំដាប់តទៅនេះ ជាគុណសម្បត្តិទាំង ៤០ ដែលលោកអ្នកត្រូវ ***ការសាងខ្លួនឯង*** គប្បីប្រតិបត្តិ ឬថាបណ្ដុះអោយកើតមានក្នុងខ្លួន ទើបនឹងបានជួបប្រទះនូវ <<***សំណាង***>> ដែលជាប្រាថ្នាជានិច្ចនោះៗបាន ។



www.budinst.gov.kh www.elibraryofcambodia.org

បណ្ដាគុណសម្បត្តិទាំងអស់នេះ យើងខ្ញុំចែកចេញជាពួកៗ មាន ***៧ពួក*** ដើម្បីជាការងាយចាំ និងតម្រូវទៅតាមពេលវេលា ដែលត្រូវប្រតិបត្តិ រួចហើយទើបមានអត្ថាធិប្បាយ ធ្វើការយល់ទំនាក់ទំនងអោយបានទូលំទូលាយតទៅទៀតចំពោះលេខរៀងយើងខ្ញុំដាក់រៀងពីមួយដល់សែសិប ។

ដូច្នេះ សូមលោកអ្នកអានជាទីគោរព ឧស្សាហ៍ចាំអោយជាក់នូវគោល ***គុណសម្បត្តិទាំង ៤០*** ដូចតទៅ :

## ពួកទី ១ ត្រូវប្រតិបត្តិចាប់ពីរលឹកពីដំណេក រហូតដល់ធ្វើការ

| ***ខ្មែរ*** | ***អង់គ្លេស*** | ***បារាំង*** |
|---|---|---|
| ១. អនាម័យ | Good-Health | Bonne santé |
| ២. ភាពជាអ្នកមិនភ្ញាក់ផ្អើល | Calmness | Tranquillité |
| ៣. ភាពជាអ្នកមានចិត្តរីករាយស្រស់ស្រាយ | Cheerfulness | Bonne humour |
| ៤. គោលបំណង | Aim | But |
| ៥. ភាពជាអ្នកមិនអស់សង្ឃឹម | Hopefulness | Bon Espoir |
| ៦. ការមិនតូញត្អូញចំពោះសេចក្ដីនឿយលំបាក | Energy | Energie |
| ៧. ភាពជាអ្នកមានចិត្តរឹងប៉ឹង | Strong-mindedness | Esprit fort |


www.budinst.gov.kh www.elibraryofcambodia.org

## ពួកទី ២ ត្រូវប្រតិបត្តិក្នុងវេលាកំពុងធ្វើការងារ

| | | |
|---|---|---|
| ៨. ភាពជាអ្នកទៀងត្រង់ចំពោះពេលវេលា | Exactitude | Exactitude |
| ៩. ភាពជាអ្នកម៉ាំទាំប្រឹងប្រែង | Activeness | Active |
| ១០. ការធ្វើការស្មើចុងស្មើដើម | Steadiness | Cinduite Rangée |
| ១១. សមាធិ | Concentration | Concentration |
| ១២. ក្លាហានមិនរួញរាក្នុងកាលធ្វើអ្វីមិនសំរេច | Courage | Courage |
| ១៣. ពិធីការ | Method | Méthode = Ordre |
| ១៤. ភាពជាអ្នកមានរបៀប | Orderliness | Bon Ordre |
| ១៥. ការត្រិះរិះ(ឧបនិជ្ឈាន) | Reflection | Reflexion |
| ១៦. ភាពជាអ្នកល្អិតល្អន់ | Thoroughness | Tout - entier |
| ១៧. ការរកហេតុផលត្រឹមត្រូវ (អនុមាន) | Right Reasoning | Bon Résonnement |
| ១៨. សេចក្តីវិនិច្ឆ័យត្រឹមត្រូវ | Good - Judgenent | Bon Jugenent |
| ១៩. ជំនឿក្នុងខ្លួនឯង | Self - Confidence | Auto Confiance ou sur de soi |
| ២០. សេចក្តីរហ័សរហែង | Rapidity | Rapidité |



www.budinst.gov.kh www.elibraryofcambodia.org

## ពួកទី ៣ ត្រូវប្រតិបត្តិ ក្នុងវេលាទំនេរ - ដើរលេង ឬ ត្រឡប់ពីកន្លែងធ្វើការមកវិញ

| | | |
|---|---|---|
| ២១. ការសង្កេត | Observation | Observation |
| ២២. សម្បជញ្ញៈ | Perception | Perception |

## ពួកទី ៤ ត្រូវប្រតិបត្តិ ក្នុងវេលាធ្វើការទាក់ទងនឹងជនដទៃ

| | | |
|---|---|---|
| ២៣. ការមិនរអែងរអា ចំពោះបុគ្គលដទៃ | Positiveness | Nature Positive |
| ២៤. ការធ្វើខ្លួនឲ្យជាទីគាប់ចិត្ត ដល់ជនដទៃ | Charming Personality | Charmante personalit |
| ២៥. ការដឹងកាលៈទេសៈ | Tact | Tact Ou Savoifiaire |
| ២៦. ការប្រយ័ត្នប្រយែង | Precaution | Trécautopm |
| ២៧. បដិភាណ(ការវៃ) | Intuition | Intuition |
| ២៨. ការពារខ្លួនឯង | Self Defence | Auto -défence |
| ២៩. ធ្វើឲ្យគេជឿជាក់បាន | Trustworthiness | Digne de confiance |
| ៣០. ការនិយាយតែសេចក្តីពិត | Truthfulness | Véracité |
| ៣១. ភាពជាអ្នកល្អ | Nobility | Noblesse |
| ៣២. ធ្វើខ្លួនអោយសមរម្យ និងកិត្តិយស | Dignity | Dignité |



www.budinst.gov.kh www.elibraryofcambodia.org

## ពួកទី ៥ ត្រូវប្រតិបត្តិ ក្នុងវេលានៅផ្ទះ

| | | | |
|---|---|---|---|
| ៣៣. | សេចក្តីចេះដឹង(វិជ្ជា) | Knowledge | Connaissance |
| ៣៤. | សេចក្តីចាំ (សតិ) | Memory | Mémoire |

## ពួកទី ៦ ត្រូវប្រតិបត្តិ ក្នុងវេលាដេកមុនលក់

| | | | |
|---|---|---|---|
| ៣៥. | ការហ្វឹកហាត់ខ្លួនឯង | Self Culture | Auto Culture |
| ៣៦. | មនោគតិ (មនោភាព) | Inmagination | Inagination |

## ពួកទី ៧ ត្រូវប្រតិបត្តិ ប្រកបនឹងគុណសម្បត្តិដទៃទាំងអស់

| | | | |
|---|---|---|---|
| ៣៧. | ការជួយខ្លួនឯង | Self Help | Efforts personnels |
| ៣៨. | ការឈ្នះខ្លួនឯង | Self control | Enpir sur soi-même |
| ៣៩. | ការមិនលះបង់ | | |
| | សេចក្តីព្យាយាម | Perseverance | Persévérance |
| ៤០. | មនោមយិទ្ធិ(ចិត្តានុភាព) | Will -power or Inflown | Pouvoir de volonté |

យើងខ្ញុំជឿថា លោកអ្នកអាន បានឃើញ និងចាំជាក់នូវគុណសម្បត្តិទាំង៤០ដែលបានចែកចេញជា ៧ពួក រៀងលំដាប់ពីលេខ ១ដល់ ៤០ ដូច្នេះតទៅនេះជាអត្ថាធិប្បាយយ៉ាងសង្ខេប ដែលធ្វើអោយលោកអ្នកអានយល់នូវទំនាក់ទំនងតាមលំដាប់ដូចតទៅ :


www.budinst.gov.kh www.elibraryofcambodia.org

## វេលាក្រោកពីព្រលឹម

១. ត្រូវរលឹកដល់អនាម័យដំបូងបំផុត ដើម្បីបណ្តុះកំឡាំងរាងកាយ និងដាស់ខ្លួនរបស់ខ្លួនអោយភ្ញាក់ពីដេកពេញលេញ(វិធីនេះមានចែងក្នុងសៀវភៅ មនោមយិទ្ធិ គ្រប់សព្វហើយ) ។

២. ត្រូវព្យាយាម ធ្វើចិត្តអោយស្ងប់ កុំអោយភ្ញាក់ផ្អើលឬអណ្តែតអណ្តូង និងអោយនឹកថា រហូតក្នុងមួយថ្ងៃនេះអាត្មាអញមានចិត្តរៀបរយនឹងធឹងប្រៀបដូចទឹកស្ងប់ឥតមានរលក ទោះបីមានហេតុការណ៍អ្វីកើតឡើងក៏ឥតមានព្រឺឡើយ ។

៣. ព្យាយាមធ្វើចិត្តអោយស្រស់ស្រាយ លះបង់មិនរើសយករឿងដែលនាំអោយសៅហ្មងចិត្តធ្វើអោយមួហ្មងចិត្តមកធ្វើជាអារម្មណ៍ ។

៤. មានគោលបំនងដ៏ស្រួចដូចជាចុងម្ជុល ដែលដោតចុះយ៉ាងចោះចំថា យើងនិងធ្វើនៅថ្ងៃនេះ ដើម្បីសំរេចដូចម្តេចសំរាប់ជីវិតរបស់យើង ។

៥. អោយមានសេចក្តីសង្ឃឹមដ៏ពេញលេញ ចំពោះកិច្ចការដែលធ្វើនោះ សូម្បីមានឧបសគ្គប្រភេទណាក៏ដោយ មករារាំងក៏មិនអស់សង្ឃឹមនិងមិនលះបង់ចោលដែរ ។

៦. តាំងចិត្តយ៉ាងមាំថា យើងមានគុណសម្បត្តិ និងមូលដ្ឋាន ជាគ្រឿងជំនួយខ្លួនយើង ***យើងពេញចិត្ត ហៅអោយគ្រោះអាក្រក់ ឬ ឧបសគ្គនានារៀបជាផ្លូវចូលមករកយើងចុះ យើងតទល់អោយវាចុះចាញ់បាត់បង់ទៅវិញ***



www.budinst.gov.kh www.elibraryofcambodia.org

***តាមលំដាប់លំដោយ*** ។ កាលបើធ្វើបានតាមទាំង ៦ ប្រការដូចពោលមកហើយនេះ យើងនឹងមានលក្ខណៈរឹងប៉ឹង មានគ្រឿងឧបករណ៍សំរាប់ដំណើរជីវិតបានរៀបរយក្នុងថ្ងៃនោះដែលជាគុណសម្បត្តិទី ***៧នៃពួកទី១*** ។

៨. ទៅដល់កន្លែងធ្វើការត្រូវតាមម៉ោងពេល

៩. ធ្វើខ្លួនជាអ្នកមាំទាំប្រឹងប្រែង ។

១០. ធ្វើការងារស្មើចុងស្មើដើមមិនចាប់នេះចោលនោះ ។

១១. ធ្វើរឿងអ្វីក៏ចុះចិត្តក្នុងរឿងនោះមិនសាត់អណ្តែត ។

១២. អ្វីដែលធ្វើទៅពុំសំរេច ក៏ពុំរួញរាព្យាយាមធ្វើទាល់តែបាន ។

១៣. ធ្វើការងារតាមក្បួនខ្នាត ពុំមែនធ្វើតាមតែបាន ។

១៤. មានរបៀបរៀបរយមិនរយីករយាក ។

១៥. ត្រិះរិះពិចារណា

១៦. មានភាពល្អិតល្អន់មិនស្រាលសេចក្តី

១៧. រាវរកហេតុផលដែលត្រឹមត្រូវ

១៨. ប្រើការពិនិត្យពិស្ច័យ ដែលជឿថាត្រឹមត្រូវ កាលបើធ្វើបានយ៉ាងនេះហើយ ក៏នឹងមានការជឿក្នុងខ្លួនឯង ប្រាសចាកការស្ទាក់ស្ទើរ (វិចិកិច្ឆា)ជាទី១៩ និងធ្វើការសំរេចដោយរហ័សពុំយឺតយូរជាទី ***២០នៃពួកទី ២*** ។

វេលាទំនេពីការងារ និងរវាងដើរតាមផ្លូវមកផ្ទះ ឆ្លៀតយកឱកាសនោះជាគ្រឿងពិនិត្យពិគ្រោះ សង្កេតវត្ថុសព្វយ៉ាង ដែលបានឃើញហើយ


www.budinst.gov.kh www.elibraryofcambodia.org

រំលងទៅជាទី ២១ ។ និងមានសម្បជញ្ញៈដឹងខ្លួន មិងបណ្តោយអោយចិត្ត អណ្តែតអណ្តូងជាទី២២ ។ នេះជាវិធីដែលប្រើពេលតិចបំផុតសំរាប់ធ្វើប្រយោជន៍អោយបានច្រើនបំផុត បាន***ជាពួកទី៣*** ។

កាលណាធ្វើការទាក់ទងនិងជនដទៃ ត្រូវព្យាយាមកុំរអែងខ្លាចជាទី ២៣ ព្រោះភាពនៃការរអែងខ្លាចជាគ្រឿងទម្លាយបង់នូវគុណសម្បត្តិដទៃទៀតទាំងអស់ ធ្វើអោយខ្លួនយើងក្លាយទៅជាផ្នែកខាងដកថយ (Negative) ហើយជនដែលយើងទាក់ទងនឹងក្លាយទៅជាផ្នែកខាងរក (Positive) គំរាមយើងអោយលះបង់ដោយអំណាចនៃដួងចិត្ត ដែលខ្លាំងជាងយើង (សូមអានក្នុងសៀវភៅមនោមយិទ្ធិ ដែលពោលពីការទាក់ទងនឹងអ្នកដទៃ) ។

២៤. ព្យាយាមធ្វើខ្លួនអោយជាទីពេញចិត្តគាប់ចិត្ត ចំពោះជនដែលយើងជួបទាក់ទង ។

២៥. គិតជាមុនអោយស្រេច មុននឹងនិយាយចេញទៅគ្រប់ៗមាត់ និងព្យាយាមនឹងទុកជាមុនថា អ្នកដែលស្តាប់ តើគេនឹងគិតដូចម្តេច ។

២៦. ប្រយ័ត្នប្រយែងមិនភាន់ជឿពាក្យសំដីរបស់មនុស្សដែលល្បួងអោយយើងភាន់ជឿ ។

២៧. មានបដិភាណ យល់ទាន់ថាអ្នកដែលនិយាយនឹងយើងនោះត្រូវការអ្វី ។

២៨. មិនចុះសម្រុងចំពោះរឿងដែលមិនគួរចុះសម្រុង ។

២៩. ធ្វើខ្លួនអោយបានជាទីជឿស្តាប់រាប់អានចំពោះគេ ។


www.budinst.gov.kh www.elibraryofcambodia.org

៣០. និយាយតែការពិត ។

៣១. មិនសំដែងអាការកិរិយាវាចាថោកទាប និង៣២ រក្សាកិត្តិយស

របស់ខ្លួនជានិច្ច ជា ***ពួកទី ៤*** ។

ពេលនៅផ្ទះ ចំណាយពេលស្វែងយកចំណេះ ទី៣៣ និងយកស្មារតីចង ចាំជាទី៣៤ អោយបានចំណេះវិជ្ជាលូតលាស់ឡើងរាល់ថ្ងៃជា ***ពួកទី ៥*** ។

វេលាចូលដេកមុននឹងលក់ អោយរំលឹកដល់កិច្ចការដែលបានធ្វើមក ហើយក្នុងមួយថ្ងៃនោះថា តើយើងបានធ្វើខុសអ្វីខ្លះ ។ ***គុណសម្បត្តិ*** ទាំង៣៤ ដែលពោលមកខាងដើមនេះ តើបានព្យាយាមធ្វើគ្រប់គ្រាន់ឬទេ តើយើងនៅខ្វះកន្លះខណាខ្លះ បើសិនជាថ្ងៃនោះ យើងបានជួបចរចារនឹងជនណា ក៏ព្យាយាមរំលឹកនឹកត្រួតមើលតាំងពីចាប់ផ្តើមរហូតដល់ចប់ ជាគុណសម្បត្តិតាំងពីខទី២៣ដល់៣២នោះ យើងខ្វះកន្លះក្នុងខណាខ្លះ ***សន្យាចំពោះខ្លួនយើងថា ថ្ងៃស្អែកនេះ យើងនឹងធ្វើអោយល្អជាងនោះ ជាទី៣៥ រួចហើយអោយបង្កើតមនោគតិឃើញហាក់ដូចថ្ងៃស្អែកហើយ ហើយយើងប្រសើរឡើងជាងថ្ងៃម្សិលជាច្រើន គិតយ៉ាងនេះរហូតដល់ដេកលក់*** ជាទី៣៦ ***ពួកទី៦*** ។

នៅ ***គុណសម្បត្តិ ៤***ប្រការទៀត ដែលចាំបាច់ត្រូវប្រើគ្រប់ពេលវេលាគឺត្រូវតាមចិត្តជួយខ្លួនឯង ទី៣៧ជានិច្ច ។ ពិតណាស់មនុស្សយើង ទោះក្នុងកិច្ចការរដ្ឋការ ឬក៏ក្នុងកិច្ចការដទៃៗគ្រប់បែប ត្រូវអាស្រ័យការជួយឧបត្ថម្ភពីអ្នកធំជាងជានិច្ច តែមុនដែលលោកអ្នកធំនោះតាមធម្មតានឹងជួយអ្នកណាមួយ លោកតែងតែពិនិត្យមើលមុនថា តើអ្នកនោះព្យាយាមជួយខ្លួនឯង



www.budinst.gov.kh www.elibraryofcambodia.org

ហើយឬនៅ ? បើលោកឃើញថា មានការប្រឹងប្រែងហើយ លោកទើបជួយជាបន្ថែមទៅទៀត ។ យើងខ្ញុំអាចពោលយ៉ាងពេញក្រប៉ោងមាត់ថា មនុស្សណាគ្មានការគិតជួយចំពោះខ្លួនឯងទេ ចាំតែពឹងអ្នកដទៃតែម្យ៉ាង នឹងគ្មានលោកអ្នកណាទទួលជួយឧបត្ថម្ភសោះឡើយ ព្រោះបើទុកជាជួយក៏ឥតប្រយោជន៍ ។ មនុស្សនោះឥតបានទទួលភាពរុងរឿងអ្វីឡើយ ពុំខុសអ្វីពីលើកសុខនអោយជិះឡាន ទីបំផុតអាចជាផលអាក្រក់ចំពោះលោកដែលជួយនោះទៀតផង ។ នៅមួយប្រការទៀត គឺការឈ្នះខ្លួនឯង ទី៣៨ មិនលះបង់ពីព្យាយាមក្នុងកិច្ចការ ដែលបានកំណត់គ្រោងការណ៍ទុករួចហើយ ទី៣៩ និងមនោមយិទ្ធិ ៤០ដូចមានពិស្តារនៅក្នុងសៀវភៅ ***មនោមយិទ្ធិ*** ស្រាប់ ។

អត្ថាធិប្បាយដែលធ្វើអោយមានទំនាក់ទំងមកប៉ុណ្ណេះនៅជាសេចក្ដីសង្ខេបដ៏ខ្លីបំផុត បើសិនជាអោយពិស្តារនោះលុះត្រាតែជាសៀវភៅច្រើនក្បាល ។ យើងខ្ញុំរៀបរាប់កាត់ដោយខ្លីៗល្មមអោយឃើញនូវគុណសម្បត្តិដែលត្រូវសាងខ្លួនឯង ដែលអស់លោកអ្នកអានមាន <<***មហាសំណាង***>> សុទ្ធតែមានគ្រប់ៗរូប ។ មែនពិត ***គុណសម្បត្តិ ៤០ប្រការ*** មើលទៅហាក់ដូចជាលើសអំពែកលើសកំឡាំងមនុស្ស និងធ្វើទៅបាន ។ តែមនុស្សដែលជា ***វីរៈបុរស*** ឬ ***មហាបុរស*** អាចយកមកប្រើបានយ៉ាងស្រណុក ដូចជារបស់នៅក្នុងក្តាប់ដៃ ហើយមុនស្សដែលអាចសាងខ្លួនឯង អោយឡើងកាន់ឧត្តមដ្ឋានបាននោះ ក៏គឺមនុស្សដែលមាន ***គុណសម្បត្តិ*** ប្រកបនៅជាមួយគ្រប់ចលនានៃឥរិយាបថ ហើយមិនធ្វើអ្វីដោយគ្មានគុណសម្បត្តិទាំងនេះជាគ្រឿងនាំផ្លូវ ដល់


www.budinst.gov.kh www.elibraryofcambodia.org

ទីបំផុតក៏បានជាម្ចាស់នៃ***គុណសម្បត្តិ ៤០ ប្រការ*** និងអាចនាំយក***គុណសម្បត្តិទាំង៤០ ប្រការ*** នេះមកប្រើបានជាខ្ញុំកំដររបស់ខ្លួន ។

លោកអ្នកអានជាទីគោរពអាចនឹងសួរថា តើ ***គុណសម្បត្តិ ទាំង៤០*** នេះ តើខណាខ្លះដែលសំខាន់បំផុត ។ យើងខ្ញុំសូមឆ្លើយថាដែលសំខាន់បំផុតតាមទស្សនៈរបស់យើងខ្ញុំនោះ មាន ៥ ប្រការគឺ

ប្រកាទី ៤ គោលបំណង Aim ; ប្រការទី ៧ ភាពជាអ្នកមានចិត្តរឹងប៉ឹង Strong Mindedness ; ប្រការទី ១១ សមាធិ Concentration ; ប្រការទី ១៩ ការជឿក្នុងខ្លួនឯង Self Confidence ; ប្រការទី ៤០ មនោមយិទ្ធិ Will power ។

ហេតុនេះ យើងខ្ញុំសូមធ្វើអត្ថាធិប្បាយចំពោះគុណសម្បត្តិដទៃទៀតនោះ លោកអ្នកអានជាទីគោរព អាចនឹងខិតខំស្រាវជ្រាវជ្រើសរើស ខណានីមួយម្តងមួយៗ ធ្វើជាសៀវភៅ ដើម្បីជាគ្រឿងបំផុលបំផុសអំណាចនៃដួងចិត្តក្នុងការសាងខ្លួននេះជាបន្ទាប់បន្តទៅទៀត ។

តទៅនេះជាសេចក្តីអធិប្បាយ ***គុណសម្បត្តិ*** ប្រការទី ៤.៧.១១.១៩ និង ៤០ ។

❊ ❊ ❊ ❊ ❊



www.budinst.gov.kh www.elibraryofcambodia.org

# ១. គោលបំណង AIM

ការដំណើរជីវិត របស់មនុស្ស ប្រៀបដូចការដើរផ្លូវឆ្ងាយ កន្តារៈដែលយើងត្រូវដឹងថានឹងទៅតាមផ្លូវណា ។ បើយើងចេញដើរទៅតាមយថាកម្ម ក៏មិនដឹងជាដល់ទីណាឡើយ ។ មនុស្សយើងបើពុំដឹងផ្លូវថាត្រូវការអ្វីក្នុងជីវិត គិតនឹងធ្វើអ្វីដែលសំខាន់ បំណងនិងអោយមានជីវិតបែបណា ដល់ពេលចាស់ជរា សោះឡើយនោះ ផ្លូវដែលដំណើរជីវិតក៏រវែក ចាប់យកអ្វីជាល័ក្ខឋានពិតប្រាកដ តែមួយក៏ពុំខាន ។

មនុស្សយើងកាលធំឡើង ជីវិតក៏រឹតតែកន្លងទៅដោយឆាប់រហ័ស ។ យើងឃើញហើយថាក្នុងរយៈវេលាតាំងតែពីដឹងក្តីរហូតដល់អាយុ ២០ឆ្នាំ ពេលវេលាកន្លងទៅយឺតៗប្រាកដហាក់ដូចជាជីវិតរបស់មនុស្សវែងយឺនយូរ គ្មានទីបំផុត ។ តែរំលងពីម្ភៃឆ្នាំឡើងទៅ ហាក់ដូចជាលឿនឡើងរាល់ថ្ងៃ ។ មនុស្សចាស់តែងប្រាប់យើងថា យប់ថ្ងៃកន្លងទៅរហ័សណាស់ ហាក់ដូចជាការយល់សប្តិ ។ មនុស្សដែលចាស់ហើយ តែងសោកស្តាយចំពោះយុវភាពដែលមិនអាចត្រឡប់មកទៀតបាន នាំគ្នាឃើញថាជីវិតមនុស្សក្នុងលោកនេះខ្លីណាស់ មិនធូនល្មមនឹងធ្វើអ្វីជាដុំកំភួនបានឡើយ ។ ខ្លះក៏តូចចិត្តក្នុងការដើរផ្លូវខុស ខ្លះក៏បានគិតថា បើសិនជាចាប់គោលការណ៍អ្វីអោយមាំទាំហើយប្រាកដជានឹងបានទទួលការចំរើនលូតលាស់ជាងនេះ ។ លោកអ្នកប្រាជ្ញទាំង


www.budinst.gov.kh www.elibraryofcambodia.org

ឡាយបានពិសោធន៍ឃើញថា ជីវិតរបស់មនុស្សយើងកន្លងទៅដោយទទេអស់ ១/៣ ដោយការចាប់នេះ ចាប់នោះមិនឆ្ពោះត្រង់ណា ។ កាលបើយល់ជាក់ច្បាស់យ៉ាងនេះហើយ ចាំបាច់ត្រូវតែសំរេចចិត្តឲ្យច្បាស់លាស់ពិតប្រាកដជ្រើសរើសវិធីណាតែមួយឲ្យមាំ ។

ដួងចិត្តរបស់មនុស្សមានអំណាចបណ្តាលអោយហេតុការណ៍ផ្សេងៗកើតមានឡើងបានតាមបំណងប្រាថ្នា ។ មនុស្សយើងអាចសំរេចផលគ្រប់ៗយ៉ាងដែលត្រូវការ ប្រសិនបើសេចក្តីត្រូវការនោះ ខ្លាំងក្លាគ្រប់គ្រាន់ ។ តែសេចក្តីត្រូវការពុំអាចខ្លាំងក្លាឡើងបាន ប្រសិនបើយើងមិនសំរេចចិត្តអោយដាច់ខាតថា យើងត្រូវការបំណងអ្វីដោយចោះចំ ។ មនុស្សដែលស្រវាស្រទេញចង់បានរបស់ណានីមួយជានិច្ច មានចិត្តខ្ជាប់ខ្ជួនក្នុងរបស់នោះតែមួយជានិច្ច ឱកាសក៏នឹងមានមកក្នុងថ្ងៃណាមួយអោយមានផ្លូវទៅកាន់ផលនោះដោយពុំដឹងខ្លួនក៏មាន ។ សេចក្តីពិតបែបនេះ នឹងលើកឧទាហរណ៍មកពិសោធន៍ប៉ុន្មានរយឧទាហរណ៍ក៏បាន ។ បើយើងជឿចំពោះគោលការណ៍នេះ យើងក៏គួរត្រិកត្រង់អោយត្រឹមត្រូវ ជ្រើសយកគោលដៅក្នុងជីវិតរបស់យើងណាមួយ អោយដឹងច្បាស់ថាយើងត្រូវការជាអ្វី ជាមេទ័ពដ៏ល្បីឈ្មោះជាទីបំផុត ឬ ជាអ្នកប្រាជ្ញដែលគេគោរពរាប់អានទាំងនគរ ឬ ជាមេធាវីដ៏ល្បីល្បាញមានប្រាក់ចំណូលរាប់ម៉ឺនក្នុងមួយថ្ងៃ ឬ ជាអ្នកជំនួញដែលមានអំណាចបណ្តាលអោយថ្លៃប្រាក់ក្នុងប្រទេសឡើងចុះបានតាមចិត្ត ឬ ជាជាងដ៏ល្បីឈ្មោះ គ្មានគូប្រជែង ឬ ជាពេទ្យដ៏ធំ មនុស្សនិយមបំផុតក្នុងប្រទេស ឬ


www.budinst.gov.kh www.elibraryofcambodia.org

ក៏ជាមន្ត្រីរដ្ឋការដ៏ល្អមានប្រវត្តិចុះក្នុងពង្សាវតារនៃប្រទេស ឬ ក៏ជាអ្នកវិទ្យាសាស្ត្រ អាចស្រាវជ្រាវរកអ្វីដែលគេរកពុំទាន់ឃើញ ឬក៏ជាអ្នកនិពន្ធមានឈ្មោះបោះសម្លេងរហូតកប្បកាល ឬក៏ជាអ្នកសារពត៌មានដែលមានអំណាចត្រឡប់ផែនដីធ្វើឲ្យកិច្ចការរដ្ឋប្រែប្រួលទៅតាមសម្លេងចាំកការរបស់ខ្លួន ។ល ។ កាលបើបានជ្រើសរើសយកផ្លូវណាមួយហើយ ត្រូវមានសេចក្តីត្រូវការយ៉ាងខ្លាំងក្លាក្នុងផ្លូវនោះ បំណងនឹងអោយបន្លុះផលនោះតែម្យ៉ាង ។ បើការប៉ងប្រាថ្នារបស់យើងប្រព្រឹត្តតាមផ្លូវដែលល្អហើយ ក៏នឹងបន្លុះដល់ផលនោះនៅថ្ងៃណាមួយដោយពិត ។

<<***គោលបំណង***>> ដូចពោលមកនេះប្រៀបដូចជាការបាញ់កាំភ្លើងដើម្បីអោយត្រូវស៊ីបដែលនៅក្នុងរយៈឆ្ងាយ ។ អ្នកបាញ់ត្រូវប្រកាន់លក្ខខណ្ឌពីរប្រការ គឺ ១ តាំងចិត្តអោយត្រូវចំកណ្តាលស៊ី និង ២ តម្រង់ចុងកាំភ្លើងអោយងើយបន្តិច ព្រោះក្នុងរយៈឆ្ងាយនោះគ្រាប់អាចរត់ទាបចុះបាន យ៉ាងណាមិញ ***គោលបំណង***របស់មនុស្សយើងក៏ដូច្នោះដែរ ១. ត្រូវប៉ងតែទៅលើទីដៅដែលយើងត្រូវការនោះតែម្យ៉ាង និង ២. ត្រូវប៉ងអោយខ្ពស់បន្តិច ដូចជាយើងត្រូវការជាអ្នកនិពន្ធអោយបានកេរ្តិ៍ឈ្មោះដូចលោកភិរម្យភាសាអ៊ូ ឬសុតន្តប្រីជា ឥន្ទ ។ យើងត្រូវប៉ងអោយខ្ពស់ជាងលោកភិរម្យភាសា ឬ សុតន្តប្រីជា ព្រោះសេចក្តីព្យាយាមរបស់មនុស្សយើង កាលធ្វើយូរទៅអាចថយចុះមកទាបខ្លះ ដូចគ្នានឹងការបាញ់កាំភ្លើងតម្រង់ស៊ីដែលនៅឆ្ងាយដូច្នោះ ។***ណាប៉ូឡេអុង*** ជាជនម្នាក់ដែលយល់នូវលក្ខខណ្ឌនេះយ៉ាងល្អ ពោលគឺគាត់មានសេចក្តីប្រាថ្នាអោយបានជាមេទ័ពដែលល្បីឈ្មោះជាទីបំផុតក្នុងលោក ។


www.budinst.gov.kh www.elibraryofcambodia.org

គាត់ត្រូវការជាម្ចាស់លើ ***ទ្វីបអឺរ៉ុប*** ទាំងមូលតែគាត់ក៏ដឹងថា ជាម្ចាស់អស់ទាំងទ្វីបពុំបានទេ ព្រោះតង់នឹងមានប្រទេសណាមួយគាត់បង្ក្រាបពុំបានដែរ ។ តែបើទុកជាដូច្នោះក៏នៅតែតាំងគោលបំណងទុកថា ជាម្ចាស់ ***ទ្វីបអឺរ៉ុប*** ទាំងមូលដែរ ហើយផលដែលគាត់បានក៏គឺហៀបតែនឹងបានជាម្ចាស់ ***ទ្វីបអឺរ៉ុប*** ទាំងទ្វីបមែន ដែលពុំអាចបានជាម្ចាស់ទាំងអស់នេះ ក៏ព្រោះផលដែលបានទទួលអំពីសេចក្ដីព្យាយាមនោះថយចុះទៅដូចជាគ្រាប់កាំភ្លើងដូច្នោះ ។

លោកប្រដៅទុកមួយបែបទៀតថា អោយយើងធ្វើគ្រឿងសំគាល់ណាមួយទុកលើកន្លែងដែលយើងអាចឃើញបានរាល់ថ្ងៃ ដូចកត់ទុកលើក្រដាស់បិតលើតុ ឬក៏ធ្វើត្រាវាយលើសៀវភៅ ឬវត្ថុដែលជាកម្មសិទ្ធិរបស់យើង គ្រឿងសំគាល់នោះជាចម្លាក់ក្បាច់ក្បូរ យ៉ាងណាក៏បាន គ្រាន់តែជាហេតុអោយយើងនឹកឃើញបាន កាលបើយើងក្រឡេកឃើញដ៏ដឹងថាជាសញ្ញានៃគោលបំណងរបស់យើង ។តែយើងឥតប្រាប់អោយនរណាដឹងឡើយ ។

អ្នកដែលបានបន្លុះដល់ឋានៈដ៏ខ្ពង់ខ្ពស់ រហូតដល់ ***វីរៈ ឬ មហាបុរស*** នោះ ដូចពោលមកពីខាងដើមនេះ សុទ្ធតែមានគោលបំណងតែមួយ និងឧទ្ទិសជីវិតទាំងមូល ដើម្បីធ្វើការអោយប្រព្រឹត្តទៅតាមគោលបំណងនោះ ។

***វីហ្សេលីយើ*** មានគោលបំណងតែម្យ៉ាង ដើម្បីអោយបានទទួលកិត្តិគុណថា ជាអ្នកស្ដារអំណាចព្រះរាជវង្ស ***ប៊ួរបុង*** (Bourbon) អោយខ្ពង់ខ្ពស់ឡើង ។ ***ណាប៉ូឡេអុង*** មានគោលបំណងតែម្យ៉ាងដើម្បីជាម្ចាស់ ***ទ្វីបអឺរ៉ុប*** ។ ***ស៊ីម៉ុងបូលីវ៉ារ*** បំណងតែម្យ៉ាងដើម្បីរំដោះ ***អាមេរិកខាងត្បូង*** ។ ***ប៊ីសមារក៍***


www.budinst.gov.kh www.elibraryofcambodia.org

បំណាងតែម្យ៉ាង ដើម្បីរួបរួមប្រទេស ***អាល្លឺម៉ាញ*** ។ ***ស៊ុន យ៉ាត់សេន*** បំណាងតែម្យ៉ាង ដើម្បី ***ប្រជាជាតិចិន***។ល។ ក្នុងបណ្ដាជនសំខាន់ៗ ដែលមានប្រវត្តិក្នុងខាងដើមនេះ សុទ្ធតែមានការស្មោះត្រង់ចំពោះគោលបំណងរបស់ខ្លួន ហើយក៏អាចបន្ទុះដល់ផលនៃគោលបំណងនោះពិតៗ ។

លោកអ្នកអានជាទីគោរព អាចនឹងចោទជាសំនួរថា ៖ បើគោលបំណងជាហេតុអោយសំរេចផលសព្វយ៉ាងតាមប្រាថ្នាមែន ដូចម្ដេចក៏ស្ទូមម្នាក់ មានបំណងជាមហាសេដ្ឋីតែទៅជាមិនបាន ហើយយាយប៉ាតគាត់វិញឆ្នោតជាតិរាល់លើកឥតខាន ថែមទាំងទៅបន់ស្រន់ព្រះដងកើទៀត សុំអោយត្រូវរង្វាន់ទី១ ។ តែសូម្បីរង្វាន់ ១០០៛ ក៏មិនត្រូវផង ។ លោកអ៊ុំម្នាក់នោះចង់បានផ្កាយមួយ យកដាក់ក្បែរផ្ទះដើម្បីលក់ពន្លឺភ្លើងផ្កាយនោះ ប្រមូលប្រាក់ធ្វើជាសេដ្ឋីផ្ដួលក្រុមហ៊ុនអគ្គិសនី ចោលតែដូចម្ដេចក៏គាត់ទាំងនេះមិនសំរេច ។ យើងខ្ញុំសូមឆ្លើយថា ***គោលបំណង*** ក្នុងសៀវភៅនេះ មានលក្ខណៈខុសគ្នាឆ្ងាយណាស់ពីរឿងគិត <<***សម្បត្តិផ្ដួលលីលា***>> គោលបំណងដែលជាហេតុអោយបណ្ដុះផលដែលត្រូវការនោះ មានល័ក្ខខ័ណ្ឌ ២ យ៉ាង គឺ

១. ត្រូវជាគោលបំណង ដែលខ្លួនជឿជាក់ប្រាកដថា អាចនឹងទៅរួចផង ។

២. ការដែលអាចប្រព្រឹត្តទៅរួចបាននោះ ត្រូវអាស្រ័យខ្លួនរបស់ផងខ្លួនផង ។ ជនដែលគិតសម្បត្តិផ្ដួលលីលាដូចលោកអ៊ុំម្នាក់ខាងលើនេះ គេក៏នឹងថាវាមិនអាចទៅរួចដែរ ។ គោលបំណងរបស់ស្ទូម



www.budinst.gov.kh www.elibraryofcambodia.org

ឬឃាយប៉ាតនោះ សូម្បីអាចនឹងសំរេចខ្លះក៏ពុំមែនអាស្រ័យខ្លួនរបស់ផងខ្លួនទេ គឺអាស្រ័យលើអ្នកដទៃធ្វើអោយ ឬក៏អាស្រ័យគ្រឿងបង្វិលលេខ វិលទៅចំលេខឆ្នោតរបស់គាត់ ។ ដូចនេះ ***គោលបំណង*** របស់ជនប្រភេទនេះទើបជាការគិត<< ***សម្បត្តិឆ្កួតលីលា*** >> មិនមែន<< ***គោលបំណង*** >>ដែលបរិយាយក្នុងសៀវភៅនេះទេ ។ ព្រោះហេតុនោះ បើលោកអ្នកអានជាទីគោរពជឿតាមដូចយើងខ្ញុំពោលមកហើយ ហើយប៉ងនឹងតាំងគោលបំណងណានីមួយ ត្រូវប្រកាន់យកលក្ខខណ្ឌ ២ ប្រការ គឺ :

***១. ជារបស់ដែលអាចទៅបាន***

***២. ត្រូវអាស្រ័យលើខ្លួនរបស់ផងខ្លួន*** ។

លោកមានប្រដៅទុកមួយបែបទៀតថា នៅក្នុងវិជ្ជាជីវៈសព្វយ៉ាង ទោះជាអ្នករដ្ឋការក្តី ជាភ្នាក់ងារឬលេខាធិការ នៅក្នុងហាងជំនួញឬក្រុមហ៊ុនណានីមួយក្តី យើងត្រូវដឹកលំមនុស្សពីរនាក់ ដែលមាននៅចំពោះមុខយើង មនុស្សម្នាក់ជាអ្នកមានឋានៈខ្ពស់ជាងយើងដោយច្រើន ហើយដែលយើងគោរពរាប់អានថា ជាមនុស្សអង់អាចឈ្លៀសវៃឆ្លាតជាង យើងបំផុត ហើយមនុស្សម្នាក់ទៀតជាអ្នកមានឋានៈខ្ពស់ជាងយើងមួយកំរិត មនុស្សដែលឋានៈខ្ពស់ជាងយើង ដោយច្រើននោះយើងដម្កល់ទុកសំរាប់ជាតួយ៉ាង ព្យាយាមប្រតិបត្តិអោយបានដូចព្យាយាមយកតម្រាប់តាំងតែពីកាយវិការ ការនិយាយស្តី ដំណើរអង្គុយគ្រប់យ៉ាង ហើយមនុស្សម្នាក់ទៀត ដែលមានឋានៈខ្ពស់ជាង



www.budinst.gov.kh www.elibraryofcambodia.org

យើងមួយកំរិតនោះ យើងដម្កល់ទុក សំរាប់ប្រកួតអោយបានស្មើរ ឬខ្ពស់ជាង (*តែប្រយ័ត្នកុំឆ្លោយអោយគេដឹងខ្លួន*) នេះជាវិធីល្អបំផុតសំរាប់អោយកើត ***មនោមយិទ្ធិ*** និងពង្រឹងព្យាយាមធ្វើខ្លួនរបស់យើងអោយបានល្អជាងជននោះ កាលបើយើងដេញទាន់ជនដែលយើងដម្កល់ទុកសំរាប់ប្រកួតនោះហើយ យើងក៏ដម្កល់ជនដទៃទៀតសំរាប់ប្រកួតតទៅទៀត ។

វិធីនេះមិនមែនរបស់ថ្មីទេ សូម្បីក្នុងពុទ្ធសាសនាយើងក៏មានពុទ្ធភាសិតមួយគាថា ចែងមកហើយក្នុងគម្ពីរធម្មបទដ្ឋកថាថា :

***អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ***

***អពលស្សំវ សីឃស្សោ ហិត្វា យាតិសុមេធសោ***

បើប្រែអោយងាយៗមិនរក្សាសម្ពស្សភាសាបាលីពេកនោះ បានសេចក្តីថា :***កាលបើជនទាំងឡាយកំពុងភ្លេចខ្លួន យើងគប្បីមានស្មារតីមាំទាំ កាលបើជនទាំងឡាយកំពុងដេកលក់ (ស្រវឹង) យើងត្រូវភ្ញាក់រលឹកជានិច្ច អ្នកមានប្រាជ្ញតែងដើរហួសជនល្ងង់ខ្លៅបាន ដូចសេះដែលមានកម្លាំងច្រើន តែងជាយចោលសេះដែលខ្សោយដូច្នោះ*** ។

ពិតណាស់ អ្នកដែលជា ***វិរបុរស*** ឬ ***មហាបុរស*** នោះ តែងតែប្រើវិធីប្រកួតគ្នា និងយកតំរាប់គ្នាប្រជែងគ្នាដូច្នេះជានិច្ច ។

ក្នុងសៀវភៅ Self Help (***ជួយខ្លួនឯង***) [១] របស់អ្នកនិពន្ធ ***សាមូអែល-ស្មែល៍*** (Samuel smile) ដែលជាសៀវភៅ ដ៏ល្បីល្បាញមួយក្នុងលោកដែរ

---

(១) សៀវភៅនេះ យើងខ្ញុំបានតាំងចិត្តថា និងប្រែរៀបរៀងជាបន្តទៅទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

នោះ បានពោលទុកពីរឿងយកតំរាប់ជាតួយ៉ាងនោះ ថាជាគ្រូដ៏សំខាន់បំផុតមួយ ទុកណាជាបង្រៀនដោយមិនបាច់ប្រើអណ្តាតក៏ដោយ ក៏ជាសាលារៀនសំរាប់មនុស្ស ធ្វើការដោយទំរើ ដែលមានអំណាចក្រៃលែងជាងធ្វើដោយមាត់ ។ ពាក្យណែនាំដែលល្អដោះ រមែងមានទម្ងន់ តែថាគ្មានឧទាហរណ៍ល្អអោយមើលឃើញផងឡើយនោះ ពាក្យណែនាំនោះក៏ថយតម្លៃចុះ ហើយក៏ក្លាយទៅជាទំរៀមដែលពោលជាទូទៅថា ***ចូរធ្វើតាមដែលខ្ញុំនិយាយកុំធ្វើតាមដែលខ្ញុំធ្វើ*** ។

តាមដែលអធិប្បាយមកនេះ អាចឃើញបានច្បាស់ថា " ***គោលបំណង*** " ជាវត្ថុដែលសំខាន់ក្នុងជីវិតមនុស្ស និងចាំបាច់ដែលមនុស្សត្រូវតែមាន ។ ជីវិតដែលប្រាសចាក ***គោលបំណង*** (Aimless life) នោះគឺជីវិតដែលគ្មានតម្លៃ ។ ជនដែលអាចធ្វើអត្តឃាដកម្មបានក៏គឺជនដែលអស់មានគោលបំណងអ្វីក្នុងជីវិត ។ តែគោលបំណងនេះត្រូវមានតែមួយ បើមានលើរពីមួយ ក៏ប្រើការពុំកើតដែរ ហើយពិសេសទៅទៀត ត្រូវបំងចំពោះវត្ថុដែលខ្លួនជឿថាអាចនឹងទៅរួចផង ហើយការដែលអាចនឹងទៅរួចបាននោះ ត្រូវទៅតាមសមត្ថភាពផ្ទាល់របស់ខ្លួន មិនមែនចាំតែពឹងអ្នកដទៃឬវត្ថុអ្វីៗក្រៅពីខ្លួនរបស់ខ្លួននោះទេ ។

បើយើងជឿ និងជ្រះថ្លា តាមវិធីដូចពោលមកនេះហើយ យើងក៏គួរត្រិកត្រង់រកគោលដៅនៃជីវិតរបស់យើងអោយប្រាកដប្រជា ចាប់ពីពេលនេះតទៅ សរសេរទុកក្នុងទីណាមួយ ហើយរក្សាទុកជាអាថ៌កំបាំង ឬ បើ



www.budinst.gov.kh www.elibraryofcambodia.org

សរសេរទុកកណ្ដាលវាល ត្រូវធ្វើជាគ្រឿងសំគាល់អ្វីមួយដែលគ្មាននរណា អាចដឹងបានក្រៅពីខ្លួនយើង ។

" ***គោលបំណងនេះ*** " ក្នុងប្រវត្តិសាកលលោកមានត្រាទុកនូវសំដីមួយរបស់មេទ័ព ***រោម៉ាំង*** ម្នាក់ឈ្មោះ Julius César ***ហ្សូលី យុសសេសារ*** នៅពេលដែលគាត់ដើរទៅកាន់ភូមិតូចមួយ បាននិយាយទៅកាន់អ្នករួមដំណើរជាមួយថា " ***បើខ្ញុំមិនបានជាទី ១ ក្នុងក្រុងរោមទេ ខ្ញុំសុខចិត្តជាទី ១ ក្នុងភូមិដ៏តូចនេះ*** " នេះគឺជាទឡ្ហីករណ៍សំរាប់ពាក្យថា ***គោលបំណង*** ។

នេះជាកូនសោទី ១ សំរាប់ " ***សំណាងរបស់ខ្លួន*** " ។

❊ ❊ ❊ ❊ ❊



www.budinst.gov.kh www.elibraryofcambodia.org

# ២. ភាពជាអ្នកមានចិត្តរឹងប៉ឹង

## STRONG MINDEDNESS

គុណសម្បត្តិដ៏សំខាន់បំផុតក្នុងខ្លួន ***វីរបុរស*** ឬ ***មហាបុរស*** ក៏គឺភាពជាអ្នកមានចិត្តរឹងប៉ឹង ។ តែមនុស្សដោយច្រើន តែងយល់ខុសចំពោះអត្ថន័យនៃគុណសម្បត្តិខនេះ ដោយយល់ច្រឡំទៅភាពក្បាលរឹង ដែលជារបស់ថោកទាប ។ ក្មេងខ្លះ ឬអ្នកតូចខ្លះយល់ខុសរហូតដល់បង្អាប់ប្រព្រឹត្តរឹងថ្អឹងចំពោះអ្នកធំ ខ្លះរហូតដល់ទៅហ៊ានអួតអាងថា អាចធ្វើអោយអ្នកធំក្រែងខ្លាច ដូចជាថា <<***ថ្ងៃនេះផ្ចាញ់លោកនាយទាល់តែហារមាត់ពុំរួច***>>ជាពាក្យដែលយើងតែងបានឮជាញយៗដោយអ្នកនិយាយនេះយល់ថា អ្នកស្តាប់ នឹងនិយមឃើញថា ខ្លួនជាអ្នកពូកែ ។ ការពិត ជាសេចក្តីល្ងង់ខ្លៅមិនយល់ការ ។ ជនបែបនេះមានតែនាំហាយនៈភាពមកដាក់ខ្លួន គ្មានសមគួរនឹងបានទទួលការនិយមសរសើរដោយប្រការណាមួយឡើយ ។

សេចក្តីអធិប្បាយចំពោះខនេះ សង្ខេបបំផុត តែចូលចិត្តងាយបំផុត និងត្រឹមត្រូវបំផុតថា <<***រឹងប៉ឹង***>> តែកុំរឹងថ្អឹង ***ទន់ភ្លន់*** តែកុំទន់ខ្សោយ ។

ជនដែលមាំទាំរឹងប៉ឹង តែងតែជាអ្នកទន់ភ្លន់ តែមិនមែនទន់ខ្សោយទេ ។ ***វីរបុរស - មហាបុរស*** រាល់រូបដូចមានប្រវត្តិខាងដើមនេះ សុទ្ធតែជាអ្នក



www.budinst.gov.kh www.elibraryofcambodia.org

មានលក្ខណៈមាំទាំ ធ្វើការដាច់ខាត ។ តែគោរពលំទោន ចំពោះអ្នកធំជាង និងទន់ភ្លន់មានមេត្តាករុណាចំពោះអ្នកតូច ។ ***ណាប៉ូឡេអុង*** ដែលជាមេទ័ពដ៏ក្លាហាន ជា***អធិរាជ*** ដ៏ធំ ប្រាកដថាជាអ្នកទន់ភ្លន់ ស្រឡាញ់បុត្រភរិយាញាតិសន្តានបងប្អូន និងជននៅក្រោមបង្គាប់ ។ បើចំពោះមុខស្ត្រីភេទទៀត គាត់រឹងរឹតតែទន់ភ្លន់ឱនលំទោន ស៊ឹងតែមិនគួរជឿថា ជាមេទ័ពដែលហ៊ានសម្លាប់មនុស្ស ទាំងម៉ឺនទាំងសែនសោះឡើយ ។ រឿងពិស្តាររបស់គាត់ថា សូម្បី ***ណាប៉ូឡេអុង*** ធ្វើដំណើរចេញពីដំណាក់គាត់ ទៅកាន់ដំណាក់មហេសី ឬទៅទីណាក៏ដោយ បើបានជួបអ្នកណាម្នាក់ សូម្បីអ្នកបំរើដ៏តូចតាច ក៏ដោយក៏គាត់ឱនក្បាលបន្តិចអោយជានិច្ចមិនធ្លាប់ប្រើជនណាឬទទួលអ្វីពីជនណាដោយមិនចេញវាចាថា អគុណ ទាល់តែសោះ មានសុភាសិតថា<<The bravest is tenderest , the noblest is humblest >> << ***អ្នកដែលក្លាហានបំផុតតែងទន់ភ្លន់បំផុត , អ្នកដែលល្អបំផុត តែងរាបសារបំផុត*** >> ។

ជនដែលមានចិត្តរឹងប៉ឹងនោះ តែងតែមិនឆេវឆាវ ឬ ក្រោធខឹងងាយទេ ។ ជនដែលក្រោធខឹងងាយ គឺជនដែលទន់ខ្សោយមិនអាចបង្គាប់របស់ខ្លួនបានឡើយ ។ ម្យ៉ាងទៀតជនដែល ***រឹងប៉ឹង*** នោះ ពុំចេះរអែងខ្លាចចំពោះអន្តរាយ និងមិនដែលគិតថាខ្លួនកើតមកមានគ្រោះអាក្រក់ ឬថា មនុស្ស និងវត្ថុសព្វយ៉ាងក្នុងលោកជាសត្រូវចំពោះខ្លួនឡើយ ។ ជនប្រភេទនេះ បើទុកជាជួបប្រសព្វនឹងឧប្បត្តិហេតុអាក្រក់ មានភ័យឬក៏ការបៀតបៀនពីជនដទៃ ឬទទួលទុកលំបាកបែបណាក៏ដោយ មិនចេះខូចចិត្ត ។ ជនប្រភេទនេះ គ្មាន


www.budinst.gov.kh www.elibraryofcambodia.org

អ្នកណាអាចយកឈ្នះបានឡើយ ព្រោះសូម្បីអ្នកដែលបៀតបៀនអោយទុក្ខទោសយ៉ាងណាក៏ដោយ ក៏ធ្វើបានតែចំពោះរាងកាយ និងប៉ះពាល់ដល់ទឹកចិត្តពុំបានជាដាច់ខាត បើទុកជាត្រូវប្រទុស្តរាយទាល់តែយ៉ាប់យ៉ឺត ក៏នៅតែអាច ***សាងខ្លួន*** អោយត្រឡប់ប្រសើរឡើងបានទៀតក្នុងកាលមិនយូរដោយអំណាច ***ចិត្តរឹងប៉ឹង*** មិនរួញរារឹតតែត្រូវប្រទុស្តរាយច្រើនឡើងត្រឹមណា ក៏រឹតតែមានមានៈដំឡើងកំឡាំងចិត្តរឹងតែខ្លាំងឡើងត្រឹមនោះ នរណានៅតែចចេសយកឈ្នះ ជនប្រភេទនេះនឹងត្រូវវិនាសទៅមុនជាក់ជាពុំខាន ។

លក្ខណៈ ***មនុស្សរឹងប៉ឹង*** នោះ យើងអាចរួបរួមមកបាន ៤ ប្រការគឺ :

១. មិនចេះពោលឬថ្ងូរ ។

២. មិនត្រូវការចង់ដឹងថា អ្នកដទៃនឹងគិតពីខ្លួនថាយ៉ាងដូចម្តេច ។

៣. មិនប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់អ្នកដទៃ និងមិនត្រូវការចង់ដឹងការអាថ៌កំបាំងរបស់អ្នកដទៃ ។

៤. មិនគិតថាខ្លួនជាមនុស្សមានគ្រោះអាក្រក់ អាចនឹងនាំយកហេតុការណ៍ផ្សេងៗ មកធ្វើជាប្រយោជន៍ដល់ខ្លួនបានទាំងអស់ ។

សូមអធិប្បាយទាំង ៤ ប្រការនេះអោយបានយល់ងាយដូចតទៅ :

***ប្រការ ១ :*** ជនដែលពោលឬថ្ងូរនោះ សំដែងអោយយើងឃើញភាពទន់ខ្សោយតស៊ូចំពោះសេចក្តីលំបាកពុំបាន ឬក៏យ៉ាងហោចមកមិនលាក់បាំងទុកក្នុងចិត្តបានត្រូវតែនិយាយអោយគេដឹង ។ ការដែលបង្ហាញអោយមនុស្សទូទៅដឹងថា ខ្លួនបានទទួលការលំបាកនោះជាផលដ៏អាក្រក់សំរាប់ផង់ចំពោះ


www.budinst.gov.kh www.elibraryofcambodia.org

ការលំបាកហើយបើការលំបាកនោះ បង្កើតឡើងដោយអ្នកដទៃក្លែងធ្វើអោយលំបាកផង នោះ នឹងជាហេតុអោយអ្នកដែលបៀបតបៀននោះ រឹតតែសប្បាយចិត្តបន្ថែមការបៀតបៀននោះអោយខ្លាំងឡើង ។ តែជនដែលមិនថ្វូតស៊ូចំពោះការលំបាកដោយស្ងៀមស្ងាត់រមែងធ្វើអោយជនទាំងឡាយមើលឃើញ នូវភាពមាំទាំរឹងប៉ឹងដែលគេអោយគោរពកោតខ្លាច និងធ្វើអោយអ្នកដែលប្រទុស្តរាយ ពុំអាចរីករាយថាគេបានជ័យជំនះ ហើយបើទុកជាគេគិតប្រទុស្តរាយទៅទៀត គេក៏ត្រូវដឹងថា និងយកជ័យជនះមិនបាន ហើយជួនកាល ធ្វើអោយគេរអាលែងហ៊ានតទៅទៀតផង ។ ក្នុងសៀវភៅ How to win (**វិធីយកឈ្នះ**)[១] របស់លោកសាស្ត្រាចារ្យ ***អែនដឺរសាន*** អ្នកទស្សនៈវិទូ***អាមេរិកកាំង*** បានពោលទុកមួយឃ្លាយ៉ាងពិរោះថា ***ចូរកុំប្រាប់ជនណាថាអ្នកមានគ្រោះអាក្រក់*** (Badluck) ***ព្រោះគ្រោះអាក្រក់នោះគ្មាន ជនណាចង់ជួបឡើយ*** ។

***ប្រការ ២*** ជនដែលមានលក្ខណៈរឹងប៉ឹង តែងមានការទុកចិត្ត ត្រិះរិះត្រឹមត្រូវហើយក៏ជឿជាក់ថា ខ្លួនធ្វើត្រូវ ហើយពុំយកចិត្តទុកដាក់ ទោះបីអ្នកណាពោលអាក្រក់ល្អយ៉ាងណាក៏ដោយ ជនដែលឧស្សាហ៍សើុបសួរចង់ដឹងថា អ្នកដទៃយល់ឃើញចំពោះខ្លួនយ៉ាងណាខ្លះនោះ ក៏ព្រោះមិនប្រាកដក្នុងចិត្តខ្លួនឯងថា ខ្លួននោះដូចម្តេចរបស់អ្វីដែលធ្វើទៅហើយនោះត្រូវ ឬខុសសូម្បីខ្លួនឯងក៏ពុំដឹងផង ។ ជនប្រភេទនេះខ្វីបខ្វៀវសើុបសួរជានិច្ចថា

(១) សៀវភៅនេះ យើងខ្ញុំប្រុងព្យាយាមនាំចេញមកបង្ហាញតទៅទៀតដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

លោកនាយថៅហ្វាយ មាននិយាយពីខ្លួនដូចម្ដេចខ្លះ ។ តែជនដែលមានលក្ខណៈរឹងប៉ឹង ដែលជឿថាខ្លួនធ្វើត្រូវហើយ តែងតែមិនព្យាយាមចង់ដឹងថាអ្នកធំជាងនិយាយពីខ្លួនដូចម្ដេចទេ ព្រោះជឿជាក់ថាបើទោះជានិយាយក៏និយាយពីល្អពុំខាន ។ អ្នកប្រាជ្ញ ***អាមេរិកកាំង*** ឈ្មោះលោក EMERSON ***អ៊ីមឺសាន់*** បានពោលពាក្យមួយឃ្លា ដែលគួរចងចាំថា ***របស់ដែលខ្ញុំត្រូវធ្វើនោះ គឺរបស់ដែលទាក់ទងនឹងខ្ញុំ មិនមែនរបស់ដែលមនុស្សទាំងឡាយគិតនោះឡើយ*** ។ (What I must do is all tha concernme , not what the people think ) ។

***ប្រការ ៣*** ការលាតត្រដាងអាថ៌កំបាំងរបស់ខ្លួនអោយអ្នកដទៃស្ដាប់ក្ដី ឬការព្យាយាមចង់ដឹងអាថ៌កំបាំងអ្នកដទៃក្ដី ជាលក្ខណៈនៃសភាពទន់ខ្សោយដោយពិត ។ ជនខ្លះលាក់អាថ៌កំបាំងមិនបាន នឹងធ្វើអោយប្រេះទ្រូង ត្រូវតែដើរប្រាប់អ្នកនេះអ្នកនោះអោយស្ដាប់ រួចហើយបន្ថែមពាក្យថា ***កុំនិយាយទៅទៀតណា៎ ដែលខ្ញុំនិយាយអោយស្ដាប់នេះ ព្រោះខ្ញុំទុកចិត្តទើបនិយាយ*** ។ តែដល់ទៅជួបអ្នកណាម្នាក់ទៀត ក៏និយាយអោយស្ដាប់ទៀត ហើយក៏បន្ថែមពាក្យហាមដដែលនេះទៀត ។ ជនខ្លះទៀតមានការខ្វល់ខ្វាយ ក្នុងការចង់ដឹងរឿងអាថ៌កំបាំងរបស់អ្នកដទៃ បើបានដឹងហើយ ទោះជារឿងគ្មានប្រយោជន៍ក៏ដោយ ក៏រីករាយស្រស់ស្រាយ ប្រហែលគ្នានឹងបានទទួលទានអាហារដ៏មានឱជារស ព្រោះហេតុនោះទើបវិធីដែលនឹងមើលលក្ខណៈរបស់មនុស្សដ៏ល្អមួយគឺ បើនរណាមួយជាអ្នកនិយាយការអាថ៌កំបាំងអោយយើងស្ដាប់ ដោយ


www.budinst.gov.kh www.elibraryofcambodia.org

គ្មានហេតុផលឬ ចូលចិត្តឱ្យបង្ខៀរ ចង់ដឹងរឿងផ្ទាល់ខ្លួនអ្នកដទៃនោះ អ្នកនោះ ជាមនុស្សទន់ខ្សោយ មិនគួរគោរពរាប់អានជឿស្តាប់ឡើយ ។

*ប្រការ ៤* មានល័ក្ខដែលគួរជឿមួយថា ជោគអាក្រក់នោះមិនអាចយកឈ្នះលើយើងបានទេ លុះត្រាតែយើងសុខចិត្តចុះចាញ់វា ។

ដូចបានពោលមកពីខាងដើមហើយថា អ្នកដែលមានលក្ខណៈរឹងប៉ឹងនោះអាចហ៊ានហៅ ជោគអាក្រក់អោយចូលជាជួរមករក ដើម្បីនឹងតស៊ូអោយវាបរាជ័យទៅជាលំដាប់លំដោយ ដោយអំណាចដួងចិត្តរបស់ខ្លួន ។ អ្នកដែលមានលក្ខណៈរឹងប៉ឹង រមែងមិនដឹងទាំងជោគអាក្រក់នោះផង បើទុកជាមានហេតុការណ៍ណាមួយកើតឡើង ក៏មិនទទួលផលពីហេតុការណ៍នោះទេ បែរជាទាញយកហេតុការណ៍នោះ ជាឧបករណ៍ធ្វើសេចក្តីល្អចំពោះខ្លួនបានគ្រប់យ៉ាង ។ អ្នកសិក្សាដែលមានលក្ខណៈទន់ខ្សោយ តែងតែទោមនស្ស រហូតដល់សម្លាប់ខ្លួនក៏មាន កាលបើប្រឡងធ្លាក់ ។ តែអ្នកសិក្សាដែលមានលក្ខណៈមាំទាំ ឥតមានតូចចិត្តទេ ព្រោះបើប្រឡងជាប់ក៏គិតឃើញថា នឹងឡើងរៀនថ្នាក់បន្តទៅទៀត បើប្រឡងធ្លាក់ក៏គិតឃើញថា នឹងរៀនអោយបានច្បាស់លាស់ទៀត អ្នកដើរទូកដែលចេះ ត្រូវការដំណើរឡើងតាមស្ទឹង គេឆ្លៀតយកពេលដែលជំនោរ ចែវទូកឡើង ហើយគេឆ្លៀតនៅពេលទឹកនាចសំរាកយកកំឡាំងបន្តដំណើរទៅទៀត ។ បើមានជនណាម្នាក់មកនិយាយប្រាប់ថា ខ្ញុំដើរទូកមិនបានដល់ទីដៅ ព្រោះកាលណាខ្យល់ជំនោរ ខ្ញុំចែវឡើងកាលណាខ្យល់នាចខ្ញុំបណ្តែតចុះវិញ ដោយខ្ញុំគ្មានកំឡាំងចែវបញ្ច្រាសទឹក



www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះយើងគិតឃើថា ជននោះបើមិនឆ្កួតស៊ប់ទេ ក៏ល្ងើពុំដឹងអីដែរ យ៉ាងណាមិញមនុស្សដែលបណ្តោយខ្លួនអោយលិចអណ្តែតតាមហេតុការណ៍ដែលប្រព្រឹត្តទៅនោះ គឺជាមនុស្សល្ងើយ៉ាងនោះឯង ។ ***ណាប៉ូឡេអុង*** ជាមនុស្សម្នាក់ដែលយល់វិធីនេះប្រាកដប្រជាណាស់ ព្រោះថាក្នុងសម័យដែលមានវិបត្តិកើតឡើងចំពោះរដ្ឋាភិបាលថ្មី កាលចាប់ផ្តើមជីវិតរុងរឿងរបស់គាត់នោះ គាត់ក៏ទទួលស្ម័គ្រចិត្តទៅច្បាំងនៅប្រទេស ***អ៊ីតាលី*** និង ***អេហ្ស៊ីប្ត*** ប្រើកាលវេលាដែលលំបាកនោះ រកកេរ្តិ៍ឈ្មោះ និងផលប្រយោជន៍ក្នុងផ្លូវដទៃ ។ កាលឃើញថារដ្ឋាភិបាលខ្សោយណាស់ទៅហើយនោះ ក៏ឆ្លៀតឱកាសប្រញាប់ចូលមក ***ប៉ារីស*** វិញ ហើយក៏បានទទួលនាទីជាប្រមុខរដ្ឋាភិបាល ។ វេលាត្រូវនិរទេសទៅនៅលើកោះ ដែលសត្រូវរបស់គាត់ នាំគ្នារីករាយថាគាត់ដល់នៅជោគជតាអាក្រក់ហើយ តែមិនដូច្នេះទេ គាត់ត្រឡប់ជាយកពេលវេលានៅលើកោះនោះសរសេរសារណាកត់ហេតុការណ៍ក្នុងជីវិតរបស់ខ្លួនទុកជាឯកសារដ៏សំខាន់ ដែលគាត់ធ្វើទុក ព្រោះជាគ្រឿងពន្យល់អោយពិភពលោកឃើញនូវគុណសម្បត្តិរបស់គាត់ សំរាលនូវសេចក្តីរិះគន់ ដែលគេថាគាត់មានមហិច្ឆិតា (Ambition) យកមនុស្សទៅស្លាប់រាប់ៗសែន និងធ្វើអោយជនជាតិបារាំងសែសស្រឡាញ់គោរពរាប់អានរហូតដល់យកសពរបស់គាត់ត្រឡប់មកបញ្ចុះនៅកណ្តាលក្រុង ***ប៉ារីស*** ដែលគ្មានស្តេចបារាំងអង្គណាបានទទួលកិត្តិយសដល់ថ្នាក់ហ្នឹងឡើយ ។ មនុស្សដែលមានលក្ខណៈរឹងប៉ឹងដូច ***ណាប៉ូឡេអុង*** នេះ តែងតែជាម្ចាស់នៃជោគជតា និងគ្មានអំណាចអ្វីក្នុង



www.budinst.gov.kh www.elibraryofcambodia.org

លោក មកធ្វើអោយមនុស្សប្រភេទនេះ ក្លាយជាមនុស្សគ្រោះអាក្រក់បានឡើយ ។

មនុស្សដែលមានលក្ខណៈរឹងប៉ឹងនោះ ក្រៅពីលក្ខណៈ ៤ ប្រការនេះ មានលក្ខណៈដែលយើងអាចកត់សំគាល់បានយ៉ាងងាយដទៃទៀត គឺជាមនុស្សមិនកញ្ឆក់កញ្ឆែង ចលនាគ្រប់យ៉ាងរបស់រាងកាយ សូម្បីតែចោលភ្នែកមើលអ្វី ក៏សុទ្ធតែមានការត្រិះរិះហើយទើបធ្វើ ឥតមានធ្វើកាយវិការក្នុងឥរិយាបថដែលឥតប្រយោជន៍នោះទេ បើធ្វើចលនាឥរិយាបថណាមួយ គឺធ្វើទៅដោយប្រយ័ត្នប្រយែង មិនច្រលេះច្រលាស់ បើនឹងឈរក៏ឈរដាក់ទម្ងន់ជើងទាំងពីរស្មើគ្នា ពុំមែនធ្ងន់មួយស្រាលមួយឡើយ ឬក៏ឈរជើងតែមួយហើយជើងមួយទៀតផ្អែកទៅលើអ្វីឡើយ ការនិយាស្តីច្បាស់ៗ មិនញាប់ខ្លះរង្ងើលខ្លះឡើយបានសេចក្តីថា ឥរិយាបថគ្រប់យ៉ាងមាននឹងនជានិច្ច បើយើងបានជួបជនប្រភេទនេះ គប្បីដឹងថាជាមនុស្សមានលក្ខណៈរឹងប៉ឹង ។

ពាក្យស្លោកបូរាណលោកថា : នាគមានពិសឫទ្ធិឬប្រៀបនឹងសូរិយាវារលូនឥតស្វែង លាក់ស្នូរស្រែងនៃតេជា ។

ផ្ទុយស្រឡះ ចំណែកជនដែលមាននិស្ស័យទន់ខ្សោយតែងមានអាការៈកញ្ឆក់កញ្ឆែង ចលនាគ្រប់យ៉ាងធ្វើដោយច្រលេះច្រលាស់ និងមានអាការៈឥតចាំបាច់ជាច្រើន ដូចយ៉ាងខាំមាត់ - ពេបមាត់ - សង្កៀតធ្មេញ ភ្នែកក្រឡឹតក្រឡាប់ ទទ្រោកជើង ឈរជើងមួយ សំរាលជើងមួយ ឬពុំដូច្នោះតឹផ្អែកលើអ្វីមួយដោយពុំចាំបាច់ និយាយស្តីឥតសណ្តាប់ញាប់ៗរង្ងើលៗ គ្មានរបៀប


www.budinst.gov.kh www.elibraryofcambodia.org

រៀបរយ នេះគឺជាលក្ខណៈរបស់ជនទន់ខ្សោយ ។

ការរៀបចំ ចលនាឥរិយាបថសព្វយ៉ាងនេះ ហាក់ដូចជាមនុស្សពុំសូវយកចិត្តទុកដាក់ទេ ។ ប៉ុន្តែការណ៍នេះ គឺជាភាពបង្ហាញចេញអោយគេកត់សំគាល់នូវលក្ខណៈទន់ខ្សោយ ឬ រឹងប៉ឹងបាន ។ ការណ៍នេះ ដំបូងឡើយយើងហាក់ដូចជាលំបាកកែ តែបើយើងយកស្មារតីមកសង្កត់បំបាត់តែក្នុងមួយអាទិត្យយ៉ាងយូរនោះ យើងនឹងឃើញបានផលជាក់ស្តែងជាពុំខាន ។

យើងគប្បីសង្កេតម្យ៉ាងទៀតថា ក្នុងកងទ័ព ហេតុអ្វីទើបគេត្រូវបង្ហាត់អោយឈរដូចតុក្កតា ។ ការធ្វើចលនាគ្រប់យ៉ាងអោយធ្វើដោយស្វាហាប់ដើរអោយត្រូវចង្វាក់ អ្នកមិនយល់គោលបំណងពិតនោះ ក៏យល់ថា ការធ្វើអកជ្រីស៊ាវេនេះ គឺដើម្បីអោយមានជារបៀបល្អមើលប៉ុណ្ណោះ ។ ការពិតមិនមែនគ្រាន់តែត្រឹមប៉ុណ្ណោះទេ គេហាត់អតជ្រីស៊ាវេនេះ គឺដើម្បីអោយទាហាន ចេះបង្ក្រាប់រាងកាយអោយនៅក្រោមការឃ្លុបឃុំរបស់ចិត្ត ជាសញ្ញាសំគាល់នៃភាពមានស្មារតីជានិច្ច ហើយនិងអោយទាហានមានចិត្តរឹងប៉ឹង ។ ហេតុនោះទាហានដែលបានទទួលការហ្វឹកហាត់អកជ្រីស៊ាវេ អោយស្វាហាន់ឡើងដរាបណា ក៏រឹងរឹតតែបន្ថែមការស្វាហាប់ខាងផ្លូវចិត្ត និងទេសេចក្តីក្លាហានឡើងដរាបនោះ ។

ភាពជាអ្នកមានចិត្តរឹងប៉ឹងនោះ ជាលក្ខណៈនៃ ***វីរបុរស*** ឬ ***មហាបុរស*** គ្រប់រូប ។ រឿង ***ប៊ីសមារក៍*** ខាងដើមដែលពោលពីកាលនៅជាកុមារនោះ បង្ហាញអោយឃើញទឹកចិត្តរឹងប៉ឹងក្រៃលែង ។ ***ប៊ីសមារក៍*** បានទទួលសម្មត



www.budinst.gov.kh www.elibraryofcambodia.org

នាមថា <<***លោកនាយករដ្ឋមន្ត្រីដែកថែប***>> ព្រោះមួយជីវិតរបស់ ***ប៊ីសមារក៍*** ។ បានបង្ហាញនូវភាពរឹងប៉ឹង មិនចុះចាញ់នរណាឡើយដូចយ៉ាង ពេលឡើងធ្វើជានាយករដ្ឋមន្ត្រីថ្មី រដ្ឋសភាក៏មិនចូលខាងខ្លួនសារព័តមានក៏ ជេររាល់ថ្ងៃ បើជាអ្នកដទៃនោះប្រហែលជាលាចេញហើយ តែ ***ប៊ីសមារក៍*** នៅតស៊ូដល់ទីបំផុត ក៏យកជ័យជំនះលើអ្នកទាំងអស់បានដោយអំពើល្អរបស់ ខ្លួន (ពុទ្ធភាសិតខ្មែរយើងថា ***អសាធុំ សាធុនា ជិនេ***) ។ ***ជីស្រាអែលី*** ធន់ទ្រាំ តស៊ូចំពោះការមើលងាយពីជនទាំងឡាយ តាំងតែពីកុមារ រហូតដល់ជា សមាជិកក្នុងរដ្ឋសភា និងតស៊ូចំពោះការលំបាកជាអនេកប្បការ រហូតដល់ បានជានាយករដ្ឋមន្ត្រី ។ ***អូ កូ បូ*** ធន់ស៊ូចំពោះពួកដែលមានយោបល់ផ្ទុយ រហូតដល់ស្លាប់ខ្លួន ទើបបានសំរេចលទ្ធផលដ៏ធំដល់ប្រទេស និងជាទី ស្រឡាញ់របស់ផងជាតិ ***ជប៉ុន*** តាំងពីព្រះអធិបរាជចុះមកដល់ពលរដ្ឋសាមញ្ញ ។ ***មុស្សូលីនី*** ធន់ស៊ូចំពោះសេចក្តីលំបាកធ្ងន់បំផុតដែលមនុស្សត្រូវទទួល គឺជាអ្នកសូមទាន ។ មនុស្សទាំងអស់សុទ្ធតែ ជាជំពូកមនុស្សដែលគ្មានអ្វីយក ឈ្នះបាន ជាមនុស្សដែលជាន់ជោគជតាផ្សេងៗ (Fate) ចុះជាទាសៈរបស់ខ្លួន បាន ទោះបីបានទទួលការទុក្ខលំបាកប្រការណាក៏ដោយ ក៏ទទួលតែត្រឹម កាយប៉ុណ្ណោះ ចំណែកផ្លូវចិត្តនោះឥតត្រូវខ្ទាំងខ្ទប់អោយញូចញ៉ាកឡើយ ។ កាលបើចិត្តឥតញូចញ៉ាក ហើយក៏អាចទម្លាយការលំបាកទាំងនោះអោយ វិនាសទៅវិញបាន ។


www.budinst.gov.kh www.elibraryofcambodia.org

It is all very well to smile

when lefe flows as a song

but the men worth while

Is the man who smiles

when everything goes dead wrong

*ជាការងាយនឹងញញឹមឥតប្រឹងសោះ*

*ព្រោះការរស់ស្រស់ដូចសម្លេងភ្លេងសួគ៌ា*

*តែជនដែលថ្លៃគួរលៃយកជាគ្នា*

*នៅចិត្តជាញញឹមបានកាលមានភ័យ ។*

ក្នុងលោកនីតិបករណ៍ លោកសុតន្តប្រីជា ***ឥន្ទ*** ពោលជាកំណាព្យដ៏ពិរោះថា :

*ជាតិអំពៅទោះនៅក្នុងយន្តគាប*

*មិនលះបង់សភាពរស់ផ្អែមសាយ*

*ជាតិបណ្ឌិតទោះមានទុក្ខក្នុងកាយ*

*មិនជិនណាយលះបង់ព្រះធម៌ថ្លៃ ។*

*ជាតិខ្លឹមចន្ទន៍ ទោះស្ងិតគ្រៀមក្រញ៉ង់*

*មិនលះបង់ក្លិនក្លែបសុគន្ធា*

*ជាតិវីរៈសារទោះចូលសឹកយុទ្ធនា*

*មិនលះបង់សីលាល្អងក្រោយ ។*



www.budinst.gov.kh www.elibraryofcambodia.org

វិជ្ជាពោលពីវិថីគោចរ នៃផ្កាយនព្វគ្រោះនោះ មានអធិប្បាយទុកម្យ៉ាងថា ជនដែលមានលក្ខណៈរឹងប៉ឹងពិតៗនោះអាចនឹងបញ្ឈប់ដំណើរគោចរដួងតារាប្រចាំគ្រោះរបស់ខ្លួនអោយឃ្លាតចេញពីអាក្រក់ទៅល្អបាន ។ ព្រោះហេតុនោះកាលបើហោរទាយថា យើងមានគ្រោះអាក្រក់នោះ ជាហេតុធ្វើអោយយើងរវាំងប្រយ័ត្នខ្លួន វិធីរវាំងប្រយ័ត្ននោះគ្មានអ្វីប្រសើរស្មើនឹងការធ្វើចិត្តរបស់យើងអោយរឹងប៉ឹងទេ ។ ព្រោះថាគ្រោះអាក្រក់ និងមនុស្សអាក្រក់ មានលក្ខណៈដូចតែគ្នា ។ មនុស្សអាក្រក់តែងបៀតបៀនជនដែលគេដឹងថា ស៊ូនឹងគេមិនបាន ។ តែថាជនណាអាចស៊ូបាននឹងត្រៀមខ្លួនចាំតស៊ូនឹងគេជានិច្ចហើយគេក៏ត្រូវបង្អង់មិនបៀតបៀនសិន និងចាំរកឱកាសកាលយើងភ្លេចខ្លួនបើជននោះមិនចេះភ្លេចខ្លួនទេ គេក៏នឹងបៀតបៀនពុំបានឡើយយ៉ាងណាមិញគ្រោះកម្មដែលភាសាអង់គ្លេសហៅថា Fate ក៏ដូច្នោះដែរ ជនដែលទន់ខ្សោយរអែង តក់ស្លុតញាប់ញ័រជានិច្ចនោះ វាក៏នឹងមកដល់នៅយើងនៅពេលណាមួយ តែជនដែលមិនខ្លាច មិនភ្លេចខ្លួន វាក៏មិនអាចមករកយើងបានដែរ ។

ខាង ***ទស្សនវិជ្ជាអឺរ៉ុប*** ក្តី ***លទ្ធិយោគី*** របស់ ***ឥណ្ឌា*** ក្តី លក្ខណៈមាំទាំរឹងប៉ឹងនេះ ជាប្រការដ៏សំខាន់បំផុតដែលគេតែងប្រដៅអោយបណ្តុះអោយមានឡើងក្នុងខ្លួន ។ វិធីប៉ុណ្ណោះនោះ គេអោយចាប់ផ្តើមដោយការបង្គាប់រាងកាយរបស់ខ្លួនជាមុន អោយព្យាយាមមិនអោយរាងកាយធ្វើចលនាដោយប្រាសចាកការឃ្លុបឃុំរបស់ចិត្ត និងមិនអោយធ្វើចលនា ដោយមិនចាំបាច់ (ត្រង់នេះត្រូវគ្នានឹងក្បួនសតិបដ្ឋានរបស់ព្រះពុទ្ធសាសនាយើងដែរ) ។


www.budinst.gov.kh www.elibraryofcambodia.org

ប្រការមួយទៀត វេលាចូលដេកមុននឹងលក់ គេបង្គាប់អោយធ្វើចិត្តអោយមាំ ទាំថា ស្អែកនេះដួងចិត្តរបស់យើង ត្រូវរឹងប៉ឹងក្រៃលែងឡើងជាងថ្ងៃនេះ ដល់ភ្ញាក់ពីព្រលឹមឡើង ក៏អោយដាក់ជំនឿក្នុងខ្លួនឯងថាយើងមានលក្ខណៈ ដករឹងប៉ឹង នឹងត្រៀមជាស្រេច ដើម្បីប្រឈមមុខ និងភាពលំបាកតោកយ៉ាក ផ្សេងៗនៃជីវិត ។ ប្រការមួយទៀត ជានិស្ស័យរបស់ជនខ្លះ ឬក៏ដោយច្រើន មានសភាពរវើរវាយនៅថ្ងៃខ្លះ ដូចជាខ្លួននោះនឹងត្រូវគ្រោះអាក្រក់ណាមួយ អោយក្រោកពីទីអង្គុយ ឈរអោយត្រង់ខ្លួនដកដង្ហើមអោយវែងៗ ៤-៥ដង ហើយតាំងចិត្តអោយមាំថា យើងឥតខ្លាចអ្វីឡើយក្នុងលោកនេះ យើងមាន អំណាចលើហេតុការណ៍ទាំងអស់ បើសិនជាយើងប្រតិបត្តិបានដូច្នេះជានិច្ច គេពន្យល់ថា យើងនឹងមានលក្ខណៈរឹងប៉ឹងឡើងរាល់ថ្ងៃក្លាយជា ***អជិត បុគ្គល*** នរណាក៏ពុំអាចយកឈ្នះបានឡើយ ។

នេះជា " ***កូនសោ*** " សំរាប់ ***សំណាងខ្លួនឯង*** ។

* * * * *



www.budinst.gov.kh www.elibraryofcambodia.org

# ៣. សមាធិ

# CONCENTRATION

គ្រាន់តែឮពាក្យថា ***សមាធិ*** ជនភាគច្រើនៗតែងគិតឃើញថា ជារបស់សំរាប់យាយជី - អាចារ្យ លោកសង្ឃ ធុតង្គ នៅឯតូបព្រៃភ្នំឯណា ឯណោះទេ ។ ហេតុអ្វីក៏ទៅយកធម៌អាថ៌ ***សមាធិ វិបស្សនា*** ឯណាមកជា ***គុណសម្បត្តិ*** នៃ ***ការសាងខ្លួន*** ទៅវិញ ។ សមាធិនេះ សំរាប់តែមនុស្សចាស់ខ្លាចស្លាប់ហើយទៅរៀនធ្វើ ជាមួយអាចារ្យ លោកសង្ឃ ដល់ស្លាប់ទៅៗកើតឋានសួគ៌តាមគម្ពីរពុទ្ធសាសនាឯណោះទេ ។ មែន រឿងនេះភាគច្រើនណាស់ដែលមិនយល់ ហើយយល់យ៉ាងនេះ ។ ព្រះពុទ្ធសាសនាមែន មានតំលៃណាស់តែអ្នកកាន់ពុទ្ធសាសនា ឥតចូលដល់សោះទេ គ្រាន់តែដូចជាកាន់ដុំថ្ម ដែលមានពេជ្រនៅពីក្នុង ហើយដើរបង្អួតគេថា ខ្លួនមានពេជ្រ តែខ្លួនពុំដឹងថាពេជ្រនោះ ដូចម្តេចផង ។ ហេតុនោះគ្រាន់ឮពាក្យនេះភ្លាមក៏ហាក់ជារបស់ពុំមានន័យចំពោះខ្លួនតែម្តងទៅ ។

លោកអ្នកអានជាទីគោរព ***សមាធិ*** ក្នុងទីនេះ មិនមែនជាការចូល ***ឈានសមាបត្តិ*** ដូចធ្លាប់ឮមកនោះទេ ។ គឺជា ***សមាធិ*** សំរាប់ប្រើក្នុងជីវិតប្រចាំថ្ងៃ ក្នុងកិច្ចការផងទាំងពួង ជាគុណសម្បត្តិដ៏សំខាន់មួយរបស់ ***វីរបុរស*** ឬ ***មហាបុរស*** ដោយពិត ។



www.budinst.gov.kh www.elibraryofcambodia.org

ពាក្យថា ***សមាធិ*** បានសេចក្ដីថា ការតាំងចិត្តមាននៅចុងវត្ថុតែមួយ ដែលយើងធ្វើ ។ មនុស្សមានសមាធិ តែងអាចផាត់ចេញនូវការគិតដទៃៗ ទៀត ដែលមិនត្រូវការនោះចេញបានអស់ និងបង្រួមកំឡាំងប្រាជ្ញាមកប្រើ ក្នុងរឿងតែមួយក្នុងគ្រាមួយ ។ គេប្រៀបប្រដូចជាកញ្ចក់ស្រូបកំដៅ ធ្វើអោយ ក្ដៅឆេះជាភ្លើងបាន ត្រូវដាក់អោយចំកន្លែងមានកំដៅនឹងតែមួយកន្លែង យ៉ាងណាមិញ ចិត្តមនុស្សដ៏ដូច្នោះ ។ តាមប្រក្រតីចិត្តមនុស្សរមែងរសាត់ អណ្ដែតមិននឹងន លោតពីអារម្មណ៍មួយទៅកាន់អារម្មណ៍មួយទៀតជានិច្ច ។ ដូច្នេះ កំឡាំងប្រាជ្ញាក៏ថយតិចចុះ តែបើតាំងខ្ជាប់នៅលើវត្ថុតែមួយ គិតតែ វត្ថុនោះ រហូតដល់សំរេចហើយ ទើបបែរទៅរកវត្ថុដទៃទៀតដូច្នេះ របស់ ទាំងឡាយដែលធ្វើរមែងសំរេចបានដោយល្អជានិច្ច ។ មនុស្សយើងរឹតតែ មាននាទីសំខាន់ឡើង ដរាបណាក៏រឹតតែត្រូវការ ***សមាធិ*** ច្រើនឡើងដរាប នោះ មនុស្សឋានៈជា ***នាយករដ្ឋមន្ត្រី*** ឬ ***ប្រមុខរដ្ឋ*** ដែលចុះហត្ថលេខាលើ លិខិតផ្សេងមួយថ្ងៃៗ ៥០-៦០ច្បាប់ដោយឥតខុស ក៏ព្រោះមាន សមាធិដ៏ខ្លាំងក្លា ។កាលអានលិខិតច្បាប់មួយ តែងតែមិនគិតដល់ច្បាប់ដែល ចាប់យកមកចុះហត្ថលេខានោះតទៅ ។ បើនៅវេលាចុះហត្ថលេខាលើលិខិត ច្បាប់មួយហើយ រវល់តែគិតទៅច្បាប់មួយទៀតនោះ ក៏នឹងខុស ១០ -២០ ដងក្នុងមួយថ្ងៃពុំខាន ។

ការដែលមានចិត្តជាសមាធិនេះ ជាលក្ខណៈរបស់មនុស្សរឹងប៉ឹង មនុស្សទន់ខ្សោយធ្វើមិនបានទេ ព្រោះហេតុនោះ ការហ្វឹកហាត់អោយមាន



www.budinst.gov.kh www.elibraryofcambodia.org

***សមាធិ*** ទើបជាគ្រឿងធ្វើមនុស្សអោយមានលក្ខណៈរឹងប៉ឹងឡើង ។ ពីព្រោះ មនុស្សយើងច្រើនបណ្ដោយចិត្ត អោយរសាត់អណ្ដែតទៅតាមអារម្មណ៍ ដែលមួយៗចូលមក តែកាលបើយើងបង្ខាប់ខ្លួនយើងអោយលះអារម្មណ៍ ដែលមិនត្រូវការចេញទៅបាន សល់តែរឿងដែលត្រូវការដូច្នេះហើយ ក្រៅ ពីធ្វើការបានត្រឹមត្រូវ និងឆាប់រហ័សហើយ អាចនឹងធ្វើអោយសំរេចបានល្អ ប្លែកទៀត នឹងមានការគិតស្រឡះស្រឡំ អាចទំពារបញ្ហាដែលពិបាកៗអោយ ងាយស្រួលបានទៀតផង ។

មនុស្សដែលដេកមិនលក់ ហើយរាងកាយដែលគួរបានទទួលការសំរាក ត្រឡប់ជាមិនបានសំរាក ទីបំផុតខឹងនឹងខ្លួនឯងថា ដេកមិនលក់ ទាល់តែយប់ ជ្រៅលក់ដល់ទៅពេលជិតភ្លឺទៅហើយ ដល់ភ្ញាក់ឡើងហេវ គ្មានកំឡាំងគ្រប់ គ្រាន់នឹងធ្វើការតទៀត ដូចនេះព្រោះមកពីខ្វះ ***សមាធិ*** ។ ចំពោះមនុស្ស ដែលមាន ***សមាធិ*** ល្អនោះ ចង់អោយលក់ពេលណា ភ្ញាក់ពេលណាក៏បាន តាមចិត្ត រាងកាយក៏បានទទួលការសំរាកដ៏ល្អ ភ្ញាក់ព្រលឹមឡើងខួរក្បាលក៏ ស្វាងស្រឡះ មានមានៈមានព្យាយាមអាចប្រកកិច្ចការប្រចាំថ្ងៃអោយសំរេច ដោយប្រពៃជាទីបំផុត ។

ដំណាលថា ***សេនាប្រមុខហ្សូហ្វ្រឺ*** Joffre ដែលអាចការពារក្រុង ***ប៉ារីស*** មិនអោយធ្លាក់ចុះក្នុងកណ្ដាប់ដៃ ***អាល្លឺម៉ង់*** និងយកជ័យជំនះនៅស្ទឹង ***ម៉ារ៍ន*** (Marn) បានជាហេតុអោយកលយុទ្ធ ***អាល្លឺម៉ង់*** ប្ដូរទៅជាការពារទប់ទល់ វិញ នោះក៏ព្រោះអំណាច ***សមាធិ*** ជាសំខាន់ ។ ដំណាលថា បើលោក ***សេនា***



BUDDHIST INSTITUTE LIBRARY បណ្ណាល័យ

www.budinst.gov.kh www.elibraryofcambodia.org

***ប្រមុខ*** អង្គុយគិតរឿងអ្វីមួយហើយ ហាក់ដូចជាឥតឮសូរកាំភ្លើងនៅជុំវិញខ្លួនឡើយ ។ កាលបើធ្វើការច្រើនពេក ឃើញរាងកាយដែលជរារបស់គាត់ត្រូវសំរាកហើយ មិនថាកន្លែងណាពេលណាឡើយ លោកអាចសំរានុលក់ភ្លាមបាន ។ កាលក្រុង ***ប៉ារីស*** ភិតភ័យស្លន់ស្លោទាំងក្រុង គេទូរស័ព្ទទៅសួរឯជួរទព័ប្រយុទ្ធថា ឥឡូវនេះលោកមេទ័ពកំពុងធ្វើអ្វី នាយទាហ៊ានម្នាក់ឆ្លើយមកវិញថា << ***លោកកំពុងសំរានុលក់*** >> ។

ដំណាលទៀតថា វេលាមួយនោះលោក ***សេនាប្រមុខ*** ជិះរថយភ្លើងយប់ជារថភ្លើងដេក ដើម្បីទៅធ្វើកិច្ចការសំខាន់មួយនៅទីមួយក្នុងថ្ងៃព្រឹកឡើង លោកឆ្លៀតយកពេលធ្វើដំណើរជាពេលសំរាក និងដេកលក់តាមផ្លូវទៅដល់ស្ថានីយមួយមានទូរលេខមកលោក នាយទាហានជំនិត បានចូលទៅដាស់លោកហើយជូនទូរលេខនោះអោយលោកពិនិត្យ លោកសេនាប្រមុខក្រោកឡើងសរសេរបញ្ជាលើសារទូលេខបានដោយឥតមានសញ្ញាថា ងឹងងោងងោកងុយបន្តិចបន្តួចឡើយ រួចហើយលោកក៏ប្រាស់ខ្លួនដេកទៅវិញគ្រាន់តែនាយទាហាននោះចុះពីរថភ្លើង ដើម្បីយកសារទូរលេខទៅបញ្ជូននៅស្ថានីយក៏នឹងឃើញថា នៅសល់ទូរលេខមួយទៀត ក៏ហាក់ឡើងមកវិញដើម្បីជូនពិនិត្យទៀត តែលោក ***លោកសេនាប្រមុខ*** លង់លក់រួចទៅហើយត្រូវដាស់ម្តងទៀត ។ ការដូច្នេះនេះ ព្រោះថា វេលាលោកភ្ញាក់ឡើងឃើញទូរលេខ កំឡាំងដួងចិត្តទាំងមូលក៏មករួមគ្នាលើទូរលេខនោះ ទើបបញ្ជាការបានភ្លាមៗ ហាក់ដូចជាលោកភ្ញាក់នៅជានិច្ច ដល់នាយទាហាននោះចេញផុត



www.budinst.gov.kh www.elibraryofcambodia.org

ទៅ លោកក៏ដេញអារម្មណ៍ផ្សេងៗចេញពីចិត្តលោកអស់ ហើយក៏សំរាន្តលក់ទៀតភ្លាម ។

ពេទ្យដែលព្យាបាល ***ណាប៉ូឡេអុង*** នៅពេលដែលគាត់ជិតស្លាប់នៅកោះ ***សាំងអេឡែន*** បានអង្វរសុំអោយគាត់ប្រាប់ ដើម្បីជាប្រយោជន៍ដល់មនុស្សលោកថា :មាន <<***កូនសោ***>> ល្អដូចម្តេច ទើងបអាចធ្វើការបានសំរេចដ៏ធំមហិមាដល់ថ្នាក់ហ្នឹង ? គាត់ប្រាប់ថា : <<ក្នុងខួរក្បាលរបស់ខ្ញុំមានសន្ទះបិទជាបន្ទប់ៗ បន្ទប់ណាខ្ញុំមិនត្រូវការប្រើ ខ្ញុំក៏បិទសន្ទះទុក ពេលខ្ញុំធ្វើការផ្នែករដ្ឋបាល ខ្ញុំបើកសន្ទះបន្ទប់ផ្នែករដ្ឋបាលមកប្រើការ បន្ទប់ដទៃទៀតខ្ញុំបិទសន្ទះ ចាក់សោពេលខ្ញុំសរសេរផែនការណ៍យុទ្ធសាស្ត្រ ខ្ញុំក៏បិទសន្ទះបន្ទប់ដទៃៗអស់ បើកតែបន្ទប់ខាងច្បាំងមកប្រើ ។ ពេលខ្ញុំរលឹកដល់នាង ***ហ្សូសែហ្វីន*** មហេសី ខ្ញុំក៏បិទបន្ទប់ដទៃអស់ ប្រើតែបន្ទប់សំរាប់ ***ហ្សូសែហ្វីន*** តែមួយ >> គ្រូពេទ្យមិនស្គាល់លក្ខណៈ ***សមាធិ*** ក៏ញញឹមសំដែងអាការ:មិនជឿ ។ ***ណាប៉ូឡេអុង*** និយាយទៅទៀតថា <<លោក មិនជឿ ឬ ខ្ញុំនឹងធ្វើអោយមើល គឺខ្ញុំបិទសន្ទះគ្រប់បន្ទប់ទាំងអស់ចាក់សោ>> និយាយប៉ុណ្ណោះ គាត់ក៏ធ្មេចភ្នែក ហើយលក់មួយរំពេច គឺលក់ពិតមែន គ្រូពេទ្យក៏សារភាពថា មិនមែនក្លែងធ្វើទេ ។ នេះឯងជា <<***កូនសោ***>> ***ណាប៉ូឡេអុង*** ។

វិធីហាត់ចិត្តអោយជា ***សមាធិ*** នោះ យើងអាចហាត់បានគ្រប់ពេលតាមធម្មតាមនុស្សយើងមានការងារប្រភេទខ្លះ ចូលចិត្តធ្វើប្រភេទខ្លះមិនចូលចិត្តធ្វើ សន្មតថា មានលិខិត៣រឿង ដែលយើងត្រូវសរសេរ ២រឿងជារឿង


www.budinst.gov.kh www.elibraryofcambodia.org

ដែលយើងចូលចិត្ត ចាប់ធ្វើភ្លាមបានមួយរំពេច រឿងមួយទៀតមិនចុះសំរុង នឹងយើង ព្រោះហេតុអ្វីក៏ដោយ យើងក៏ទុកព្រឹកទៅល្ងាចស្អែកទៅខានស្អែក ទីបំផុតពេលក៏កន្លងយូរទៅ រឿងមិនប្រញាប់ក៏ក្លាយជាប្រញាប់ទាល់តែកើត រឿងរ៉ាវអ្វីឡើង ទើបស្តាយក្រោយថា បើធ្វើអោយហើយម្ល៉េះសមល្អ ហេតុដូច្នេះ លោកទើបប្រដៅថា បើមានកិច្ចការច្រើនយ៉ាងមកដល់ព្រមគ្នា ហើយមិនសូវប្រញាប់ជាងគ្នាទេ លោកអោយជ្រើសរើសយកកិច្ចការដែលយើងមិនចូលចិត្តនោះមកធ្វើមុន ការដែលលោកប្រដៅដូច្នេះ ដើម្បីប្រយោជន៍ពីរយ៉ាងគឺ : ដើម្បីបង្ខំចិត្តបង្គាប់អោយធ្វើការនោះអោយផុតទៅ ដែលជាគ្រឿងអោយកើត ***សមាធិ*** ម្យ៉ាង ហើយម្យ៉ាងទៀត ដើម្បីអោយចេះបំពារចិត្តខ្លួនឯងដែលជាគ្រឿធ្វើអោយកើតលក្ខណៈរឹងប៉ឹង ។ ពិតណាស់ វិធីនេះមានប្រយោជន៍បំផុត បើហាត់ធ្វើយ៉ាងនេះបានតែមួយខែ ក៏នឹងផ្លាស់ប្តូរនិស្ស័យរបស់យើងទៅជាមនុស្សម្នាក់ទៀត ហើយការងារដែលយើងធ្វើសំរេចនោះក៏ល្អទៀត ។

លោកប្រដៅទុក ម្យ៉ាងទៀតថា អោយយកទឹកដាក់កែវហើយឈរទ្រលើកឡើង អោយសំឡឹងមើលក្នុងកែវ ព្យាយាមបង្គាប់ចិត្តអោយស្ងប់បង្គាប់ដៃអោយនឹង ទាល់តែទឹកក្នុងកែវមិនក្រឡុក ជាន់ដំបូងគ្មានមនុស្សណាធ្វើអោយទឹកនឹងបានទេ ទឹកតែងតែក្រឡុកជានិច្ច តែកាលបើព្យាយាមធ្វើអោយបានច្រើនថ្ងៃទៅ ទឹកនឹងក្រឡុកតិចចុះម្តងបន្តិចៗ ទាល់តែនឹងបាន បើបានដូច្នេះហើយ គប្បីជ្រាបថា យើងមានលក្ខណៈ មាំទាំឡើងហើយ ***សមាធិ*** ក៏


www.budinst.gov.kh www.elibraryofcambodia.org

មាំឡើងហើយ ។

មែនពិតកែវទឹកដូចពោលមកខាងលើនេ ជាគ្រឿងវាស់លក្ខណៈមនុស្សបានយ៉ាងប្រសើរ ល្បងយកមនុស្សដែលមានចិត្តច្រលេសច្រលាស់ជាប្រក្រតី ឬមនុស្សដែលធ្វើអ្វីមិនប្រាកដប្រជាមកឈរកាន់កែវទឹក តាមវិធីដូចពោលមកហើយនោះ ទឹកនឹងក្រឡុកខ្លាំងបំផុត តែមនុស្សដែលមាននិស្ស័យរាបទាប មិនច្រលេសច្រលាស់មាននិស្ស័យខ្ជាប់ខ្ជួនរួចហើយនោះនឹងកាន់កែវទឹកអោយក្រឡុកតិចបំផុត ។

ការត្រាទុក នូវការគិតឃើញរបស់ខ្លួនដែលបានមកថ្មី រាល់ៗថ្ងៃ ក៏ជាការជួយអោយកើត កំឡាំងសមាធិបានយ៉ាងល្អបំផុត ។

***វីរបុរស*** និង***មហាបុរស*** គ្រប់រូប សុទ្ធតែចំណាយពេលវេលាមិនច្រើនក៏តិចសរសេរត្រាទុកនូវចំណេះ ឬ គតិដែលបានមកថ្មីរាល់ៗថ្ងៃ សឹងគ្មានលោះថ្ងៃ ។ ថ្ងៃណាគ្មានរឿងត្រាទុកទេ ក៏នឹងថាខ្លួនខាតពេលអស់មួយថ្ងៃដោយគ្មានបានទទួលចំណេះ ឬ គតិណាមួយកើតឡើងថ្មីឡើយ ហើយក្នុងថ្ងៃនេះខ្លួនឥតមានឆ្លាតឡើងជាងថ្ងៃម្សិលសោះ នេះឯងជាការតូចចិត្តរបស់ ***វីរបុរស*** និង***មហាបុរស*** ។ ព្រោះហេតុនោះកាល ***វីរបុរស*** និង***មហាបុរស*** ម្នាក់ៗស្លាប់ទៅ សុទ្ធតែបន្សល់នូវការត្រាទុកនូវចំណាំរបស់ខ្លួនទុក ជាសៀវភៅក្រាស់ៗ ជាច្រើនក្បាល រដ្ឋាភិបាលក៏យកមកបោះពុម្ពផ្សាយ ដើម្បីជាប្រយោជន៍ដល់មនុស្សទូទៅ ។

តាមដែលបរិយាយមកនេះ លោកអ្នកអានជាទីគោរពនឹងឃើញបានថាការធ្វើចិត្តអោយជា ***សមាធិ*** នោះ មិនមែនជាការហួសសមត្ថភាពរបស់មនុស្ស


www.budinst.gov.kh www.elibraryofcambodia.org

ទេ ។ តាមពិតគឺជារបស់ចាំបាច់សំរាប់មនុស្សគ្រប់រូបគ្រប់នាម មិនចំពោះតែអ្នកត្រូវការបន្ទះវិបស្សនាកម្មដ្ឋាន តាមវត្តអារាមប៉ុណ្ណោះទេ ។ ***សមាធិ*** ជាគុណសម្បត្តិ ដែលចូលជ្រកនៅគ្រប់ចរិយាគ្រប់បែបយ៉ាងរបស់មនុស្ស ។ ចំណោះអាចរៀនទាន់គ្នាបានទាំងអស់ តែមនុស្សដែលបានរៀនមកស្មើគ្នា បានមកធ្វើការដូចគ្នា ម្នាក់ធ្វើហើយក្នុងមួយម៉ោង ត្រឹមត្រូវរៀបរយល្អ ម្នាក់ទៀតធ្វើហើយក្នុង ៦ ម៉ោង តែនៅមានភ្លាំងភ្លាត់ខ្វះខាត មនុស្សខ្លះដែលអង់អាចមែនៗ ធ្វើការបានស្មើអ្នកដទៃធ្វើ ៥-៦ នាក់ យ៉ាងនេះ ក៏ព្រោះមានសមាធិល្អ ចំណែកម្នាក់ទៀតមិនមាន ឬក៏មិនគ្រប់គ្រាន់សេចក្តីពិតគឺដូច្នេះឯង ។

រឿង ***សមាធិ*** នេះគ្រាប់ជាតិគ្រប់ភាសា ពិសេសគ្រប់លទ្ធិសាសនា សុទ្ធតែមានវិធីហ្វឹកហាត់ នឹងជាគុណសម្បត្តិបឋមបំផុត សំរាប់អ្នកត្រូវការសេចក្តីសំរេចសព្វយ៉ាង ។ ពិសេសមក ខ្មែរយើងដែលកាន់ព្រះពុទ្ធសាសនា ច្រើនមើលហួសនូវវត្ថុល្អរបស់ខ្លួនដោយពុំដឹងខ្លួនក្នុងទ្រឹស្តីពុទ្ធសាសនាដែលពោលពីផ្លូវកណ្តាល (មជ្ឈិមាដិបទា) ទាក់ទងនឹងអដ្ឋង្គិកមគ្គមាន ៨ the eight tolds path of Buddhism) នោះគឺរាប់ ***សមាធិ*** នោះជាទី ៨ គឺសម្មាសមាធិ (Right concentration) ដែរ ។

ក្នុងសៀវភៅ ***មនោមយិទ្ធិ*** របស់យើងខ្ញុំក៏មានបញ្ចូលរឿង ***សមាធិ*** នេះដោយច្រើនដែរសូមលោកអ្នកអានសិក្សាដោយសង្ខាត ឱហាតដោយប្រពៃចុះ ។

នេះជា " ***កូនសោ*** " សំរាប់ ***សំណាងខ្លួនឯង*** ។



www.budinst.gov.kh www.elibraryofcambodia.org

# ៤. ការជឿក្លួនខ្លួនឯង

## SELF CONFIDENCE

ក្នុងសៀវភៅ <<**ជួយខ្លួនឯង**>> (Self help) ដែលមានចេញឈ្មោះម្តងខាងដើមមកហើយ លោក **សាមូអែលស្មែល** បានពោលពាក្យ នៅជំពូកទី១ ពីរឿងជួយខ្លួនឯង ជួយជាតិ មួយឃ្លាថា << Help yaurself first , The god will help you **អាទិទេពជួយមនុស្សដែលជួយខ្លួនឯង**>> ព្រះពុទ្ធសាសនាខ្មែរយើង ក៏មានភាសិតថា <<**អត្តាហិ អត្តនោ នាថោ** you are your own refuge>> ទាំងនេះជាភាសិត ដែលបានពិសោធប្រើមកដោយប្រពៃណីហើយ ។ សេចក្តីតែពីរបីមាត់ប៉ុណ្ណោះ ប្រមូលចុះ នូវការប្រព្រឹត្តដែលមនុស្សបានជួយប្រសបមកហើយយ៉ាងទូលំទូលាយ ។ ការគិតជួយខ្លួនឯងនោះជាបុគ្គលនៃការលូតលាស់តាមធម្មជាតិក្នុងខ្លួនមនុស្ស ជាដែនកើតដ៏ពិតប្រាកដ នៃស្ថិរភាពនិងភាពខ្លាំងក្លារបស់ជាតិ ។ ជំនួយដែលមកពីខាងក្រៅ ច្រើនតែមានផលទាបទន់ តែជំនួយដែលចេញមកពីខាងក្នុង តែងមានកំឡាំងខ្លាំងមិនប្រែប្រួល ។ ផលដែលកើតដល់មនុស្សភាគច្រើនក្តី ដល់ក្រុមវណ្ណៈបុគ្គលក្តី **ដោយច្រើនតែងបានមកអំពីការចាំបាច់** ដែលមនុស្សត្រូវធ្វើសំរាប់ខ្លួនឯង ។ ហើយក្នុងទីណាមនុស្សទាំងឡាយត្រូវនៅក្រោមបញ្ញាឃុំគ្រងរបស់អ្នកដទៃគ្រប់



www.budinst.gov.kh www.elibraryofcambodia.org

ជំហាននោះ ផលដែលនឹងមានឡើង យ៉ាងជៀសមិនផុត ក៏គឺធ្វើអោយមនុស្សទាំងនោះ ក្លាយជាមនុស្សដែលឥតប្រយោជន៍ ។

នៅខាងដើម យើងខ្ញុំបានពោលឃ្លាមួយថា សេចក្តីទាល់ក្រ ជាហេតុអោយមនុស្សត្រូវបានសេចក្តីព្យាយាមប្រកបអំពើល្អ ហើយកាលសេចក្តីព្យាយាមនេះខ្លាំងក្លា ក៏រមែងជាផលល្អចំពោះខ្លួន និងដល់ ***ប្រទេសជាតិ*** ផង ។ បើមនុស្សគ្រប់រូបគ្មានការចាំបាច់ ត្រូវតស៊ូ សេចក្តីទាល់ក្រទេនោះ ពិភពលោកយើង ក៏នឹងគ្មានការលូតលាស់ដល់ថ្នាក់នេះឡើយ ។

មែនពិត មនុស្សយើង ត្រូវតែអាស្រ័យអ្នកដទៃ តាំងពីកើតមករហូតដល់ជីវិតរលត់ ។ បើនរណាអួតថា ឥតត្រូវអាស្រ័យនរណាឡើយ ជននោះជាមនុស្សកុហកយ៉ាងមុខក្រាស់ តែថាខ្លួនត្រូវធ្វើខ្លួនអោយមានសមត្ថភាពជាទីពឹងដល់ខ្លួន និងដល់អ្នកដទៃបាន នៅថ្ងៃណាមួយអោយបានជាទីពឹងពំនាក់របស់លោកអ្នក ដែលខ្លួនធ្លាប់ពឹងមកហើយដូចយ៉ាងមាតាបិតា ឬអ្នកមានគុណូបការទាំងឡាយ និងរបស់អ្នកដែលខ្លួនមាននាទី ដោយធម្មជាតិត្រូវជួយតទៅ ដូចយ៉ាងបុត្រភរិយា នរណាចាំតែពឹងអ្នកដទៃ ជានិច្ចជាកាល មិនគិតពឹងខ្លួនឯង និងមិនធ្វើខ្លួនអោយបានជាទីពឹងដល់អ្នកដទៃបានខ្លះទេនោះ រាប់ថាកើតមកបង្ហិនតែជាតិកំណើត នាំអោយចង្អៀតលោក ។

ចុះអ្វីជាហេតុអោយមនុស្ស អាចពឹងខ្លួនឯង និងជាទីពឹងអ្នកដទៃបានផង ចម្លើយក្នុង២ នេះគឺ <<***ត្រូវមានការជឿក្នុងខ្លួនឯង***>> ។



www.budinst.gov.kh www.elibraryofcambodia.org

មានមនុស្សជាច្រើនមើលងាយខ្លួនរបស់ខ្លួន គិតថាខ្លួនគ្មានសមត្ថភាព និងធ្វើអ្វីពុំកើតទេ ទើបជាហេតុអោយអស់មានៈឥតគិតធ្វើអ្វីខ្លះក៏និយាយថា <<ខួរក្បាលរបស់យើងមិនដល់គេទេ >> ខ្លះថា <<យើងគ្មានដីគ្រេ មហាវិទ្យាល័យដូចគេ>> ខ្លះក៏ក្រែងត្រូវរិះគន់និន្ទា រួមសេចក្ដីមក គឺមនុស្ស ទាំងនេះ គ្មានជំនឿក្នុងខ្លួនឯង និងក្រែងធ្វើទៅខុស ។

ការខ្លាចធ្វើខុសនោះឯង ជាហេតុអោយមនុស្សរួញរា មិនហ៊ានធ្វើអ្វី ដោយខ្លួនឯង ។ តែការពិតនោះ កំហុសនោះជាគ្រូបង្រៀនអោយយើងធ្វើ ត្រូវទេ មានពាក្យស្លោកដែល ***ណាប៉ូឡេអុង*** គិតឡើង និងកាន់យ៉ាងខ្ជាប់ខ្ជួន ជានិច្ចថា <<***ជនដែលមិនធ្លាប់ធ្វើអ្វីខុសសោះ ក៏គឺជនដែលមិនធ្លាប់ធ្វើអ្វី ឡើយ*** >> កិច្ចការសព្វយ៉ាងដែលនឹងនាំយើងទៅកាន់សេចក្ដីចំរើននោះ តែងត្រូវមានការប្រឡូកនឹងគ្រោះថ្នាក់ជានិច្ច ។ ក្នុងពិភពលោកនេះ គ្មានផ្លូវ ណាដែលរាបទាបរលីងស្មើសំរាប់នាំទៅកាន់សេចក្ដីចំរើន សូម្បីតែមួយ ឡើយ ។ យើងត្រូវតែរុកព្រៃពារបន្លាទៅទើបបាន អ្នកស្វះស្វែងរកអណ្តូង មាសពេជ្រ ត្រូវតែប្រឡូកនឹងគ្រោះថ្នាក់ បើមិនត្រូវខ្លាស៊ីទេ ក៏នឹងត្រូវមាន បាន ហើយការដែលនឹងមានបាន ក៏ព្រោះទុកចិត្តក្នុងខ្លួនឯងថា អាចតស៊ូនឹង ខ្លាបានបានហើយនឹងទៅដល់អណ្តូងពេជ្រនោះ ។ មនុស្សដែលអាចនាំខ្លួន ឡើងកាន់ភាពខ្ពង់ខ្ពស់ដល់ថ្នាក់ ***វីរបុរស*** ឬ ***មហាបុរស*** នោះ ក៏សុទ្ធតែមាន ជំនឿក្នុងខ្លួនឯង នឹងហ៊ានប្រឡូកនឹងគ្រោះថ្នាក់ទាំងអស់ ។ ***វីហ្សីលីយ៉ី*** ហ៊ាន បញ្ជាប្រហារជីវិត និងដាក់គុកអ្នកធំៗសំខាន់ៗ ដូចមានពោលមកហើយ ក៏



www.budinst.gov.kh www.elibraryofcambodia.org

ព្រោះជឿជាក់ថាខ្លួនធ្វើត្រូវ និងមិននាំពារ ចង់ដឹងថា អ្នកដទៃយល់ឃើញចំពោះខ្លួនដូចម្តេច រហូតដល់វារៈទីបំផុតដែល ***វីហ្សីលីយ៉ី*** ជិតស្លាប់ ក៏នៅតែសំដែងការទុកចិត្តចំពោះខ្លួនឯង ។ ពោលគឺដល់ឈឺធ្ងន់វិញ្ញាណទៅស្ថានសួគ៌ តាមលទ្ធិគ្រិស្តសាសនា លោកសង្ឃបានអោយឱវាទដល់ ***វីហ្សីលីយ៉ី*** ថា << ***ចូរអោយអភ័យដល់សត្រូវរបស់អ្នក*** >> ***វីហ្សីលីយ៉ី*** ឆ្លើយថា << ***ខ្ញុំគ្មានសត្រូវក្រៅពីសត្រូវរបស់ប្រទេសបារាំង*** >> ជាការសំដែងអោយឃើញការជឿជាក់ក្នុងចិត្តម្តងទៀតថាអ្វីៗ ដែលខ្លួនធ្វើមកហើយនោះឥតមានខុស ។ ការពិតដូច្នោះមែន ***វីហ្សីលីយ៉ី*** បានធ្វើប្រយោជន៍ដ៏មហិមាទុកអោយប្រទេសរបស់ខ្លួនទាល់តែមនុស្សទាំងអស់ទទួលស្គាល់ថាគ្មាននាយករដ្ឋមន្ត្រីណាធ្លាប់បានធ្វើដល់កំរិតហ្នឹង ចរិយារបស់ ***វីហ្សីលីយ៉ី*** ជាឧទាហរណ៍ដែលវីរជនទាំងឡាយ បាននាំយកទៅប្រើតៗគ្នាជាច្រើនតំណ ។

រឿងមួយទៀតនោះ គឺ ***ឌីស្រាអែលី*** ប្រកួតជាមួយ ***គ្លេតស្តូន*** អស់មួយជីវិត ម្នាក់ទម្លាក់ម្នាក់ហើយឡើងកាន់តំណែងនាយក ម្នាក់ទៀតទម្លាក់ម្នាក់ទៀតឡើងកាន់តំណែងនាយក ។ ការទម្លាក់គ្នាម្តងម្នាក់ ហើយឡើងកាន់តំណែងនេះ ក៏មកពីការជឿជាក់ប្រាកដក្នុងខ្លួនឯងថា អាចនឹងធ្វើបានល្អជាង ។ ការដែលជឿងនេះ មិនមែនជឿបែបសើៗទេ គឺជឿដោយមានហ្ល័កមានហេតុផល និងធ្វើបានល្អពិតៗផង ។ ***អូ កូ បូ*** ជានាយករដ្ឋមន្ត្រី ***ជប៉ុន*** មុនគេបង្អស់ដែលនាំយកអារ្យធម៌លោកខាងលិចចូលមកចាត់ការក្នុង ***ប្រទេសជប៉ុន*** នោះ គឺជាការក្រឡាប់ផែនដី និងប្រឆាំងលើទឹកចិត្តជនជាតិ


www.budinst.gov.kh www.elibraryofcambodia.org

***ជប៉ុន*** សឹងទូទាំងប្រទេស តែការដែលធ្វើដូច្នោះនោះ ក៏ព្រោះចិត្តជា នឹងជឿថាខ្លួនគិតត្រូវ ។ មែនពិតជំនឿនេះ ជាផលអាក្រក់ចំពោះ ***អូ កូ បូ*** រហូតដល់ត្រូវគេចាក់ស្លាប់នៅកណ្តាលថ្នល់ តែក៏គ្មាននរណាបដិសេធថា ព្រោះតែជំនឿក្នុងខ្លួនឯងរបស់ ***អូ កូ បូ*** នោះ ជាហេតុអោយ ***ប្រទេសជប៉ុន*** ក្លាយទៅជាមហាប្រទេសបាននោះទេ ។ ***ណាប៉ូឡេអុង*** ប្រាថ្នាជាម្ចាស់លើ ***ទ្វីបអឺរ៉ុប*** ក្តី ។ ***ប៊ីសមារក៍*** ប្រាថ្នារួបរួមអាណាចក្រ ***អាល្លឺម៉ាញ*** ក្តីវេលាដែលគិតនោះបើយកគំនិតនោះទៅបកស្រាយ អោយពីណាមួយស្តាប់ ក៏នឹងត្រូវគេទាយថាឆ្កួត ឬ ក៏ជាការយល់សប្តិព្រោះគ្មានពីណាជឿថា អាចធ្វើបានដល់ថ្នាក់នេះ ។ តែជនទាំងនេះឥតប្រាប់ជនណាទេ ឥតត្រូវការគំនិតយោល់របស់អ្នកណាទេ ជឿមាំចំពោះខ្លួនឯងថា អាចនឹងធ្វើបាន ក៏សុខចិត្តយកជីវិតទៅប្តូរ ទើបធ្វើបានសំរេច ហើយទីបំផុតក៏សំរេចបានពិតប្រាកដ ។

ពាណិជ្ជករ ជាច្រើនដែលតែងពោលថា ការទុកចិត្តចំពោះខ្លួនឯង ជាខសំខាន់បំផុត ខាងពាណិជ្ជកម្ម ។ អ្នកលក់ដូរដែលមិនចេះឃើញមាន ក៏ព្រោះមិនទុកចិត្តខ្លួនឯង ខ្លាចខាត ខនេះយើងគួរជឿជាក់ថាជាការពិតបំផុតៗ មហាសេដ្ឋីជាតិ***ប៊ែល្ស*** ឈ្មោះ ***លេអូវេនស្តែន៍*** Léovenstein ជាសេដ្ឋីទី៣ក្នុងលោកបន្ទាប់ពី ***រ៉ុក្កហ្វែល្ល័រ*** (Roekfeller) និង ***ហ្វ័រដ*** (Ford) ដំបូងកាលអាយុ ២០ឆ្នាំ តាំងហាងមួយប្រកបរបរ ប្តូរប្រាក់ ។ តែលក្ខណៈរបស់ ***លេអូវេនស្តែន៍*** ជាមនុស្សហ៊ានបង់ហ៊ានបានរបស់ណាដែលខ្លួនគិតល្អិតល្អន់ឃើញថាគំនិតរបស់ខ្លួនត្រឹមត្រូវហើយ ក៏មានជំនឿមុតមាំចំពោះខ្លួនឯង ឥត


www.budinst.gov.kh www.elibraryofcambodia.org

ចាំបាច់ប្រឹក្សានឹងនរណាឡើយ មិនត្រេកអរទទួលពាក្យដឹកនាំរបស់ជនណា ដែលលើកក្តោងអោយទុកខួចទេ ។ ហេតុនោះតាមប្រក្រតី ***លេអូវេនស្តែន៍*** មានលេខាធិការ ២ នាក់ និងអ្នកអង្គុលីលេខ ៣ នាក់ ជាប់តាមខ្លួនជានិច្ច យល់អាផាត្រថ្មើណាក៏ដោយ តែគិតឃើញអ្វីឡើងភ្លាម ក៏ដាស់លេខាធិការ ឡើងសរសេរលិខិត ឬក៏វាយទូរលេខភ្លាមៗ ។ ***លេអូវេនស្តែន៍*** កាន់កិច្ចការ ប្រាក់ទាំងលានៗហាក់ដូចជាមានតម្លៃមួយកាក់ដូច្នោះ ធ្វើអ្វីដោយឥតខ្លាច ខុស ឬក៏មានការមិនអស់មិនហើយ ក្នុងសមត្ថភាពរបស់ខ្លួនឡើយ ។ មែន ពិត មនុស្សប្រភេទនេះ គង់តែមានធ្វើខុសមកក៏ច្រើនដែរ តែកាលណាធ្វើ ខុស ក៏កត់ចំណាំចាំទុកក្នុងខួរក្បាលសំរាប់ជាគ្រូ និងព្យាយាមកែកំហុសរបស់ ខ្លួនតទៅ ។ ***លេអូវេនស្តែន៍*** ស្លាប់ដោយធ្លាក់ពីលើយន្តហោះ ដោយពុំដឹង បុព្វហេតុមកពីអ្វី តែទោះបីដូចម្តេចក៏ដោយក្នុងពេលស្លាប់ទៅ អាយុ ៥០ ឆ្នាំយនេះបានបន្សល់ទ្រព្យសម្បត្តិអោយដល់បុត្រភរិយារាប់លានដុល្លា (រៀល) ។ ថ្ងៃដែល ***លេអូវេនស្តែន៍*** ស្លាប់បានធ្វើអោយផ្សារប្តូរប្រាក់នៅ ***ប៊ិរឺស ឡុងដ៍ ញីវយ៉ក*** រំដើបរំជួលតៗគ្នា ក្រុមហ៊ុនខ្លះមានដល់ធ្លាក់រលំ ព្រោះភាគហ៊ុនស្រុតតម្លៃភ្លាមៗទាក់ទងមកពីមរណភាពរបស់គាត់ ។ ***លេអូវេនស្តែន៍*** ធ្លាប់បានត្រូវរដ្ឋាភិបាលខ្ចីប្រាក់ផ្ទាល់ខ្លួនដល់ទៅ ៥០ លាន ដុល្លា ដោយគិតការប្រាក់តែ ២ ភាគរយមួយឆ្នាំ មិនលំបាកដល់រដ្ឋាភិបាល ត្រូវទៅខ្ចីពីប្រទេសដទៃ ដែលត្រូវអោយការប្រាក់ ៨ ភាគរយយ៉ាងតិច ។


www.budinst.gov.kh www.elibraryofcambodia.org

គ្មានអ្វីក្នុងលោកនេះ ដែលរារាំងការចំរើនរបស់មនុស្សស្មើនឹងការមិនទុកចិត្តចំពោះខ្លួនឯង ។ ការធ្វើអ្វីៗគ្រប់យ៉ាង បើយើងចាំប្រឹក្សានឹងជនដែលយើងស្គាល់ និងត្រូវការស្តាប់ការយើញរបស់ជនទាំងឡាយហើយ យើងក៏មិនអាចនឹងធ្វើការនោះៗបានឡើយ ព្រោះគ្មានកិច្ចការណាក្នុងលោកនេះបានទទួលការយល់ឃើញស្របគ្នារបស់ជនគ្រប់ៗគ្នាទេ ឧទាហរណ៍ងាយៗដូចជាយើង មានប្រាក់ច្រើន ចង់សាងសាលារៀននៅកន្លែងមួយ ទទួលកុមារាកុមារី ចូលមកសិក្សាដោយឥតគិតថ្លៃ យើងចេញថ្លៃខ្លួនយើងសំរាប់ផ្គត់ផ្គង់សាលារៀននោះ ហើយអោយប្រាក់ខែដល់គ្រូយ៉ាងថ្លៃ ដើម្បីអោយគ្រូល្អគំនិតដូចពោលនេះយើងឃើញថាល្អណាស់ ជាការកុសល ជាប្រយោជន៍ដល់មនុស្សជាតិ តែយើងសាកល្បងយកទៅប្រឹក្សាមិត្រភក្តិរបស់យើងមើល គង់តែមានអ្នកខ្លះប៉ុណ្ណោះ នឹងយល់ស្របតាម តែគង់មានជាច្រើននាក់ផ្សេងៗទៀត ទាញគំនិតរបស់យើងអោយទៅផ្សេងទៀត ។ ខ្លះគង់អោយយោបល់ថា <<ទៅធ្វើអ្វីសាលារៀនមានពេញនគរទៅហើយ យកប្រាក់ទៅជួយមន្ទីរពេទ្យល្អជាង >> ខ្លះអោយយោបល់ថា ធ្វើមណ្ឌលចិញ្ចឹមក្មេងកំព្រាល្អជាង>> ហើយសម្លេងខ្លះក៏នឹងមានឡើងថា <<ធ្វើមណ្ឌលចិញ្ចឹមស្មូមយាចកវិញល្អជាងព្រោះឥឡូវនេះ ស្មូមយាចក ក្នុងស្រុកយើងនៅពាសពេញតាមថ្នល់ ខ្មាស់ជនបរទេស >> ខ្លះក៏ថា <<ទំនុកបំរុងវត្តអារាមល្អជាង >> ខ្លះថា <<យកប្រាក់នេះទៅទំនុកបំរុង ខាងអាកាសចរណ៍វិញ ព្រោះនឹងលើកកិត្តិយសប្រទេសជាតិមាតុភូមិ>> ដូច្នេះៗគ្មានទីបំផុត ។ មែនពិត គំនិត


www.budinst.gov.kh www.elibraryofcambodia.org

យោបល់ទាំងនោះ ក៏សុទ្ធតែល្អៗទាំងអស់ តែធ្វើអោយចិត្តយើងបែក រហូតដល់អស់សទ្ធា ក្នុងការសាងសាលារៀន និងយកប្រាក់នោះទៅធ្វើអ្វីក៏លែងប្រាកដក្នុងចិត្តទៅហើយ ព្រោះអ្នកនេះនិយាយថាអីចេះ អ្នកនោះនិយាយថាអីចុះ ហើយសុទ្ធតែល្អៗដូចគ្នា ។ ទីបំផុតក៏លែងធ្វើអ្វីតែម្តង តែបើយើងគិតថា ធម្មជាតិបានសាងគំនិតមកអោយយើងគ្រប់ៗគ្នា ដូចពាក្យរបស់លោក ***អេមឺនសាន់*** (Emerson) ថា (Every one has his own soul) ***គ្រប់គ្នាមានអាត្មនរបស់គេ >>*** ដូច្នេះហើយ ក៏គួរប្រើគំនិតផ្ទាល់របស់យើងបានខ្លះដោយមិនបាច់ពឹងតែគំនិតដទៃជានិច្ចនោះទេ ។

ការមិនទុកចិត្តចំពោះខ្លួននោះ ជាហេតុមួយដែលនឹងនាំអន្តរាយ និងការហិនហោចមកដាក់ខ្លួន ។ ជនដែលគិតថាខ្លួននឹងធ្វើខុស ច្រើនតែធ្វើខុសមែន ។ ជនដែលខ្លាចធ្វើអ្វីខុស ច្រើនតែធ្វើខុសមែនៗ ។ យើងយកក្តារមួយបន្ទះដាក់ជាស្ពាន ខ្ពស់បំផុតពីដីចំនួនមួយហត្ថ យើងអាចដើរលើស្ពាននោះបានដោយឥតធ្លាក់ និងរត់ក៏បាន ឬ យកសំពត់រុំមុខ ក៏អាចដើរបាន ព្រោះមានជំនឿក្នុងខ្លួនថាមិនធ្លាក់និងមិនខ្លាចធ្លាក់ផង ។ ឥឡូវយើងល្បងយកក្តារបន្ទះនោះដាក់ឆ្លងលើផ្ទះថ្មខ្ពស់ ៤-៥ ជាន់ ហើយល្បងដើរមើល នឹងត្រូវហាក់កញ្ជាញចេកមកជាពុំខាន ព្រោះការមិនទុកចិត្តខ្លួនឯង និងការខ្លាចធ្លាក់នោះឯងជាហេតុ ។ តែបើជាងឈើ ជាងកំបោរ អាចដើរបានយ៉ាងស្រួលដូចខ្ពស់ពីដីប្រហែលមួយហត្ថ ក៏ព្រោះពួកនោះ ជឿក្នុងចិត្ត និងមិនខ្លាចធ្លាក់នោះឯង ។ ដូចម្តេចក៏ដោយ ការប្រកបកិច្ចការគ្រប់យ៉ាង ក៏ដូច្នោះដែរ រិត


www.budinst.gov.kh www.elibraryofcambodia.org

តែកិច្ចការធំដុំទៅទៀតនោះ ការជឿក្នុងខ្លួនឯង ក៏រឹតតែសំខាន់ច្រើនឡើង ។ ដូចនេះ ក្នុង ***ទស្សនវិជ្ជា*** លោកខាងលិច គេប្រដៅមិនអោយមនុស្សមើលងាយសតិប្រាជ្ញា និងសមត្ថភាពរបស់ខ្លួនឯង ព្រោះ ***គុណសម្បត្តិ*** ទាំងនេះ ធម្មជាតិបានសាងមកអោយយើងយ៉ាងប្រពៃ គ្រប់រូបគ្រប់នាមហើយ ហើយល្អប្រពៃជាងយើងនឹកគិតទៅទៀត តែបើយើងមិននាំយកចេញមកប្រើ ក៏នៅតែជារបស់ដែលប្រើការមិនបានជានិច្ចជាកាល នរណាគ្មានជំនឿក្នុងខ្លួនឯងហើយ និងគ្មានឱកាសធ្វើអ្វីបានឡើយក្នុងលោកនេះ ។

នេះជា " ***កូនសោ*** " សំរាប់ ***សំណាងខ្លួនឯង*** ។

* * * * *



www.budinst.gov.kh www.elibraryofcambodia.org

# ៥. មនោមយិទ្ធិ

## WILL POWER

គ្រាន់តែនឹកដល់ ***មនោមយិទ្ធិ*** ភ្លាមលោកអ្នកអានជាទីគោរព និងនឹកឃើញដល់សៀវភៅអ្វីមួយជាមិនខាន គឺសៀវភៅ ***មនោមយិទ្ធិ*** ដែលយើងខ្ញុំបានបោះពុម្ពផ្សាយរួចហើយនោះ ដូច្នេះសេចក្តីពិស្តារមាននៅស្រាប់ក្នុងទីនោះហើយ ចំពោះទីនេះយើងខ្ញុំសូមអធិប្បាយត្រឹមតែលក្ខណៈនៃ***វីរបុរស*** ឬ ***មហាបុរស*** ប៉ុណ្ណោះ ។

***មនោមយិទ្ធិ*** មានលក្ខណៈប្រហាក់ប្រហែល នឹងភាពជាអ្នកមានចិត្តរឹងប៉ឹង តែខសំខាន់ដែលខុសគ្នានៅត្រង់ចិត្តរឹងប៉ឹងជាផ្នែកខាងទប់ទល់ (Defensive) ។ ***មនោមយិទ្ធិ*** ជាផ្នែកខាងលុក (offensive) ចិត្តរឹងប៉ឹងជាគ្រឿងទប់ទល់ស៊ូការលំបាក ។

***មនោមយិទ្ធិ*** ជាគ្រឿងនាំអោយសំរេចផលដែលត្រូវការ ។

លោកអ្នកអានក្នុងសៀវភៅ ***មនោមយិទ្ធិ*** នឹងបានឃើញមកហើយថា ក្រសែដួងចិត្តនោះ មានអំណាចពីរប្រការគឺ : អំណាចដែលទាក់ទាញយកផលដែលត្រូវការមកអោយយើងម្យ៉ាង ។ ម្យ៉ាងទៀតជាគ្រឿងបញ្ជាសត្រូវអោយចុះចាញ់យកជ័យជំនះបានដោយកំឡាំងដួងចិត្ត ។



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងប្រការខាងដើម យើងបានឃើញហើយថា ***វីរបុរស*** ឬ ***មហាបុរស*** គ្រប់រូបមានសេចក្ដីត្រូវការដ៏ខ្លាំងក្លា ដើម្បីសំរេចផលដែលខ្លួនបំណង ។ សេចក្ដីត្រូវនោះជាកម្លាំងភ្លើងឆេះនៅជានិច្ច ធ្វើការសព្វយ៉ាងដើម្បីអោយសំរេចផលតែបុំណ្ណោះអោយបាន ហើយទីបំផុតក៏សំរេចបានពិតៗ ។ ក្នុងប្រការទី ២ មនុស្សដែលនឹងឡើងកាន់អំណាចដ៏ធំបំផុតបាននោះ ត្រូវមានអំណាចនៃដួងចិត្ត ដ៏ខ្លាំងគ្រប់គ្រាន់សង្កត់លើទឹកចិត្តជនដទៃបាន បើពុំដូច្នេះទេ ហេតុអ្វីក៏ជនជាតិ ***បារាំងសេស*** ទាំងប្រទេស សុខចិត្តអោយ ***ណាប៉ូឡេអុង*** ដែលមិនមែនកំណើតជាបារាំងសេស ធ្វើជាចៅហ្វាយរបស់ខ្លួន និងសុខចិត្តនៅក្រោមបង្គាប់បញ្ជា ទទួលធ្វើការគ្រប់យ៉ាងដែល ***ណាប៉ូឡេអុង*** បង្គាប់អោយធ្វើ ... ។ ហេតុអ្វី ***ណាប៉ូឡេអុង*** ទើបអាចធ្វើអោយមនុស្សទាំងកងទ័ព ដែលស្ដេច ***លួីសទី ១៨*** បញ្ជូនទៅអោយចាប់ខ្លួននោះ ប្រែចិត្តចូលមកខាងខ្លួន ត្រឡប់មកច្បាំងនឹងសត្រូវបានទៀត ។ ហេតុអ្វី ***ឌីស្រាអែលី*** ទើបធ្វើអោយជនជាតិ ***អង់គ្លេស*** ដែលធ្លាប់ស្អប់ខ្ពើមខ្លួនថាជា ***ហ្សីហ្វ*** (Juif) បែរមកស្រឡាញ់ខ្លួន និងភ្លេចនឹកដល់ខ្ទង់ច្រមុះកោង បង្ហាញនូវលក្ខណៈមុខមាត់ជា ហ្សីហ្វនោះអស់រលីង ... ។ ហេតុអ្វី ***មូស្សូលីនី*** ជាមនុស្សជាន់ទាបបំផុត ទើបត្រឡប់ជាបានទទួលការនិយមរាប់អានកោតក្រែងរបស់មនុស្សជាន់ខ្ពស់បំផុត ។ ហេតុការណ៍ទាំងនេះ យើងត្រូវទទួលរាប់ថាសុទ្ធតែជាអំណាចនៃ ***មនោមយិទ្ធិ*** ទាំងអស់ ។


www.budinst.gov.kh www.elibraryofcambodia.org

ចំពោះ ***ណាប៉ូឡេអុង*** ក្នុងសៀវភៅ Arthurlévis ថាពេលដែលប្រជល់មុខនឹងកងទ័ព ដែលស្ដេច ***លូវីស៍ទី១៨*** បញ្ជូនទៅចាប់ខ្លួន កាលគាត់រត់ពីកោះមកឡើងគោកនោះ ទាហានទាំងកងឈរជាជួរភ្ជាប់កាំភ្លើងនឹងស្នា ត្រៀមស្រេចចាំតែបាញ់ ។ ***ណាប៉ូឡេអុង*** ដើរពើងទ្រូងតម្រង់ទៅរកកាំភ្លើង និងពោលយ៉ាងត្រជាក់ចិត្តថា ***អញ្ជើញបាញ់មេទ័ពចាស់របស់អ្នកមកចុះ*** រំពេចនោះ ចុងកាំភ្លើងក៏សំយ៉ុងចុះម្ដងមួយជាបន្តបន្ទាប់គ្នា រហូតអស់ទាំងក្រុម ។ ការពិតទាហានដែលស្ដេច ***លូវីស៍ទី ១៨*** បញ្ជូនទៅនោះ គឺពិតជាទ្រង់ជ្រើសសុទ្ធតែទាហានដែលមិនស្រឡាញ់ ***ណាប៉ូឡេអុង*** និងទាហានដែលបានសច្ចាថា ប្រតិបត្តិតាមបញ្ជារបស់ស្ដេច ***លូវីស៍ទី ១៨*** ។ តែហេតុអ្វីក៏ក្រឡះចិត្តមួយរំពេចដូច្នោះ និងពន្យល់ដោយគំនិតដទៃទៀតក៏មិនកើត ក្រៅពីថាជា ***មនោមយិទ្ធិ*** របស់ ***ណាប៉ូឡេអុង*** នោះឯង ។

ចុះ ***មនោមយិទ្ធិ*** នោះ មនុស្សយើងនឹងមានបានដោយវិធីណា ? ***មនោមយិទ្ធិ***នោះអាចមានបានពីរផ្លូវ គឺមាននៅក្នុងខ្លួនពីកំណើតមកមួយផ្លូវ និងដោយហ្វឹកហាត់បណ្ដុះឡើងខ្លួនឯងមួយផ្លូវទៀត ។

មនុស្សខ្លះ យើងអាចហៅបានថាកើតមកជានាយមនុស្ស ។ មនុស្សប្រភេទនេះ មាននិស្ស័យខ្លាំងក្លាមកតាំងតែពីតូច កាលត្រូវការអ្វីហើយ ត្រូវយកអោយបាន ដូចយ៉ាង ***ប៊ីសមារក៍*** មនុស្សប្រភេទនេះអាចសំរេចនូវវត្ថុដែលត្រូវការជានិច្ច កាលបើមានគោលបំណងជាក់លាក់ថា ខ្លួនត្រូវការអ្វី ។


www.budinst.gov.kh www.elibraryofcambodia.org

តែយ៉ាងណាក៏ដោយ ***មនោមយិទ្ធិ*** ជារបស់ដែលអាចបណ្តុះអោយមានឡើងក្នុងខ្លួនឯង ហើយអ្នកប្រាជ្ញទាំងឡាយអះអាងថា បើយើងចេះបណ្តុះអោយត្រូវវិធីហើយ នឹងប្រើបានល្អក្រៃលែងជាងដែលមានមកពីកំណើតទៀតផង ។ លោកប្រៀបថា មនុស្សដែលមាន ***មនោមយិទ្ធិ*** ពីកំនើតនោះ ប្រៀបដូចសំលៀកបំពាក់ដែលគេកាត់ហើយស្រេច យើងទៅទិញយកមក កម្រនឹងត្រូវសក្តិសមនឹងខ្លួនយើងណាស់ តែមនុស្សដែលមាន ***មនោមយិទ្ធិ*** បណ្តុះឡើងខ្លួនឯងនោះប្រៀបដូចទៅវាស់កាត់សំលៀកបំពាក់ថ្មី ទើបអាចសក្តិសមទម្រង់ល្អតាមបំណងរបស់ខ្លួន ។

ចំណែកវិធីដែលនឹងបណ្តុះនោះ តាមពិតក៏មិនសូវលំបាកណាស់ណាទេ តែមនុស្សយើងដោយច្រើនធ្វើមិនបាន ព្រោះខ្ជិលច្រអូសនិងធ្វើនោះម្យ៉ាង ឬក៏ម្យ៉ាងទៀតព្រោះមិនជឿងតែម្តង ។ វិធីដែលល្អបំផុតដែលគេចែងទុកនោះគឺថា នឹងធ្វើអ្វីៗគ្រប់យ៉ាងឲ្យមានសេចក្តីត្រូវការជាប្រាកដប្រជាប្រកបផងជានិច្ច ។ ឧទាហរណ៍ថា យើងចាប់ប៉ាក្កាឡើងសរសេរសៀវភៅត្រូវតាំងចិត្តអោយប្រាកដប្រជាជាងធម្មតាថា យើងនឹងចាប់ប៉ាក្កាឡើងយើងនឹងសរសេរសៀវភៅអោយចប់ក្នុងរយៈវេលាប៉ុណ្ណោះ ។ បើនឹងចាប់សៀវភៅឡើងអានក៏អោយគិតថា ***ត្រូវ*** អានសៀវភៅនេះអោយចប់ ត្រូវយល់សេចក្តីក្នុងសៀវភៅនេះទាំងអស់ ត្រូវចាំសាច់រឿងអោយបាន ។ ឥរិយាបថគ្រប់យ៉ាងសូម្បីរបស់បន្តិចបន្តួច ដូចយ៉ាងចាប់កៅអីបង្ខិតបន្តិច ក៏អោយតាំងចិត្តថា កៅអីនេះត្រូវបង្ខិត តាមដែលពោលមកនេះហាក់ជារបស់



www.budinst.gov.kh www.elibraryofcambodia.org

ងាយដូចកូនក្មេងលេង ។ តែការសិក្សាវិជ្ជាទាក់ទងនឹងដួងចិត្តគ្រប់ប្រភេទ លោកទូន្មានថា << ***កុំអោយការងាយឡកខ្លួនឯង*** >> ពោលគឺ កុំអោយមើលឃើញថាជារបស់ងាយទាល់តែជាហេតុអោយមើលងាយថា មិនបានផលអ្វី ហើយមិនធ្វើតាម ។ លោកទូន្មានថា បើឃើញថាជារបស់ងាយត្រូវល្បងធ្វើមើល និងដឹងភ្លាមថាមិនមែនងាយដូចយើងនឹកនោះទេ ហើយវិធីដែលពោលពីខាងដើមនោះ កាលបើព្យាយាមធ្វើបានគ្រប់ឥរិយាបថហើយ នឹងមានគុណប្រយោជន៍ជាច្រើនប្រការទៀត គឺការពារមិនអោយយើងគ្មានសម្បជញ្ញៈ ធ្វើអ្វីដោយគ្មានចិត្តគ្រប់គ្រងប្រការមួយ នឹងធ្វើការនោះឲ្យបានសំរេចរៀបរយដោយរហ័សប្រការមួយ និងប្រការមួយទៀតនឹងធ្វើអោយដួងចិត្តយើងមានអំណាចជានាយលើវត្ថុសព្វយ៉ាង ធ្វើអោយមានលក្ខណៈមាំទាំរឹងប៉ឹងឡើងគ្រប់វេលា ។

មែនពិត មនុស្សយើងនឹងធ្វើអ្វីមួយ ក៏សុទ្ធតែសេចក្តីត្រូវការនាំមុខទាំងអស់ សេចក្តីត្រូវការនោះ ជួនកាលជាសេចក្តីត្រូវការបែបសើៗ គ្មានថាមពលភាព ដូចយើងដើរចូលទៅក្នុងបន្ទប់មួយ ដើម្បីមើលនាឡិកាក្នុងបន្ទប់នោះ តើវាត្រូវគ្នានឹងនាឡិកាដៃយើងទេ តែដល់ចូលទៅដល់បន្ទប់នោះ យើងក៏ភ្លេចបណ្តោយ នឹកមិនឃើញថា យើងចូលមកធ្វើអ្វី ត្រូវចំណាយពេលនឹកយូរបន្តិចទៅទៀត ជួនកាលខឹងនឹងខ្លួនឯងនឹកមិនឃើញបណ្តោយក៏មាន នេះគឺសេចក្តីត្រូវការយ៉ាងសើៗ តែបើហាត់ធ្វើតាមវិធីដែលពោលមកខាងដើមហើយ ទើបនឹងមានសេចក្តីត្រូវការដែលពិតប្រាកដ


www.budinst.gov.kh www.elibraryofcambodia.org

ជាប្រការអោយកើត ***មនោមយិទ្ធិ*** ។

លោកប្រដៅទុកម្យ៉ាងទៀតថា វេលាដើរទៅតាមផ្លូវណាៗអោយសំឡឹងមើលរបស់ដែលនៅខាងមុខផុតកន្ទុយភ្នែករបស់យើង ទោះជាវត្ថុអ្វីក៏ដោយ ហើយអោយធ្វើសេចក្តីត្រូវការដ៏មុតមាំថា យើង ***ត្រូវ*** ទៅដល់ទីនោះ ។ កាលទៅដល់ហើយយើងនៅត្រូវធ្វើដំណើរតទៅទៀត ឬក៏ងាយទៅខាងផ្លូវណា ក៏ត្រូវរកទីដៅដូចគ្នានឹងធ្វើចិត្តអោយមានសេចក្តីត្រូវការដ៏មុតមាំដូចគ្នា ។

វេលានិយាយនឹងអ្នកណា ក៏ត្រូវមានសេចក្តីត្រូវការដ៏ខ្លាំងអោយអ្នកស្តាប់ជឿពាក្យដែលយើងនិយាយ ។ កាលធ្វើចិត្តអោយមាំយ៉ាងនេះហើយពាក្យនិយាយរបស់យើងក៏នឹងមានទម្ងន់ខ្លាំងឡើង ។ សូមអោយសង្កេតថាជនដែលនិយាយអ្វីរបៀបហ្ញុយៗ គ្មានទម្ងន់អ្វីសោះនោះ រឿងដែលសំខាន់ក៏ក្លាយជាមិនសំខាន់ ឬ រឿងដែលពិតៗមែនៗ អ្នកស្តាប់បែរទៅជាយល់ថារឿងភូតភរលេងទៅវិញ ។

យើងគង់ធ្លាប់បានជួបមនុស្សខ្លះ ដែលមានចិត្តជានាយ (Master mind) ដែលធ្វើអោយយើងត្រូវញញើត ចំពោះមុខជនមានអំណាចដូច្នេះ យើងក៏ក្លាយជាស្រមោចមួយ ចំណេះដឹងទាំងឡាយដែលយើងបានរៀនក៏លិចបាត់អស់ មិនអាចលើកយកមកជជែកយកឈ្នះជននេះបានឡើយ របស់ដែលយើងមិនគួរយល់ស្របសោះ យើងត្រឡប់ជាយល់ស្រប យើងជាមនុស្សធ្វើត្រូវពិតៗ ត្រឡប់ជាត្រូវទទួលខុស តែកាលចេញមកផុតពីមុខជននេះ


www.budinst.gov.kh www.elibraryofcambodia.org

ហើយ យើងទើបឃើញ ខួរក្បាលភ្លឺស្វាង បើក្រៅពីមនុស្សនោះ យើងគង់តែនឹងយកឈ្នះបានដោយពិតៗ ។ ហេតុការណ៍ដូច្នេះនេះ យើងគង់ធ្លាប់បានជួបប្រសប់មកហើយ ជាច្រើនហើយបើទុកជាយើងរៀនសូត្របានមានចំណេះដឹងពូកែជាងគេប៉ុណ្ណា យើងក៏គង់ត្រូវចាញ់គេដដែល មានផ្លូវតែមួយដែលយើងនឹងយកឈ្នះជនប្រភេទនេះបាន ក៏គឺត្រូវបណ្តុះ ***មនោមយិទ្ធិ*** អោយកើតឡើងក្នុងខ្លួនយើង អោយយើងមានអំណាចដូចគេ ហើយកាលនោះយើងក៏នឹងមានអាវុធដូចគ្នានឹងគេ ឬល្អជាងគេ ល្មមថាក់គ្នាបាន ។

តាមន័យដែលពោលមកនេះ ឃើញបានថាការបណ្តុះ ***មនោមយិទ្ធិ*** នោះ មានល័ក្ខតែមួយគឺត្រូវធ្វើអោយមានសេចក្តីត្រូវការ ដ៏ខ្លាំងក្លាក្នុងកិច្ចការគ្រប់ៗយ៉ាងដែលយើងធ្វើវេលាហាត់ធ្វើជាដំបូងយើងនឹងឃើញថាជារបស់មិនបីបើនឹងនឹកអស់សំណើចខ្លួនឯង តែកាលធ្វើយូរៗទៅនឹងក្លាយជាគ្រឿងចក្រ ដែលយើងឃើញប្រើបានភ្លាមៗ ដោយមិនចាំចាប់នឹកទុកមុន ។ ពិធីការដែលយើងឃើញថា ជារបស់លេងនោះ ក៏ក្លាយជារបស់ពិតអាចនាំប្រយោជន៍ដ៏ធំដល់យើង ។

នេះជា " ***កូនសោ*** " សំរាប់ ***សំណាងខ្លួនឯង*** ។

❊ ❊ ❊ ❊ ❊



www.budinst.gov.kh www.elibraryofcambodia.org

# អវសានកថា

***គុណសម្បត្តិទាំង ៥ ប្រការ*** ដែលយើងខ្ញុំបានពិពណ៌នាមកនេះ សុទ្ធតែជាគ្រឿងឧករណ៍ដ៏សំខាន់អោយមនុស្សនាំខ្លួនឡើងទៅកាន់ឋានៈដ៏ខ្ពស់បាន នៅ៣៥ប្រការទៀតនោះក៏សំខាន់ក្រៃលែងដែរ តែបើយើងខ្ញុំនាំមកបរិយាយអោយអស់ក្នុងសៀវភៅនេះ សៀវភៅនឹងក្លាយទៅជាវចនានុក្រមទស្សនវិជ្ជាជាមិនខាន ហើយដែលលើសពីសេចក្តីត្រូវការនៃគោលបំនង ។ ក្នុងការរៀបរៀងសៀវភៅនេះ គឺដើម្បីនាំយកឧទាហរណ៍ដ៏ល្អ ជាគ្រឿងបង្ហាញផ្លូវរុញសន្ទុះទឹកចិត្តពួកយើងដែលនៅក្នុងយុវភាព អោយលះបង់ការខ្ជិលច្រអូសរួញរា ត្រឡប់ទៅជាមានពីព្យាយាមតំឡើងឋានៈអោយល្អឡើង ។ ព្រោះហេតុនោះការដែលនាំមកពោលតែត្រឹម៥ប្រការនេះ ក៏រាប់ថាគ្រប់គ្រាន់នឹងគោលបំណងហើយ ។

យើងប្រាថ្នាចង់ឃើញប្រទេសជាតិរបស់យើង ចំរើនលូតលាស់ស្មើមុខនឹងប្រទេសសូតលាស់ដទៃទៀត តែការចង់បានរបៀបនេះ នោះមនុស្សដោយច្រើនៗយល់ថា ត្រូវមានដែនដីធំទូលំទូលាយ មានប្រទេសចំណុះជាច្រើន មានដែនដីដ៏ធំ បង្ហាញដល់ពិភពលោក ការយល់បែបនេះ មិនខុសច្រើនទេ តែមិនត្រូវច្បាស់ប្រាកដ ព្រោះថាដែលពិតនោះ មិនមែនស្ថិតនៅលើដែនដីធំទេ គឺត្រូវស្ថិតលើតួបុគ្គល ។ ប្រទេសដែលចំរើន គឺពិតជាអាស្រ័យលើមនុស្សនៃប្រទេសនោះល្អរឹងប៉ឹង ឧទាហរណ៍ ដូចប្រទេស



www.budinst.gov.kh www.elibraryofcambodia.org

***អ៊ីស្រាអែល*** ក្នុងសម័យបច្ចុប្បន្ននេះ ជាភស្តុតាងស្រាប់ទោះបីមហាប្រទេសនានា ក៏ត្រូវតែទទួលស្គាល់ជាក់ទូត ទាក់ទងផ្លូវពាណិជ្ជកម្មជាដើម ។

ដូច្នេះ ការលូតលាស់នៃប្រទេសជាតិនីមួយៗនោះ គឺមកពីពលរដ្ឋស្គាល់ខ្លួនឯង ទុកចិត្តខ្លួនឯង មានការប្រឹងប្រែង ស្គាល់ករណីយកិច្ចពលរដ្ឋដែលត្រូវធ្វើចំពោះរដ្ឋ ហ៊ានទទួលខុសត្រូវ ក្នុងនាមរបស់ជាតិ ។

យើងខ្ញុំបានពោលមកហើយ ក្នុងបុព្វប្រយោគថាធម្មជាតិបានសាងកន្សែងបក់កន្សែងបោយ ទុកមកអោយមនុស្សគ្រប់រូប គ្រប់នាមគឺ ***<<ខួរក្បាល >>*** សៀវភៅនេះ តាំងពីដើមរហូតដល់ចប់ ក៏គឺត្រូវការសូមអោយម្នាក់ យកគុណសម្បត្តិដ៏ត្រឹមត្រូវមកគាស់ យកកន្សែងបក់កន្សែងបោយនេះចេញមកប្រើប្រាស់ ដើម្បីអភិវឌ្ឍន៍នូវសម្បជញ្ញៈផ្ទាល់ខ្លួន និងសម្បញ្ញៈជាតិ ដើម្បីអោយបានជាខ្លឹមមនុស្ស ខ្លឹមផែនដីតទៅរហូតដល់អវសានកាល ។

យើងខ្ញុំ ខំប្រឹងប្រែងរួបរួមរៀបរៀងសៀវភៅនេះ ពុំមែនជាការអួតអាងអ្វីទេ ឬក៏ថាប្រៀនប្រដៅអ្វីដល់ជនរួមជាតិក៏ទេដែរ គឺមានបំណងត្រឹមតែដាក់វិញ្ញាសា ជូនជនរួមជាតិដោះស្រាយរួមគ្នា រកផ្លូវដ៏ត្រឹមត្រូវដើរទៅកាន់វឌ្ឍនភាពនិងទុកសំណាងដល់អនុជនទៅអនាគតតទៅ ។

យើងខ្ញុំសូមបញ្ចប់ ដោយពាក្យស្លោកជាចុងក្រោយថា :

***<<ស្តុកមនុស្សល្អ ប្រសើរជាងស្តុកស្មៅ***
***តែបើស្តុកមនុស្សល្ងង់ខ្លៅ ស្តុកស្មៅប្រសើរជាង >>*** ។



www.budinst.gov.kh www.elibraryofcambodia.org

# ប៉ៃ ណែត

## តូបលេខ ២៥

(ផ្សារអូរឫស្សី ជាន់ឡៅតឿ)

**ទទួលបោះពុម្ពគ្រប់ប្រភេទ**

មានលក់ដុំ និង រាយ នូវសៀវភៅ
សិក្សា គ្រប់មុខដូចជា ចិន បារាំង
ជប៉ុន អង់គ្លេស ធមិ ចំរៀង......។

Tel: 012 977 668
011 823 668


www.budinst.gov.kh www.elibraryofcambodia.org